# ការសិក្សាអំពីការចាត់ចែងថវិកា
# សៀវភៅសំរាប់អ្នកបណ្តុះបណ្តាល

អង្គការពលកម្មអន្តរជាតិ

កម្ពុជា ២០០៨

# មាតិការ


សេចក្តីថ្លែងអំណរគុណ.................................................................... ៥

សេចក្តីផ្តើម.................................................................................. ៧

គោលបំណង និងកាលវិភាគ............................................................ ៩

ទម្រង់វាយតម្លៃប្រចាំថ្ងៃ.................................................................១១

មេរៀនទី ១: ការណែនាំអំពីកម្មវិធីបណ្តុះបណ្តាល និងសិក្ខាកាម.............................១៣

មេរៀនទី ២: ការបង្កើតគោលបំណងហិរញ្ញវត្ថុ.................................................. ១៥

ជំនួយការបណ្តុះបណ្តាលទី ១: គោលបំណងហិរញ្ញវត្ថុ........................................ ១៨

មេរៀនទី ៣: ការគ្រប់គ្រងប្រាក់កាសរបស់អ្នក.................................................... ១៩

ជំនួយការបណ្តុះបណ្តាលទី ២: កាបូបប្រាក់ " គ្រួសារ " "និងកាបូបប្រាក់អាជីវកម្ម "............... ២៣

ជំនួយការបណ្តុះបណ្តាលទី ៣: ប្រភពថវិកាចំណូល........................................... ២៤

មេរៀនទី ៤: ការប្រើប្រាស់ថវិកាផ្ទាល់ខ្លួន និងថវិកាកម្ចី ដើម្បីធ្វើអាជីវកម្ម..........................២៥

ជំនួយការបណ្តុះបណ្តាលទី ៤: ការសម្តែងរឿង " អាជីវកម្មទឹកសណ្តែករបស់នារីនិងចន្ថា "................. ៣០

ជំនួយការបណ្តុះបណ្តាលទី ៥: ប្រើប្រាស់ថវិកាកម្ចី ឬថវិការបស់អ្នក ដើម្បីផ្គត់ផ្គង់អាជីវកម្ម..................៣២

ជំនួយការបណ្តុះបណ្តាលទី ៦: បំណុលល្អ និងបំណុលអាក្រក់.................................................៣៣

ជំនួយការបណ្តុះបណ្តាលទី ៧: ពិភាក្សាអំពីការប្រើប្រាស់ថវិកាផ្ទាល់ខ្លួន និងថវិកាកម្ចី ដើម្បីធ្វើ
អាជីវកម្ម.................................................................................... ៣៤

មេរៀនទី ៥: គ្រោះថ្នាក់នៃការជាប់បំណុលធ្ងន់ធ្ងរ និងការខកខានមិនបានសង............................. ៣៥

ជំនួយការបណ្តុះបណ្តាលទី ៨: រឿងអ្នកខ្ចីប្រាក់បីនាក់........................................................ ៤១

ជំនួយការបណ្តុះបណ្តាលទី ៩: ក្រដាសកាតសម្រាប់ការសម្តែងរឿង......................................... ៤២

ជំនួយការបណ្តុះបណ្តាលទី ១០: ផលវិបាកនៃការមិនបានសងបំណុល................................... ៤៣

មេរៀនទី ៦: ការប្រៀបធៀបសេវាសន្សំប្រាក់...............................................................៤៥

ជំនួយការបណ្តុះបណ្តាលទី ១១: គុណសម្បត្តិនិងគុណវិបត្តិនៃប្រភេទសេវាសន្សំប្រាក់ផ្សេងៗ..................... ៥០

ជំនួយការបណ្តុះបណ្តាលទី ១២: ប្រភេទបញ្ញើប្រាក់នៅស្ថាប័នផ្លូវការ............................................ ៥២

ជំនួយការបណ្តុះបណ្តាលទី ១៣: ការផ្គូផ្គងគោលបំណងសន្សំប្រាក់ជាមួយប្រភេទបញ្ញើប្រាក់..................... ៥៣

ជំនួយការបណ្តុះបណ្តាលទី ១៤: ការពិភាក្សាអំពីការជ្រើសរើសសេវាផ្ញើប្រាក់...................................... ៥៤

**មេរៀនទី ៧: ការរៀបចំគំរោងថវិកាសម្រាប់គ្រួសារ................................................................... ៥៥**

ជំនួយការបណ្តុះបណ្តាលទី ១៥: ជំហានានាដើម្បីរៀបចំគំរោងថវិកា................................................. ៥៩

ជំនួយការបណ្តុះបណ្តាលទី ១៦: គំរោងថវិកាគ្រួសាររបស់ខ្ញុំ.......................................................... ៦០

ជំនួយការបណ្តុះបណ្តាលទី ១៧: តារាងប្រាក់ចំណូលនិងចំណាយមិនប្រក្រតី: ការប៉ាន់ប្រមាណប្រចាំខែ......... ៦១

ជំនួយការបណ្តុះបណ្តាលទី ១៨: គំរោងថវិកាគ្រួសារខ្ញុំ......................................................... ៦២

**មេរៀនទី ៨: ការអនុវត្តទៅតាមគំរោងថវិការបស់អ្នក........................................................... ៦៣**

ជំនួយការបណ្តុះបណ្តាលទី១៩: រឿងស្ត្រីពីរនាក់ខិតខំអនុវត្តឱ្យសមស្របតាមវង្ងថវិការបស់គេ................... ៦៧

ជំនួយការបណ្តុះបណ្តាលទី២០: វិធីសាស្ត្រទប់ស្កាត់ការប៉ុនប៉ងចំណាយ................................................ ៦៨

**មេរៀនទី ៩: ការរៀបចំផែនការសន្សំប្រាក់..................................................................... ៦៩**

ជំនួយបណ្តុះបណ្តាលទី ២១: ផែនការសន្សំប្រាក់របស់ខ្ញុំ.......................................................... ៧១

**ខ្លឹមសារមេរៀន........................................................................................................... ៧៣**

ក, សមភាពយេនឌ័រ.................................................................................... ៧៣

ខ, គំរោងថវិកា......................................................................................... ៧៤

គ, ការសន្សំប្រាក់: អ្នកអាចធ្វើបាន!........................................................................ ៨១

ឃ, ការគ្រប់គ្រងបំណុល: ដោះស្រាយដោយយកចិត្តទុកដាក់.............................................. ៨៧

# សេចក្តីថ្លែងអំណរគុណ

ឯកសារស្តីអំពីការចាត់ចែងថវិការនេះ គឺបានមកពីឯកសារនានាដែលបានរៀបរៀងដោយគម្រោងការអប់រំកិច្ចការហិរញ្ញវត្ថុសម្រាប់ជួយជនក្រីក្រ ដែលបានឧបត្ថម្ភដោយ **Microfinance Opportunities, Citigroup and Freedom for Hunger** ។ ឯកសារទាំងនោះ ត្រូវបានកែសម្រួលសម្រាប់ការប្រើប្រាស់នៅកម្ពុជាដោយ អង្គការពលកម្មអន្តរជាតិ គំរោងលើកកំពស់ការអភិវឌ្ឍន៏មុខរបររបស់ស្ត្រី និងសមភាពយេនឌ័រ **(ILO WEDGE)** និងគំរោងមានរយៈពេលកំណត់ ដើម្បីលុបបំបាត់ទំរង់ធ្ងន់ធ្ងរនៃពលកម្មកុមារ **(ILO IPEC TBP - SP)** ។

# សេចក្ដីផ្ដើម

អសន្តិសុខផ្នែកសេដ្ឋកិច្ច និងការជាប់បំណុលគឺជាបញ្ហាចម្បងពីរ ដែលបណ្ដាលឱ្យមានពលកម្មកុមារនៅកម្ពុជា ។ គ្រួសារទាំងឡាយដែលពុះពារពីមួយថ្ងៃទៅមួយថ្ងៃ ដើម្បីដោះស្រាយបញ្ហាជីវភាព ជារឿយៗត្រូវ បានបង្ខំចិត្តឱ្យកូនៗរបស់ពួកគេឈប់រៀន ហើយមកជួយការងារ ដើម្បីបំពេញបន្ថែមលើប្រាក់ចំណូលគ្រួសារ ។ កុមារទាំងឡាយដែលចំណាយវ័យកុមារភាពរបស់ខ្លួន ទៅធ្វើការនៅតំបន់ចំការកៅស៊ូ ឡតដ្ឋ ឬធ្វើការនៅរោងចក្រផលិតអំបិល ធ្វើជាអ្នកនេសាទ ឬជាអ្នកលីសែង តែងតែបាត់បង់ឱកាស ដើម្បីកសាងអនាគតភ្លឺស្វាងរបស់ខ្លួន ។

ការបណ្ដុះបណ្ដាលស្ដីអំពីការចាត់ចែងថវិការនេះ ត្រូវបានចងក្រងឡើង ដើម្បីផ្ដល់ជំនាញមូលដ្ឋាននានា ដែលទាក់ទិននឹងការរកប្រាក់ចំណូល ការចំណាយ ការគ្រោងថវិកា ការសន្សំនិងការខ្ចីបុល ដល់គ្រួសារពលកម្មកុមារ ។ ការបណ្ដុះបណ្ដាលនេះ គឺផ្ដោតជាសំខាន់ទៅលើស្ដ្រីនៅកម្ពុជា ដែលធម្មតាជាអ្នកចាត់ចែងថវិកាគ្រួសារ ។ គេសង្ឃឹមថា ស្ដ្រីទាំងនោះនឹងក្លាយជាអ្នកធ្វើសេចក្ដីសម្រេច ដែលមានការយល់ដឹង និងមានអំណាចជាច្រើនលើកិច្ចការហិរញ្ញវត្ថុ អាចបង្កើតផែនការហិរញ្ញវត្ថុ និងអាចសម្រេចផែនការនោះបាន។ ការណ៍នេះនឹងជួយលើកកម្ពស់ល័ក្ខខ័ណ្ឌជីវិតរបស់ពួកគេ អាចបញ្ជូនកូនៗឱ្យទៅរៀន និងរីករាយជាមួយនឹងជីវិតរស់នៅរបស់ពួកគេ។

ការបណ្ដុះបណ្ដាលស្ដីអំពីការចាត់ចែងថវិកានេះ មានគោលដៅដើម្បីលើកកម្ពស់តរិយាបទវិជ្ជមាន ឆ្ពោះទៅរកការបង្កើនការសន្សំប្រាក់ បង្កើនការប្រុងប្រយ័ត្ននៅពេលចំណាយ ព្រមទាំងការខ្ចីបុលដោយមានមូលហេតុសមស្រប ។ ការបណ្ដុះបណ្ដាលត្រូវបានចងក្រងឡើង ដោយប្រើប្រាស់វិធីសាស្ដ្របណ្ដុះបណ្ដាល ដែលមានការចូលរួម។ នេះមានន័យថាសិក្ខាកាមទាំងឡាយ នឹងចូលរួមក្នុងការពិភាក្សាជាក្រុមតូចៗ ចែករំលែកបទពិសោធន៍វិជ្ជមាន និងអវិជ្ជមានរបស់ពួកគេ ព្រមទាំងស្វែងរកការរៀនសូត្រថ្មីៗ តាមរយៈការសម្ដែងរឿង ករណីសិក្សា។

កំណត់ចំណាំរបស់ខ្លឹមសារប្រធានបទនៅចុងបញ្ចប់នៃឯកសារនេះ នឹងផ្ដល់ចំណេះដឹងមូលដ្ឋានដល់អ្នកបណ្ដុះបណ្ដាលទាំងឡាយពីគោលគំនិត ដែលនឹងត្រូវយកទៅពិភាក្សា នៅក្នុងបណ្ដុះបណ្ដាលនេះ ។

# គោលបំណង និងកាលវិភាគ

## គោលបំណងវគ្គបណ្តុះបណ្តាល

- ជួយក្រុមគោលដៅ ដើម្បីធ្វើសេចក្តីសំរេចចិត្តឱ្យបានកាន់តែប្រសើរអំពីការចំណាយ ការសន្សំ និងការវិនិយោគ ។
- ជួយក្រុមគោលដៅ ឱ្យសម្រេចបាននូវគោលបំណងហិរញ្ញវត្ថុ ដោយមិនចាំបាច់ប្រើពលកម្មកុមារ ។
- លើកកម្ពស់សមត្ថភាពរបស់ស្ត្រី ក្នុងការធ្វើសេចក្តីសម្រេចលើកិច្ចការសេដ្ឋកិច្ចនៅក្នុងគ្រួសារ ។

## ឧទាហរណ៍ ៖ កាលវិភាគសម្រាប់វគ្គបណ្តុះបណ្តាល

| ម៉ោង | មេរៀន | អ្នកសម្របសម្រួល |
|---|---|---|
| ថ្ងៃទី ១ | | |
| ០៨:០០ - ០៨:៤៥ | មេរៀនទី ១: ការណែនាំអំពីកម្មវិធីបណ្តុះបណ្តាល និងសិក្ខាកាម | |
| ០៨:៤៥ - ០៩:៤៥ | មេរៀនទី ២: ការបង្កើតគោលបំណង និងកំណត់ចំនួនថវិកាដែលត្រូវការ ដើម្បីសម្រេចគោលបំណងនោះ | |
| ០៩:៤៥ - ១០:០០ | សម្រាក | |
| ១០:០០ - ១១:០០ | មេរៀនទី ២: (បន្ត) | |
| ១១:០០ - ១២:០០ | មេរៀនទី ៣: ការគ្រប់គ្រងប្រាក់កាសរបស់អ្នក | |
| ១២:០០ - ១៤:០០ | ការសម្រាកពិសារអាហារថ្ងៃត្រង់ | |
| ១៤:០០ - ១៥:០០ | មេរៀនទី ៣: (បន្ត) | |
| ១៥:០០ - ១៥:១៥ | សម្រាក | |
| ១៥:១៥ - ១៧:០០ | មេរៀនទី ៤: ប្រើប្រាស់ថវិកាផ្ទាល់ខ្លួននិងថវិកាកម្ចីសំរាប់ធ្វើអាជីវកម្ម | |

| **ថ្ងៃទី ២** | | |
|---|---|---|
| ០៨:០០ - ០៨:១៥ | ការរំឭកមេរៀន | |
| ០៨:១៥ - ០៩:៤៥ | មេរៀនទី ៥: គ្រោះថ្នាក់នៃការជាប់បំណុលធ្ងន់ធ្ងរ និងការខកខានមិនបានសង | |
| ០៩:៤៥ - ១០:០០ | សម្រាក | |
| ១០:០០ - ១១:០០ | មេរៀនទី ៥: (បន្ត) | |
| ១១:០០ - ១២:០០ | មេរៀនទី ៦: ការប្រៀបធៀបសេវាសន្សំប្រាក់ | |
| ១២:០០ - ១៤:០០ | សម្រាក | |
| ១៤:០០ - ១៥:៣០ | មេរៀនទី ៦: (បន្ត) | |
| ១៥:៣០ - ១៥:៤៥ | សម្រាក | |
| ១៥:៤៥ - ១៧:០០ | មេរៀនទី ៧: ការរៀបចំគំរោងថវិកា | |
| **ថ្ងៃទី ៣** | | |
| ០៨:០០ - ០៨:១៥ | ការរំឭកមេរៀន | |
| ០៨:១០ - ០៩:៤៥ | មេរៀនទី ៧: (បន្ត) | |
| ០៩:៤៥ - ១០:០០ | សម្រាក | |
| ១០:០០ - ១២:០០ | មេរៀនទី ៨: ការអនុវត្តទៅតាមគំរោងថវិការបស់អ្នក | |
| ១២:០០ - ១៤:០០ | សម្រាកពិសារអាហារថ្ងៃត្រង់ | |
| ១៤:០០ - ១៥:៣០ | មេរៀនទី ៩: ការរៀបចំផែនការសន្សំប្រាក់ | |
| ១៥:៣០ - ១៥:៤៥ | សម្រាក | |
| ១៥:៤៥ - ១៧:០០ | - ការរំលឹកមេរៀនទាំងអស់ឡើងវិញ<br>- ការវាយតម្លៃ និងបិទវគ្គបណ្តុះបណ្តាល | |

# ទម្រង់វាយតម្លៃប្រចាំថ្ងៃ

ទម្រង់វាយតម្លៃប្រចាំថ្ងៃនេះ ត្រូវតែកែសម្រួលទៅតាមកាលវិភាគបណ្តុះបណ្តាល

## " ការសិក្សាអំពីការចាត់ចែងថវិកា "
## ទម្រង់វាយតម្លៃប្រចាំថ្ងៃ

កាលបរិច្ឆេទ :...............................

ជាទូទៅ តើអ្នកដាក់ពិន្ទុឱ្យមេរៀននៅថ្ងៃនេះយ៉ាងដូចម្តេច ?

| ☺☺ | ☺ | 😐 | ☹ | ☹☹ |
|---|---|---|---|---|
| | | | | |

មេរៀន " **ការបង្កើតគោលបំណងហិរញ្ញវត្ថុ** "

| សូមគូសសញ្ញា (√) នៅកន្លែងណា ដែលជាការដាក់ពិន្ទុត្រឹមត្រូវ : | ប្រពៃណាស់ | | | | ខ្សោយណាស់ |
|---|---|---|---|---|---|
| | ☺☺ | ☺ | 😐 | ☹ | ☹☹ |
| ខ្លឹមសារមេរៀន | | | | | |
| វិធីសាស្ត្របណ្តុះបណ្តាល | | | | | |
| អ្នកបណ្តុះបណ្តាល | | | | | |

តើអ្នកមានការភាន់ច្រឡំអ្វីខ្លះ នៅក្នុងមេរៀននេះ ? ប្រសិនបើមាន សូមពន្យល់

..........................................................................................................................

..........................................................................................................................

....................................................................................................................... ។

តើអ្នកមានយោបល់យ៉ាងណា ដើម្បីធ្វើឱ្យមេរៀននេះប្រសើរជាងមុន ?

..........................................................................................................................

..........................................................................................................................

....................................................................................................................... ។

មេរៀន "ការគ្រប់គ្រងប្រាក់កាសរបស់អ្នក "

| សូមគូសសញ្ញា (√) នៅកន្លែងណា ដែលជាការដាក់ពិន្ទុត្រឹមត្រូវ : | ប្រពៃណាស់ | | | | ខ្សោយណាស់ |
|---|---|---|---|---|---|
| | ☺☺ | ☺ | 😐 | ☹ | ☹☹ |
| ខ្លឹមសារមេរៀន | | | | | |
| វិធីសាស្រ្តបណ្តុះបណ្តាល | | | | | |
| អ្នកបណ្តុះបណ្តាល | | | | | |

តើអ្នកមានការភាន់ច្រឡំអ្វីខ្លះ នៅក្នុងមេរៀននេះ ? ប្រសិនបើមាន សូមពន្យល់

.....................................................................................................................

..................................................................................................................... ។

តើអ្នកមានយោបល់យ៉ាងណាដើម្បីធ្វើឱ្យមេរៀននេះប្រសើរជាងមុន ?

.....................................................................................................................

..................................................................................................................... ។

មេរៀន " ការប្រើប្រាស់ថវិការរបស់អ្នក ឬប្រាក់កម្ចី សំរាប់ធ្វើអាជីវកម្ម "

| សូមគូសសញ្ញា (√) នៅកន្លែងណា ដែលជាការដាក់ពិន្ទុត្រឹមត្រូវ : | ប្រពៃណាស់ | | | | ខ្សោយណាស់ |
|---|---|---|---|---|---|
| | ☺☺ | ☺ | 😐 | ☹ | ☹☹ |
| ខ្លឹមសារមេរៀន | | | | | |
| វិធីសាស្រ្តបណ្តុះបណ្តាល | | | | | |
| អ្នកបណ្តុះបណ្តាលរបស់គ្រូ | | | | | |

តើអ្នកមានការភាន់ច្រឡំអ្វីខ្លះ នៅក្នុងមេរៀននេះ ? ប្រសិនបើមាន សូមពន្យល់

.....................................................................................................................

.....................................................................................................................

..................................................................................................................... ។

តើអ្នកមានយោបល់យ៉ាងណាដើម្បីធ្វើឱ្យមេរៀននេះប្រសើរជាងមុន ?

.....................................................................................................................

..................................................................................................................... ។

# មេរៀនទី ១ : ការណែនាំអំពីកម្មវិធីបណ្តុះបណ្តាល និងសិក្ខាកាម



កំណត់ចំណាំរបស់គ្រូបណ្តុះបណ្តាល

## គោលបំណង

នៅចុងបញ្ចប់មេរៀន សិក្ខាកាមនឹង :

- អាចពន្យល់បានពីគោលបំណងនានា និងការរៀបចំវគ្គបណ្តុះបណ្តាល
- យល់បានពីអ្វីដែលជាការរំពឹងទុកពីពួកគេ

## ច្បង់វគ្គសិក្សា (៩០ នាទី)

### ជំហានទី ១ - ២០ នាទី

ស្វាគមន៍ដល់សិក្ខាកាមទាំងអស់ ព្រមទាំងដល់វាគ្មិនទាំងឡាយ ។ អនុញ្ញាតឱ្យសិក្ខាកាមទាំងអស់ធ្វើការណែនាំខ្លួនតាមវិធីដូចខាងក្រោមនេះ :

ស្នើឱ្យសិក្ខាកាមធ្វើការសម្ភាសន៍ខ្លីមួយ ជាមួយសិក្ខាកាមម្នាក់ទៀត ដែលអង្គុយនៅបន្ទាប់គ្នា ដោយសាកសួរពីឈ្មោះរបស់គេ អាស័យដ្ឋានស្នាក់នៅ បទពិសោធន៍ក្នុងការបណ្តុះបណ្តាលស្តីពីក្រុមជួយខ្លួនឯង ឬពីប្រធានបទផ្សេងៗទៀត ក៏ដូចជាការរំពឹងទុកនានារបស់គេពីសិក្ខាសាលានេះ ។

ឱ្យសិក្ខាកាមឡើងបង្ហាញលទ្ធផលសម្ភាសន៍ដល់ក្រុមធំ (ចូរផ្តល់ពេលវេលាមួយនាទីសម្រាប់ការបង្ហាញ របស់សិក្ខាកាមម្នាក់) ។

### ជំហានទី ២ - ១០ នាទី

ចូរបង្កើតវិន័យសិក្សាដូចតទៅនេះ :

ចូរលើកឡើងពីវិន័យសិក្សាខ្លះៗ (ដូចជាពេលវេលា ការគោរពគ្នាទៅវិញទៅមក ការយកចិត្តទុកដាក់ស្តាប់នៅពេលសិក្ខាកាមផ្សេងទៀតកំពុងនិយាយ) ។ ចូរស្នើឱ្យក្រុមបន្ថែមចំណុចដែលគួរធ្វើ និងចំណុចផ្សេងៗទៀតដែលមិនគួរធ្វើទៅក្នុងវិន័យសិក្សានោះ ។ ស្នើឱ្យសិក្ខាកាមពីរនាក់សរសេរចំណុចទាំងនេះនៅលើក្រដាសផ្ទាំងធំ រួចបិទវានៅលើជញ្ជាំងសម្រាប់ប្រើប្រាស់នៅអំឡុងពេលនៃវគ្គបណ្តុះបណ្តាលនេះ ។ សិក្ខាកាមអាចផ្តល់ជាមតិសម្រាប់ការដាក់ពិន័យផ្សេងៗ (ដូចជា ការផាកពិន័យ ការរាំ ឬការច្រៀង) ។ សូមពន្យល់បញ្ជាក់ ពីការរៀបចំផ្សេងៗនៅអំឡុងពេលនៃវគ្គសិក្សានេះ ។

### ជំហានទី ៣ - ១០ នាទី

ចូរពន្យល់ពីកម្មវិធី និងគោលបំណងនានារបស់វគ្គសិក្សា ។ ចូរសង្កត់បញ្ជាក់ពីសារសំខាន់នៃការចូលរួមជាសកម្ម និងការរៀនសូត្រពីគ្នាទៅវិញទៅមក ។

# មេរៀនទី ២ : ការបង្កើតគោលបំណងហិរញ្ញវត្ថុ និងកំណត់ចំនួនថវិកា ដែលត្រូវការដើម្បីសំរេចគោលដៅនោះ




កំណត់ចំណាំរបស់គ្រូបណ្តុះបណ្តាល

### គោលបំណង

នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមនឹងបាន :

- ពិនិត្យមើលមូលហេតុផ្សេងៗ ដែលដាក់សម្ពាធទៅលើហិរញ្ញវត្ថុគ្រួសារ
- បង្កើតគោលបំណងហិរញ្ញវត្ថុ ព្រមទាំងពន្យល់ពីវិធីផ្សេងៗ ដើម្បីឈានទៅសំរេចគោលបំណងទាំង នោះ
- យល់ដឹងពីអត្ថន័យនៃផែនការហិរញ្ញវត្ថុ និងវិធីណាខ្លះ ដែលអាចជួយឱ្យសម្រេចបាននូវសុខុមាលភាពហិរញ្ញវត្ថុ

### ប្លង់វគ្គសិក្សា (១១៥ នាទី)

### ជំហានទី ១ - ៣០ នាទី

បង្កើតគោលបំណងហិរញ្ញវត្ថុ រួចចាត់វាជាអាទិភាព ។ ស្នើឱ្យសិក្ខាកាមរកដៃគូម្នាក់ ហើយពិភាក្សា លើសំណួរ " **តើអ្នកមានគោលបំណងអ្វីខ្លះ ដើម្បីអនាគតដ៏ស្រស់បំព្រងមួយ** ?" បន្ទាប់ពីរយៈពេល ៥- ១០ នាទីក្រោយមក ចូរស្នើឱ្យដៃគូនីមួយៗចែករំលែកគោលបំណងរបស់គេទៅក្រុមធំ ។ ពួកគេទំនងជាមានគោលបំណងច្រើនដូចជា ការបញ្ជូនកូនៗទៅសាលារៀន ការជួសជុលគេហដ្ឋាន មានប្រាក់ចំណូលច្រើនជាងមុន មានបំណុលតិចជាងមុន មានអាជីវកម្មធំជាងមុន និងគ្មានជម្ងឺ នៅក្នុងគ្រួសារជាដើម ។

សិក្ខាកាមអាចមានគោលបំណងហិរញ្ញវត្ថុច្រើនយ៉ាង ដែលត្រូវការធនធានហិរញ្ញវត្ថុនានា ។ សាកសួរ **តើអ្នកអាចសម្រេចគោលបំណងទាំងអស់នោះ នៅក្នុងពេលតែមួយដែរឬទេ** ? ពួកគេនឹងឆ្លើយថា " មិនអាចទេ " ។ ដូច្នេះ ចូរស្នើឱ្យពួកគេចាត់អាទិភាពទៅលើគោលបំណងណាមួយ ដែលគេចង់សម្រេចបានមុនគេ ហើយគោលបំណងណាមួយ ដែលគេចង់សម្រេចនៅពេលបន្ទាប់ ។ តើស្ត្រីមានគោលបំណងហិរញ្ញវត្ថុច្រើនជាង បុរសដែរឬ ? ប្រសិនបើមែន តើគេត្រូវធ្វើដូចម្តេច ដើម្បីសម្រេចគោលបំណងនៅក្នុងគ្រួសាររបស់ពួកគេ ?

### ជំហានទី ២ - ៤០ នាទី

ស្នើឱ្យសិក្ខាកាមទាំងអស់បិទភ្នែករបស់គេចំនួន ៣ នាទី ដើម្បីធ្វើការស្រមៃគិត (សុបិន) អំពីជីវិតគេនៅពេលអនាគតពិតប្រាកដមួយ ។ **ប្រសិនបើអ្នកអាចសម្រេចបាននូវគោលបំណងហិរញ្ញវត្ថុទាំងអស់ តើ**

**អនាគតអ្នកមានសភាពយ៉ាងណា** ? បន្ទាប់មក ចូរស្នើឱ្យពួកគេបើកភ្នែកជាធម្មតាវិញ ហើយគូររូបភាពមួយបង្ហាញពីការស្រមៃគិតនៅក្នុងរយៈពេល ២ នាទី ។ ពួកគេអាចប្រើប្រាស់និមិត្តសញ្ញា ដើម្បីធ្វើជាតំណាងឱ្យគំនិតទាំងឡាយរបស់គេបាន ។

នៅពេលពួកគេបានបញ្ចប់ការគូររូបភាពហើយនោះ ចូរស្នើឱ្យពួកគេពិពណ៌នារូបគំនូររបស់ពួកគេ ។ ចូរកត់ត្រាពាក្យពេជន៍សំខាន់ៗ (ឧ. គ្មានបំណុល គ្មានជម្ងឺដង្កាត់ កូនៗបានទៅសាលារៀន ។ល។) នៅលើក្តារខៀន ។ បិទផ្ទាំងរូបភាពទាំងឡាយរបស់ពួកគេនៅលើជញ្ជាំង ។

បន្ទាប់មក ចូរសាកសួរពួកគេជាបន្តទៀត **តើអ្នកអាចធ្វើអ្វីខ្លះ ដើម្បីធ្វើឱ្យប្រាកដប្រជាថា អ្នកមានធនធានហិរញ្ញវត្ថុនានា ដើម្បីធ្វើឱ្យសុបិនរបស់អ្នកក្លាយជាការពិតបាន** ?

ចូរសង្ខេបចម្លើយទាំងឡាយរបស់សិក្ខាកាម ។ ចូរធ្វើឱ្យប្រាកដថា ចំណុចទាំងឡាយដូចខាងក្រោមនេះត្រូវមាននៅក្នុងសេចក្តីសង្ខេបរបស់អ្នក ។

ដើម្បីសម្រេចបាននូវគោលបំណងនានារបស់អ្នកសម្រាប់ពេលអនាគត អ្នកចាំបាច់ត្រូវ :

- គណនាចំនួនប្រាក់កាស ដែលអ្នកអាចរកបាន និងចំនួនប្រាក់ ដែលអ្នកត្រូវចាយចាំបាច់ក្នុងគ្រួសារ
- ធ្វើការកំណត់ចំនួនប្រាក់ សម្រាប់គោលបំណងទាំងឡាយរបស់អ្នក
- ធ្វើការសម្រេចចិត្តទៅលើចំនួនប្រាក់ប៉ុន្មានដែលត្រូវសន្សំទុក ប្រាក់ប៉ុន្មានដែលត្រូវយកទៅសង បំណុល និងប្រាក់ប៉ុន្មានទៀត ដែលត្រូវយកទៅវិនិយោគក្នុងកិច្ចការអាជីវកម្មរបស់អ្នក
- សម្រេចលើការកំណត់ពេលវេលាសម្រាប់អនុវត្តកិច្ចការទាំងនេះ

នេះហើយគឺជា ***ការធ្វើផែនការហិរញ្ញវត្ថុ*** ។

ស្នើឱ្យសិក្ខាកាមទាំងអស់កត់ត្រាគោលបំណងរបស់គេទៅក្នុងសៀវភៅ ពីព្រោះថាគោលបំណងទាំងនោះនឹងត្រូវយកមកពិនិត្យមើលម្តងទៀត នៅក្នុងមេរៀនជាបន្តបន្ទាប់ ។

### ***ជំហានទី ៣ - ២០ នាទី***

ស្នើឱ្យសិក្ខាកាមធ្វើការពិភាក្សាជាមួយដៃគូ អំពីសារសំខាន់នៃការធ្វើផែនការហិរញ្ញវត្ថុ ។ ចូរសង្ខេបគំនិតរបស់គេ ហើយធ្វើឱ្យប្រាកដប្រជាថា ចំណុចទាំងឡាយដូចខាងក្រោមនេះ នឹងមាននៅក្នុងសេចក្តីសង្ខេបនោះ ។

ការធ្វើផែនការហិរញ្ញវត្ថុ :

- ជួយអ្នកក្នុងការសម្រេចទៅលើអាទិភាពនៃការចំណាយរបស់អ្នក សម្រាប់ពេលអនាគត
- ផ្តល់ឱ្យអ្នកមានទម្លាប់ល្អក្នុងការចំណាយ និងការសន្សំប្រាក់
- ជួយអ្នកឱ្យជៀសវាងបានពីកង្វះខាតប្រាក់កាស ដែលអាចកើតមានឡើង
- ជួយឱ្យអ្នកគេចផុតពីសម្ពាធហិរញ្ញវត្ថុ

## ជំហានទី ៤ - ២០ នាទី

ចូរពន្យល់ថា ជំនឿនានាអំពីប្រាក់កាស គឺមានមូលដ្ឋានដោយផ្អែកលើអ្វី ដែលយើងបានឃើញបានស្តាប់ឮ និងបទពិសោធន៍ពីអតីតកាល ។ យើងមានឥរិយាបថរបស់យើងដោយសារជំនឿទាំងនេះឯង ។ ប៉ុន្តែជំនឿអំពីប្រាក់កាសជាទូទៅ គឺមិនមែនសុទ្ធតែត្រឹមត្រូវទាំងអស់ទេ ហើយវាទាញយើងឱ្យថយក្រោយបាន។ ឧទាហរណ៍ យើងភាគច្រើនតែងជឿថា យើងមិនអាចគ្រប់គ្រងប្រាក់កាសបានប្រសើរឡើយ ដោយយើងមិនពូកែខាងគណិតវិទ្យា ។

សាកសួរសិក្ខាកាម ថាតើគេយល់ស្របជាមួយនឹងប្រយោគដូចខាងក្រោមនេះ ដែរឬទេ ហើយពិភាក្សាប្រយោគនេះម្តងមួយៗ ។ តើមានគំនិតអ្វីផ្សេងៗទៀតដែលទាក់ទងអំពីប្រាក់កាស ហើយមានលក្ខណៈទូទៅនៅក្នុងភូមិរបស់គេ ដែរឬទេ ?

### ពិត ឬ មិនពិត

- ការគ្រប់គ្រងប្រាក់កាស គឺមានភាពស្មុគ្រស្មាញណាស់
- អ្នកត្រូវតែពូកែខាងគណិតវិទ្យា ដើម្បីឱ្យអ្នកអាចគ្រប់គ្រងប្រាក់កាសបានល្អ
- មិត្តភ័ក្តិទាំងឡាយរបស់ខ្ញុំនឹងចាកចោលខ្ញុំ នៅពេលខ្ញុំរកប្រាក់បានច្រើនជាងពួកគេ
- វាត្រូវប្រើប្រាក់កាសជាច្រើនដើម្បីចាប់ផ្តើមអាជីវកម្ម
- បំណុលរបស់ខ្ញុំធ្ងន់ធ្ងរណាស់ ដែលគ្មានអ្វីយកមកដោះស្រាយបានទេ
- ខ្ញុំជឿជាក់លើស្វាមីរបស់ខ្ញុំ ដើម្បីផ្តល់ជម្រើសល្អៗសម្រាប់ខ្ញុំ
- ជនក្រីក្រមិនអាចសន្សំប្រាក់បានទេ

## ជំហានទី ៥ - ៥ នាទី

ស្នើឱ្យសិក្ខាកាមទាំងអស់រលឹកឡើងវិញនូវអ្វីដែលពួកគេបានរៀន និងអ្វីដែលគេបានគ្រោងនឹងអនុវត្តជាក់ស្តែង ។ ចំណុចសំខាន់ៗនៅក្នុងមេរៀននេះមាន :

- ការបង្កើតគោលបំណងហិរញ្ញវត្ថុ
- ការចាត់អាទិភាពគោលបំណងហិរញ្ញវត្ថុ
- វិធីនានាដើម្បីសម្រេចគោលបំណងរបស់ពួកគេ
- សារសំខាន់នៃការធ្វើផែនការហិរញ្ញវត្ថុ

## ជំនួយការបណ្តុះបណ្តាលទី ១ : គោលបំណងហិរញ្ញវត្ថុ



# មេរៀនទី ៣ ៖ ការគ្រប់គ្រងប្រាក់កាសរបស់អ្នក



កំណត់ចំណាំរបស់គ្រូបណ្តុះបណ្តាល

## គោលបំណង

នៅចុងបញ្ចប់មេរៀននេះ សិក្ខាកាមទាំងអស់នឹងបាន ៖

- កត់ត្រា ព្រមទាំងធ្វើចំណាត់ជាក្រុម នូវចំណាយផ្សេងៗនៅក្នុងគ្រួសារ
- កំណត់ និងធ្វើចំណាត់ជាក្រុម នូវប្រភពចំណូលផ្សេងៗនៅក្នុងគ្រួសារ
- ពន្យល់ពីវិធីនានា ដើម្បីគ្រប់គ្រងចំណាយ និងចំណូលមិនប្រក្រតី

## ប្លង់វគ្គសិក្សា (១៨០នាទី)

### *ជំហ៊ានទី ១ - ៣០នាទី*

សាកសួរសិក្ខាកាមទាំងអស់ ៖ **តើអ្នកត្រូវការប្រាក់កាសយកទៅធ្វើអ្វីខ្លះ** ? ចែកក្រដាសកាតពណ៌ ឱ្យពួកគេដើម្បីសរសេរគំនិតរបស់គេ (ប្រសិនបើគេអាចសរសេរបាន) ។ ប្រសិនបើពួកគេមិនអាចសរសេរបានទេ ចូរស្នើឱ្យពួកគេគូរនិមិត្តសញ្ញានានា ដើម្បីធ្វើជាតំណាងឱ្យគំនិតរបស់គេ ។ នៅពេលពួកគេ បានបញ្ចប់កិច្ចការ នេះហើយ ស្នើឱ្យពួកគេចែករំលែកគំនិតរបស់គេ ហើយបិទកាតដែលបានកត់ត្រាគំនិតទាំងឡាយនោះនៅលើក្រដាសផ្ទាំងធំមួយ ។

ប្រសិនបើពួកគេមិនបានលើកឡើងពីចំណាយសំរាប់ភាពបន្ទាន់នានាទេនោះ ចូរស្នើឱ្យពួកគេកត់ត្រា បន្ថែមពីការចំណាយនៅពេលមានភាពបន្ទាន់នានាទាំងនោះ ។ **តើគ្រួសាររបស់អ្នកអាចប្រឈមមុខនឹងភាពបន្ទាន់អ្វីខ្លះ** ?

ចូរពន្យល់ថាវាមានសារៈសំខាន់ក្នុងការបែងចែកឱ្យដាច់រវាងប្រាក់កាស ដែលអ្នកត្រូវការសម្រាប់អាជីវកម្មរបស់អ្នក (ការសងប្រាក់កម្ចី ការទិញគ្រឿងឧបករណ៍ សម្ភារៈផ្សេងៗ) និងប្រាក់កាសសម្រាប់ចំណាយក្នុងគ្រួសាររបស់អ្នក (ថ្លៃសាលា ចំណាយបន្ទាន់ និងស្បៀងអាហារជាដើម ។ល។ )។ បន្ទាប់មកចូរស្នើឱ្យសិក្ខាកាមម្នាក់ឬពីរនាក់ ឡើងមករៀបក្រដាសកាតជាជំពូកចំណាយក្នុងអាជីវកម្ម និងចំណាយក្នុងគ្រួសារ ។ ឧទាហរណ៍ ៖

<u>គ្រួសាររបស់ខ្ញុំ :</u>
- ចំណាយចាំបាច់នានា
- ព្រឹត្តិការណ៍ដែលបានគ្រោងទុក
- ថ្លៃសាលា
- ចំណាយបន្ទាន់ផ្សេងៗ

<u>អាជីវកម្មរបស់ខ្ញុំ :</u>
- ការសងបំណុល
- គ្រឿងបរិក្ខាអាជីវកម្ម
- ថ្លៃជួលអាគារ ឬឧបករណ៍

### ជំហានទី ២ - ២០ នាទី

ចូរសង្កេតមើលចំណាយទាំងនេះម្តងទៀត ។ **តើមានប្រភេទចំណាយអ្វីខ្លះ ដែលអ្នកត្រូវចាយយូរៗម្តង ដែលខុសពីការចំណាយរៀងរាល់ថ្ងៃ ឬរៀងរាល់សប្តាហ៍** ? ចូរដាក់សញ្ញាបញ្ជាក់ ឬសញ្ញាផ្កាយនៅត្រង់មុខចំណាយណា ដែលសិក្ខាកាមកំណត់ថា ជាការចំណាយយូរៗម្តង ឬចំណាយមិនប្រក្រតី ។

ស្នើឱ្យសិក្ខាកាមធ្វើការជាដៃគូ ហើយពិភាក្សាលើសំណួរ : **តើអ្នកធ្វើផែនការយ៉ាងណា សម្រាប់ការចំណាយទាំងឡាយដែលកើតឡើងយូរៗម្តង រួចទាំងការចំណាយសម្រាប់ពេលមានភាពបន្ទាន់ផងដែរ ?**

ចូរសង្ខេបចម្លើយនានារបស់ពួកគេ ហើយពន្យល់ថា :

ការធ្វើផែនការសម្រាប់ចំណាយនានា ដែលកើតឡើងមិនប្រក្រតី មានសារៈសំខាន់ដើម្បីឱ្យការគ្រប់គ្រងប្រាក់កាសបានល្អ ។ អ្នកបានលើកឡើងនូវវិធីជាច្រើនដើម្បីដោះស្រាយបញ្ហានេះ ដោយរាប់បញ្ចូលទាំងការសន្សំប្រាក់ និងការផ្អាកការចំណាយនានា រហូតទាល់តែមានប្រាក់កាសគ្រប់គ្រាន់ ។

### ជំហានទី ៣ - ៣០ នាទី

សួរសិក្ខាកាម : **តើអ្នកប្រឈមមុខនឹងការលំបាកអ្វីខ្លះ នៅពេលអ្នកព្យាយាមសន្សំប្រាក់** ? កត់ត្រាការលំបាកទាំងនោះ ដែលសិក្ខាកាមបានជួបប្រទះ ។

បែងចែកសិក្ខាកាមជាក្រុមតូចៗ ដែលមានសមាជិកបីនាក់ក្នុងមួយក្រុម រួចស្នើឱ្យក្រុមនីមួយៗជ្រើសរើសយកការលំបាក ឬឧបសគ្គមួយ ហើយស្វែងរកដំណោះស្រាយរបស់វា ។ ផ្តល់ពេលវេលាដល់ក្រុមនីមួយៗចំនួន ២ នាទីសម្រាប់ការឡើងបង្ហាញ ។

សង្ខេបគំនិតទាំងឡាយនោះ ហើយដាក់បញ្ចូលបន្ថែមចំណុចដូចខាងក្រោមនេះ :

- ធ្វើការសម្រេចលើចំនួនទឹកប្រាក់ប៉ុន្មាន ដែលអ្នកអាចរក្សាទុកក្នុង១ថ្ងៃឬ១ខែ សំរាប់អនុវត្តទៅតាមផែនការនោះ ។
- ជាការប្រសើររក្សាទុកប្រាក់កាសនៅកន្លែងមានសុវត្ថិភាពមួយ ។ បើអ្នករក្សាវាទុកនៅទីកន្លែងដទៃ ក្រៅពីក្នុងផ្ទះ ដូច្នេះអ្នកមិនអាចដកយកវាមកប្រើប្រាស់ ដោយងាយស្រួលបានឡើយ ។
- កំណត់កាលវិភាគជាក់លាក់មួយ ដើម្បីសងបំណុលដែលមានការប្រាក់ខ្ពស់មុនគេ ។

### ជំហានទី ៤ - ២៥ នាទី

ពិភាក្សាសំណួរដូចខាងក្រោមនេះ :

- តើថវិកាចំណូលរបស់អ្នកបានមកពីប្រភពណាខ្លះ ?
- តើនរណារកចំណូលនេះបានច្រើនជាងគេ - ខ្លួនអ្នក ឬប្តីរបស់អ្នក ? ហេតុអ្វី ?
- តើប្រភពចំណូលណាមួយដែលមិនញឹកញាប់ ឬមិនប្រក្រតី ? ហេតុអ្វី ?
- នៅពេលអ្នកទទួលបានប្រាក់ចំណូលជាចំនួនធំម្តងម្កាល តើអ្នកធ្វើផែនការយ៉ាងណា ដើម្បីប្រើប្រាស់វាយកទៅទូទាត់ចំណាយនានាសម្រាប់ពេលពេញមួយឆ្នាំនោះ ?

សង្ខេបចម្លើយនានារបស់សិក្ខាកាមដោយពន្យល់ទៅដល់ក្រុមថា :

វាជាការប្រពៃណាស់នៅពេលទទួលបានចំណូលច្រើននៅពេលណាមួយ ។ វាជាការសំខាន់ក្នុងការពិចារណារកវិធីនានាសម្រាប់ប្រើប្រាស់ប្រាក់កាសនេះដោយប្រុងប្រយ័ត្ន ក្នុងការសងបំណុល និងធ្វើឱ្យប្រាកដប្រជាថា អ្នកអាចដោះស្រាយភាពចាំបាច់ទាំងឡាយបាន ហើយសន្សំទុកមួយចំនួន ដើម្បីទូទាត់ចំណាយនានា ដែលនឹងអាចកើតឡើងនៅក្នុងពេលអនាគត ។

### ជំហានទី ៥ - ១៥ នាទី

សួរសិក្ខាកាម : **តើអ្នកគ្រប់គ្រងថវិកាចំណូល និងថវិកាចំណាយយ៉ាងដូចម្តេច** ? លើកទឹកចិត្តសិក្ខាកាមឱ្យចែករំលែកបទពិសោធន៍ទាំងឡាយ ។ តើបុរស ឬស្ត្រីដែលជាអ្នកគ្រប់គ្រងថវិកាចំណូល និងចំណាយបានប្រសើរជាង ? ហេតុអ្វី ?

ពិភាក្សាលើគុណសម្បត្តិ និងបញ្ហានានានៃការកត់ត្រាលំហូរសាច់ប្រាក់ ហើយកំណត់រកវិធីទាំងឡាយដើម្បីទប់ទល់នឹងឧបសគ្គ ដែលសិក្ខាកាមបានជួបប្រទះ ។

**ខ្លឹមសារគន្លឹះសម្រាប់គ្រូបណ្តុះបណ្តាល :**

គុណសម្បត្តិ ឬផលប្រយោជន៍ នៃការកត់ត្រាបញ្ជី :

- អ្នកដឹងពីចំនួនប្រាក់ប៉ុន្មានដែលហូរចូលមក និងប្រាក់ប៉ុន្មានដែលហូរចេញទៅ
- អ្នកអាចពិនិត្យមើលការចំណាយនានារបស់អ្នកជាទៀងទាត់បាន
- អ្នកអាចគ្រប់គ្រងសាច់ប្រាក់របស់អ្នកបានប្រសើរ (ធ្វើផែនការសម្រាប់ពេលខាងមុខ និងគ្រោងថវិកា)
- អ្នកអាចត្រួតពិនិត្យមើល ថាតើមានបាត់បង់សាច់ប្រាក់ ឬចោរលួច

ទាំងអស់នេះ **អ្នកអាចធ្វើបាន** ។ ចំណុចសំខាន់គឺថា មានវិធីសាមញ្ញជាច្រើនដើម្បីកត់ត្រាប្រតិបត្តិការសាច់ប្រាក់របស់អ្នក ដោយមិនចាំបាច់ទាល់តែជាគណនេយ្យករទេ !

### *ជំហានទី ៦ - ១០ នាទី*

សួរសិក្ខាកាម :

- តើអ្នកបានរៀនសូត្រអ្វីខ្លះពីមេរៀននេះ ?
- តើអ្នកចាប់អារម្មណ៍លើចំណុចណាខ្លះ ដែលមានផលប្រយោជន៍សម្រាប់ការគ្រប់គ្រងកិច្ចការហិរញ្ញវត្ថុរបស់អ្នក ?
- តើអ្នកនឹងយកចំណុចអ្វីខ្លះ ទៅអនុវត្តជាក់ស្តែង ?

## ជំនួយការបណ្តុះបណ្តាលទី ២: កាបូបប្រាក់ " ឯកជនឬគ្រួសារ " និងកាបូបប្រាក់ " អាជីវកម្ម "



## ជំនួយការបណ្តុះបណ្តាលទី ៣៖ ប្រភពថវិកាចំណូល



# មេរៀនទី ៤ : ការប្រើប្រាស់ថវិកាផ្ទាល់ខ្លួន និង ថវិកាកម្ចី សំរាប់ធ្វើអាជីវកម្ម



កំណត់ចំណាំរបស់គ្រូបណ្តុះបណ្តាល

## គោលបំណង

នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមទាំងអស់នឹងបាន :

- កំណត់រកមូលហេតុជាចម្បងនានានៃការខ្ចីប្រាក់
- កំណត់រកវិធីនានាដើម្បីពង្រីកអាជីវកម្មដោយប្រសិទ្ធភាព
- កំណត់រកគុណសម្បត្តិ និងគុណវិបត្តិនៃការប្រើប្រាស់ថវិកាផ្ទាល់ខ្លួន និងថវិកាកម្ចីសំរាប់ធ្វើអាជីវកម្ម
- បែងចែកពីគ្នារវាងប្រាក់កម្ចីល្អ និងប្រាក់កម្ចីមិនល្អ

## វគ្គសិក្សា (១២០ នាទី)

### ដំណាក់ទី ១ - ២៥ នាទី

សួរបំផុសគំនិតទៅលើ **តើមានមូលហេតុអ្វីខ្លះ ដែលជំរុញឱ្យមនុស្សខ្ចីប្រាក់** ? នៅពេលបញ្ចប់ការបំផុសគំនិតនេះ ស្នើឱ្យសិក្ខាកាមទាំងអស់សង្កេតមើលចម្លើយទាំងឡាយរបស់ពួកគេ ហើយបន្ទាប់មកពិភាក្សា : **តើគំនិត និងចម្លើយដែលស្រដៀងគ្នាទាំងនោះ អាចត្រូវរៀបចំទៅតាមប្រភេទអ្វីខ្លះ** ? ចូរស្នើឱ្យសិក្ខាកាមជួយរៀបចំគំនិតរបស់ពួកគេ ទៅតាមប្រភេទខុសៗគ្នា ដូចដែលបានផ្តល់មតិពីសិក្ខាកាម ។

**ខ្លឹមសារគន្លឹះសម្រាប់គ្រូបណ្តុះបណ្តាល :**

មានមូលហេតុបីយ៉ាងដែលបណ្តាលឱ្យមានអ្នកខ្ចីប្រាក់ :

១. ដើម្បីធ្វើវិនិយោគ (ក្នុងអាជីវកម្ម : ការទិញវត្ថុធាតុដើម គ្រឿងឧបករណ៍ ដីធ្លី ។ល។)

២. ដើម្បីឆ្លើយតបនឹងព្រឹត្តិការណ៍ដែលមិនបានគ្រោងទុកមុន ឬភាពបន្ទាន់ (ការអញ្ជើញទៅចូលរួមពិធីមង្គលការ ឬបុណ្យប្រពៃណី និងសកម្មសង្គមផ្សេងៗ ការឈឺថ្កាត់ ចោរលួច ឬការបាត់បង់)

៣. ដើម្បីដោះស្រាយសេចក្តីត្រូវការចាំបាច់ក្នុងគ្រួសារ ទិញវត្ថុដែលនៅពេលបច្ចុប្បន្ននេះ ពួកគេមិនមានប្រាក់គ្រប់ចំនួន ។

* ប៉ុន្តែ យើងបានពិភាក្សានៅក្នុងមេរៀនខាងដើមថា ប្រសិនបើអ្នកមានការសន្សំគ្រប់គ្រាន់អ្នកមិនចាំបាច់ត្រូវការប្រាក់កម្ចីសម្រាប់ការប្រើប្រាស់ និងសម្រាប់ភាពបន្ទាន់ផ្សេងៗទាំងនោះឡើយ ។

ឥឡូវនេះចូរពិភាក្សា : **តើប្រាក់កម្ចីណាមួយ ដែលអាចបង្កើតចំណូលបាន ? ហេតុអ្វី ?**

**គន្លឹះសារគន្លឹះសម្រាប់គ្រូបណ្តុះបណ្តាល :**

- ប្រាក់កម្ចីសម្រាប់វិនិយោគក្នុងអាជីវកម្ម អាចរកចំណូលសម្រាប់អ្នកខ្ចី ។
- ប្រាក់កម្ចីសម្រាប់ការប្រើប្រាស់លើវិបត្តិផ្សេងៗ និងសម្រាប់សេចក្តីត្រូវការក្នុងគ្រួសារ មិនបាននាំមកនូវចំណូលថ្មីៗទៀតឡើយ ហើយត្រូវតែសងវិញដោយសាច់ប្រាក់ដែលបានមកពីប្រភពផ្សេង ។ ចូរព្យាយាម ជៀសវាងការខ្ចីសម្រាប់បំរើគោលបំណងទាំងនេះ ។

ពិភាក្សា : **តើមានធនធានហិរញ្ញវត្ថុអ្វីខ្លះ ដែលអាជីវករទាំងឡាយអាចប្រើប្រាស់ នៅពេលពួកគេចង់ពង្រីកអាជីវកម្មរបស់ខ្លួន?** កត់ត្រារាល់ធនធានហិរញ្ញវត្ថុទាំងអស់ដែលសិក្ខាកាមបានឆ្លើយ ។ បន្ទាប់មកសួរបន្តទៀត: **តើចម្លើយដែលស្រដៀងគ្នាទាំងនោះ អាចចាត់ជាក្រុមៗ (ទ្រព្យរបស់ម្ចាស់ភាគហ៊ុន និងប្រាក់កម្ចី) បានដែរឬទេ** ? ស្នើឱ្យសិក្ខាកាមម្នាក់ឬពីរនាក់ ឡើងមករៀបចំចម្លើយ ទាំងនោះជា២ក្រុម " ទ្រព្យរបស់អាជីវករ " និង " ទ្រព្យកម្ចី " ។ ឧទាហរណ៍ :

**ទ្រព្យរបស់អាជីវករ :**
- ប្រាក់សន្សំផ្ទាល់ខ្លួន
- ចំណូលពីអាជីវកម្ម
- ចំណូលពីការលក់ទ្រព្យសម្បត្តិផ្សេងៗ

**កម្ចី :**
- កម្ចីពីស្ថាប័នហិរញ្ញវត្ថុនានា
- កម្ចីពីមិត្តភក្តិ ឬបងប្អូន
- កម្ចីពីឈ្មួញផ្តល់ប្រាក់ឱ្យខ្ចី

ចូរពន្យល់ថា ការលក់ទ្រព្យសម្បត្តិអាចជាយុទ្ធសាស្ត្រល្អ ឬជាយុទ្ធសាស្ត្រមិនល្អ ដោយអាស្រ័យទៅលើប្រភេទទ្រព្យសម្បត្តិដែលគេចង់លក់នោះ ។ ឧទាហរណ៍ ការលក់គ្រឿងអលង្ការនឹងមិនប៉ះពាល់ដល់ប្រាក់ចំណូលគ្រួសារក្នុងពេលអនាគតទេ ។ តែការលក់ដីធ្លីឬសត្វចិញ្ចឹម អាចប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ការចិញ្ចឹមជីវិតរបស់គួសារ ។

### ជំហានទី ២ - ៣៥ នាទី

ស្នើឱ្យសិក្ខាកាមពីរនាក់សម្តែងរឿងខ្លីមួយ ។ សាច់រឿងនេះ គឺនិយាយអំពីអាជីវករស្ត្រីពីរនាក់ ដែលជាបងប្អូនបង្កើត ហើយប្រកបកិច្ចការអាជីវកម្មដូចគ្នា (ការផលិតនិងលក់ទឹកសណ្តែកនៅក្នុងភូមិដោយឡែកពីគ្នា) ។ នៅអំឡុងពេលការសម្តែងនេះ បងប្អូនម្នាក់ៗ សាកសួរដោយចង់ដឹងពីវិធីផ្សេងៗ ដែលបងប្អូនគេផ្គត់ផ្គង់ថវិកាដល់អាជីវកម្មរបស់គេ ។

ក្រោយពីការសម្តែងនេះមក ចូរសាកសួរសិក្ខាកាម :

- តើ **នារី** និង **ចន្ធា** បានពង្រីកអាជីវកម្មរបស់នាងយ៉ាងដូចម្តេច ?
- តើស្ត្រីអាជីវករមួយណា ដែលទំនងជាជោគជ័យច្រើនជាង ? ហេតុអ្វី ?
- តើស្ត្រីអាជីវករមួយណា ដែលមានការប្រថុយប្រថានខ្ពស់ជាង ?
- តើអ្នកមានយោបល់អ្វីខ្លះ ដើម្បីផ្តល់ជូនដល់ស្ត្រីអាជីវករទាំងពីរនាក់នេះ ?
- ប្រសិនបើអ្នកជា **នារី** ឬ **ចន្ធា** តើអ្នកនឹងធ្វើអ្វីខ្លះឱ្យខុសពីនាង ?

**ខ្លឹមសារគន្លឹះសម្រាប់គ្រូបណ្តុះបណ្តាល :**

នៅក្នុងរយៈពេលខ្លី អាជីវកម្មរបស់ **ចន្ធា** នឹងរីកចម្រើនលឿនជាងពីព្រោះនាងមានប្រាក់កាសដើម្បីដាក់វិនិយោគថែមទៀតទៅក្នុងអាជីវកម្មនោះ ។ **នារី** វិនិយោគប្រាក់កាសតិចតួចជាជំហ៊ានៗ ហើយអាជីវកម្មរបស់នាងមានការវិវឌ្ឍឡើងដោយសន្សឹមៗ ។ នៅពេលខាងមុខទៀត អាជីវកម្មរបស់នាង **នារី** គឺទំនងជាស្ថិតស្ថេរ និងមានសុវត្ថិភាពច្រើនថែមទៀត ដោយសារនាងមិនត្រូវសងប្រាក់កម្ចីដែលមានប្រាក់ការខ្ពស់ ហើយអាចសន្សំប្រាក់ទុកសម្រាប់ការចំណាយនានាក្នុងពេលបន្ទាន់ និងវិនិយោគក្នុងពេលអនាគត ។

នាង **ចន្ធា** ទទួលយកភាពប្រថុយប្រថានច្រើន ។ នាងមានប្រាក់កម្ចីចំនួនពីរ ក្នុងពេលតែមួយ ដោយមានការសន្សំតិចតួចបំផុតសម្រាប់ការការពារហានិយភ័យនោះ ។

### *ជំហ៊ានទី ៣ - ៩០ នាទី*

ប្រាប់សិក្ខាកាមទាំងអស់គ្នាថា ពួកគេនឹងពិភាក្សាអំពីគុណសម្បត្តិ និងគុណវិបត្តិនានានៃការប្រើប្រាស់ថវិកាកម្ចី និងការប្រើប្រាស់ប្រាក់កាសផ្ទាល់ខ្លួន ក្នុងការធ្វើអាជីវកម្ម ។ បែងចែកសិក្ខាកាមទាំងអស់ ជាពីរក្រុម មួយក្រុមពិភាក្សាអំពីគុណសម្បត្តិនៃការប្រើប្រាស់ប្រាក់កាសផ្ទាល់ខ្លួន និងគុណវិបត្តិ នៃការប្រើប្រាស់ថវិកាកម្ចី ។ មួយក្រុមទៀត ពិភាក្សាអំពីគុណសម្បត្តិនៃការប្រើប្រាស់ថវិកាកម្ចី និងគុណវិបត្តិនៃការប្រើប្រាស់ ប្រាក់កាសផ្ទាល់របស់ខ្លួន ។ ពួកគេនឹងជជែកគ្នា ដោយក្រុមមួយព្យាយាមបញ្ចុះបញ្ចូលក្រុមមួយផ្សេងទៀតថា ការប្រើប្រាស់ថវិកាកម្ចី មានភាពប្រសើរជាងការប្រើប្រាស់ប្រាក់កាសផ្ទាល់ខ្លួន ។ រីឯក្រុមមួយ ផ្សេងទៀតព្យាយាមអះអាងថា ការប្រើប្រាស់ប្រាក់កាសផ្ទាល់របស់ខ្លួន គឺប្រសើរជាងការប្រើប្រាស់ថវិកាកម្ចី ច្រើនណាស់ ។

ផ្តល់ពេលវេលាដល់ក្រុមទាំងពីរ ដើម្បីត្រៀមលក្ខណៈឱ្យបានគ្រប់គ្រាន់មុនពេលធ្វើការ ជជែកពិភាក្សាគ្នា (debate) ។

សង្ខេបលទ្ធផលនៃការជជែកពិភាក្សា ដោយនិយាយថា ទាំងការប្រើប្រាស់ថវិកាផ្ទាល់ខ្លួន និងថវិកាកម្ចី គឺមានគុណសម្បត្តិ និងគុណវិបត្តិរៀងៗខ្លួន (សូមមើលជំនួយបណ្តុះបណ្តាលទី ៥)។

### *ជំហ៊ានទី ៤ - ១៥ នាទី*

ពិភាក្សា : **តើប្រាក់កម្ចីទាំងអស់សុទ្ធតែល្អឬ? ហេតុអ្វីបានជាប្រាក់កម្ចីខ្លះមានផលអាក្រក់សម្រាប់អ្នកខ្ចី? ហេតុអ្វីបានជាកម្ចីខ្លះទៀតមានផលវិជ្ជមានសម្រាប់អ្នកខ្ចី** ? ស្នើសិក្ខាកាមឱ្យពន្យល់ និងលើកឡើង ពីបទពិសោធន៍ជីវិតជាក់ស្តែង ដែលទាក់ទិននឹងប្រាក់កម្ចី ហើយផ្តល់ផលអាក្រក់ និងប្រាក់កម្ចីដែលមានផលប្រយោជន៍ ។

ចូរសង្ខេបថា មានប្រាក់កម្ចីល្អ និងប្រាក់កម្ចីមិនល្អ។ ដូច្នេះ **តើអ្នកចាំបាច់ត្រូវដឹងអ្វីខ្លះមុនពេលខ្ចីប្រាក់**?

**ខ្លឹមសារគន្លឹះសម្រាប់គ្រូបណ្តុះបណ្តាល :**

យើងបានឃើញថា ការខ្ចីប្រាក់នេះគឺអាចជាបទពិសោធន៍វិជ្ជមានមួយ ។ ប្រាក់កម្ចីល្អអាចជួយឱ្យអ្នកចាប់ផ្តើម ឬពង្រីកអាជីវកម្មណាមួយបាន ។ វាអាចជួយអ្នកដោះស្រាយនឹងភាពបន្ទាន់ណាមួយ ដែលកើតមានឡើងនៅក្នុងគ្រួសាររបស់អ្នក ។ វាអាចជួយអ្នកឱ្យលើកកម្ពស់ល័ក្ខខ័ណ្ឌនៃការរស់នៅភ្លាមៗបាន ។ ប៉ុន្តែការខ្ចីប្រាក់គឺតែងតែមានហានិយភ័យ បញ្ហាដោយយើងមិនអាចសងប្រាក់ជំពាក់វិញបាន ។ ប្រសិនបើវាធ្វើឱ្យអ្នកចំណាយប្រាក់ជាច្រើន ឬបង្ខំឱ្យអ្នកធ្លាក់ទៅក្នុងបំណុលកាន់តែជ្រៅទៅៗ (មិនអាចសងវិញបំណុលបាន) វាគឺជាប្រាក់កម្ចីដ៏អាក្រក់មួយ ។

ចំណុចដែលត្រូវយល់ដឹងមុនពេលខ្ចីប្រាក់ :

- ចំនួនប្រាក់កម្ចីសរុប ដែលត្រូវសង ដោយរាប់បញ្ចូលទាំងប្រាក់ដើម ប្រាក់ការ និងថ្លៃផ្សេងៗទៀត
- ប្រភពផ្សេងៗនៃប្រាក់ចំណូល និងប្រាក់សន្សំ ដែលអ្នកអាចយកទៅទូទាត់សំណងទាំងនោះ
- ទ្រព្យសម្បត្តិដែលអ្នកទិញដោយប្រាក់កម្ចី
  នឹងអាចបន្តប្រើប្រាស់បានដើម្បីអាចយកទៅទូទាត់ប្រាក់កម្ចី
  និងបន្តការរកប្រាក់ចំណូលសម្រាប់អ្នក
- តម្លៃផលិតផលដែលបានពីប្រាក់កម្ចី គឺត្រូវមានកម្រិតខ្ពស់ល្មម ដើម្បីយកទៅទូទាត់ប្រាក់កម្ចី និងរកប្រាក់ចំណេញបាន ។

### *ជំហ៊ានទី ៥ - ៥ នាទី*

រំលឹកឡើងវិញលើអ្វីដែលយើងបានពិភាក្សា និងរកឃើញនៅក្នុងមេរៀននេះ ។

- តើអ្នកបានរៀនសូត្រអ្វីខ្លះពីមេរៀននេះ ?
- តើអ្នករកឃើញអ្វីខ្លះដែលជាការចាប់អារម្មណ៍ និងមានផលប្រយោជន៍សម្រាប់ការគ្រប់គ្រង

ហិរញ្ញវត្ថុរបស់អ្នក ?

- តើអ្នកនឹងយកចំណុចអ្វីខ្លះ ទៅអនុវត្តជាក់ស្តែង ?

**សង្ខេបចំណុចសំខាន់ៗ :**

- មូលហេតុចម្បងៗដែលបណ្តាលឱ្យមានអ្នកខ្ចីប្រាក់
- ធនធានហិរញ្ញវត្ថុនានាដើម្បីពង្រីកអាជីវកម្មរបស់អ្នក
- ការប្រើប្រាស់ថវិកាផ្ទាល់ខ្លួន និងការប្រើប្រាស់ថវិកាកម្ចី ដើម្បីធ្វើអាជីវកម្ម
- ប្រាក់កម្ចីល្អ និងប្រាក់កម្ចីអាក្រក់

## ជំនួយការបណ្តុះបណ្តាលទី ៤: ការសម្តែងរឿង " អាជីវកម្មទឹកសណ្តែករបស់នារី និងចន្ថា "

អ្នកឈ្មោះ **នារី** ជាអ្នកប្រកបអាជីវកម្មទឹកសណ្តែក ។ ថ្ងៃនេះ អ្នកនឹងទៅសួរសុខទុក្ខប្អូនស្រីរបស់អ្នក គឺនាង**ចន្ថា** ដែលជាអ្នកប្រកបអាជីវកម្មទឹកសណ្តែកដែរ ។ នៅពេលជួបនាង ចូរសាកសួរប្អូនស្រីរបស់អ្នកឱ្យបានច្រើនអំពីវិធីនានា ដែលនាងបានរៀបចំថវិកា ដើម្បីពង្រីកអាជីវកម្មរបស់នាង ។

ប្អូនស្រីរបស់អ្នកក៏ចង់ដឹងអំពីវិធីនានា ដែលអ្នករៀបចំថវិកាពង្រីកអាជីវកម្មរបស់អ្នកដែរ ។ ខាងក្រោមនេះ គឺជាដំណើរការដែលអ្នកប្រកបកិច្ចការ និងបានពង្រីកអាជីវកម្មរបស់អ្នក ។

អ្នកមានអាជីវកម្មទឹកសណ្តែកមួយ ដែលអ្នកបានចាប់ផ្តើមដំបូងជាមួយសាច់ប្រាក់ចំនួន ២០ ០០០ រៀល បានមកពីប្រាក់សន្សំរបស់អ្នក ១០ ០០០រៀល និង ១០ ០០០ រៀលទៀតស្វាមីរបស់អ្នកផ្តល់ឱ្យ ។ ថ្វីបើអាជីវកម្មនេះមានលក្ខណៈតូចតាចក្តី តែអ្នកមានផែនការពង្រីកវាជាជំហ៊ានៗ ។ អ្នកបានដកប្រាក់ចំនួន៥០០ រៀល ដើម្បីសន្សំទុកក្នុងធនាគារភូមិរបស់អ្នករៀងរាល់សប្តាហ៍ សម្រាប់កិច្ចការអាជីវកម្មរបស់អ្នក ។ តាមវិធីនេះ អ្នកអាចសន្សំប្រាក់បានគ្រប់គ្រាន់សម្រាប់ទិញសំភារៈអ្វីមួយ ដែលអ្នកត្រូវការដើម្បីជួយឱ្យអាជីវកម្មរបស់អ្នករីកចម្រើនឡើងនៅក្នុងរយៈពេលពី ៣ ទៅ ៤ ខែ ។ អ្នកបានចាប់ផ្តើមទិញសណ្តែក និងស្ករស្តុកទុកជាច្រើន ។ បន្ទាប់មកអ្នកបានទិញដបប្លាស្ទិកជាច្រើន ដូច្នេះអ្នកអាចលក់ទឹកសណ្តែកកាន់តែច្រើនទៅឱ្យអតិថិជនទាំងឡាយណា ដែលចង់ទិញទឹកសណ្តែកយកទៅផ្ទះ ។ នៅពេលដែលប្រាក់ចំណូល របស់អ្នកកើនឡើង អ្នកអាចសន្សំច្រើនថែមទៀត ហើយធ្វើផែនការវិនិយោគធំឡើងៗ នៅក្នុងអាជីវកម្មរបស់អ្នក ។

អ្នកឈ្មោះ **ចន្ថា** ជាអ្នកប្រកបអាជីវកម្មទឹកសណ្តែក ។ បងស្រីរបស់អ្នក **នារី** ក៏ជាអ្នកប្រកបអាជីវកម្មទឹកសណ្តែកដែរ ។ ថ្ងៃនេះនាង នារី នឹងមកសួរសុខទុក្ខអ្នក ។ អ្នកមានចិត្តចង់ដឹងពីវិធីនានា ដែលបងស្រីរបស់អ្នកមានថវិកាសំរាប់ពង្រីកអាជីវកម្មរបស់គាត់ ។ ដូច្នេះអ្នកត្រូវសួរបងស្រីរបស់អ្នកឱ្យបានច្រើន អំពីវិធីនានាដែលគាត់ពង្រីកអាជីវកម្មរបស់គាត់ ។

បងស្រីរបស់អ្នកក៏ចង់ដឹងពីអ្នកផងដែរអំពីវិធីនានា ដែលអ្នករៀបចំថវិកាសំរាប់ពង្រីកអាជីវកម្មរបស់អ្នក ។ ខាងក្រោមនេះ គឺជាដំណើរការដែលអ្នកបានប្រកប និងពង្រីកការងារអាជីវកម្មរបស់អ្នក ។

អ្នកមានអាជីវកម្មទឹកសណ្តែកមួយ ដែលអ្នកបានចាប់ផ្តើមដំបូងជាមួយសាច់ប្រាក់ចំនួន ១០ ០០០ រៀល ដែលជាប្រាក់របស់អ្នកផ្ទាល់ និង ២០ ០០០ រៀលដែលជាកម្ចីពីធនាគារភូមិមួយ ។ ដោយមានប្រាក់កម្ចីនោះ អ្នកមានប្រាក់គ្រប់ចំនួន ដើម្បីទិញទូត្រជាក់មួយគ្រឿងសំរាប់ទុកទឹកសណ្តែកឱ្យបានយូរ ហើយអាចលក់ទឹកសណ្តែកត្រជាក់បាន ។ អ្នកអាចបង់ថ្លៃចំណាយទាំងឡាយប្រចាំសប្តាហ៍ ទាន់ពេលវេលាដោយរាប់បញ្ចូលទាំងការសងប្រាក់កម្ចី ប៉ុន្តែអ្នកអាចសន្សំបានច្រើនបំផុតត្រឹមតែ ២០០០ រៀលប៉ុណ្ណោះក្នុងមួយសប្តាហ៍ ។ នៅពេលមានតូបលក់ក្នុងផ្សារមួយ ត្រូវបានដាក់ឱ្យជួល អ្នកយល់បានឃើញថាវាជាឱកាសដ៏ល្អ សម្រាប់អាជីវកម្មរបស់អ្នក ។ អ្នកបានគណនាឃើញថា ការលក់របស់អ្នកនឹងកើនឡើងទ្វេរដង ។ អ្នកបានខ្ចីប្រាក់ ៤០០ ០០០ រៀល ពីប្អូនថ្លៃរបស់អ្នក ពីព្រោះអ្នកត្រូវការជួលតូបភ្លាមៗ ឬខ្លាចបាត់បង់ឱកាសជួលវា ។

## ជំនួយការបណ្ដុះបណ្ដាលទី ៥ៈ ប្រើប្រាស់ថវិកាកម្ចី ឬថវិការបស់អ្នក ដើម្បីផ្គត់ផ្គង់អាជីវកម្ម

| | ការប្រើថវិកាកម្ចី | ប្រើថវិកាប្រាក់របស់អ្នក |
|---|---|---|
| **គុណសម្បត្តិ** | - អ្នកអាចមានលទ្ធភាពទទួលប្រាក់គ្រប់ចំនួន ដែលច្រើនជាងប្រាក់សន្សំ ។<br>- អ្នកទទួលប្រាក់បានលឿន នៅពេលអ្នកត្រូវការវាសម្រាប់ភាពបន្ទាន់នានា ។ | - អ្នកជៀសផុតពីការចំណាយផ្សេងៗសំរាប់ខ្ចីប្រាក់ ។<br>- អ្នកមានសេរីភាពប្រើប្រាស់ប្រាក់របស់អ្នកតាមដែលចិត្តចង់ ។<br>- អ្នកមានការប្រឈមមុខនឹងហានិយភ័យតិចតួច នៅពេលអ្នកផ្គត់ផ្គង់ថវិកាដល់អាជីវកម្មបន្ថែមបន្តិចម្ដងៗ ដែលពឹងផ្អែកលើលទ្ធភាពដែលអ្នកអាចវិនិយោគ<br>- អ្នកជៀសផុតពីកាតព្វកិច្ចនៃការសងប្រាក់កម្ចីនៅពេលអនាគត ។ |
| **គុណវិបត្តិ** | - អ្នកត្រូវបង់ថ្លៃចំណាយផ្សេងៗសំរាប់ការខ្ចីនេះ ( ប្រាក់ការ ថ្លៃរដ្ឋបាល និងពេលវេលាស្នើសុំខ្ចី) ។<br>- អ្នកទទួលខុសត្រូវចំពោះការសងប្រាក់កម្ចីរបស់អ្នកឱ្យទាន់ពេលវេលា និងប្រឈមមុខនឹងការផាកពិន័យចំពោះការសងយឺតយ៉ាវ ។<br>- អ្នកត្រូវបំពេញទៅតាមតម្រូវការនានារបស់សមាជិកភាពក្នុងក្រុម (ចូលរួមប្រជុំទាន់ពេល ។ល។) ប្រសិនបើប្រាក់កម្ចីនោះត្រូវធ្វើឡើងទៅតាមរយៈក្រុម | - អ្នកខ្វះលទ្ធភាពដើម្បីទទួលបានដើមទុនដែលត្រូវការ ។<br>- អាជីវកម្មរបស់អ្នករីកចម្រើនយឺត<br>- លទ្ធភាពឆ្លើយតបទៅនឹងឱកាសនានាមានកំរិត |

## ជំនួយការបណ្តុះបណ្តាលទី ៦: បំណុលល្អ និងបំណុលអាក្រក់

| ការប្រើប្រាស់បំណុល | បំណុលល្អ | បំណុលអាក្រក់ |
|---|---|---|
| ទិញសំភារៈសម្រាប់អាជីវកម្ម | ទ្រព្យឬសំភារៈដែលបានទិញមានអាយុកាលប្រើប្រាស់យូរអង្វែងសម្រាប់ទូទាត់ទៅឱ្យម្ចាស់បំណុល ។ ចំណូលដែលរកបានពីទ្រព្យនោះ គឺខ្ពស់ជាងចំណាយទៅលើប្រាក់កម្ចី ។ | បំណុលគឺនៅតែជាប់ជំពាក់ ក្រោយពីទ្រព្យនោះត្រូវអស់អាយុកាលប្រើប្រាស់ ហើយខូចខាត ឬប្រាក់ចំណូលពីទ្រព្យសម្បត្តិនោះ មានចំនួនតិចតួចជាងថ្លៃប្រាក់កម្ចី ។ |
| ដើមទុនបង្វិល | ប្រាក់កម្ចីអាចឱ្យអ្នកចាប់យកឱកាសអាជីវកម្មណាមួយ ដែលអាចរកកម្រៃគ្រប់គ្រាន់ដើម្បីសងប្រាក់កម្ចីវិញ និងមានប្រាក់មួយចំនួននៅសេសសល់ ។ ប្រាក់កម្ចី ដែលជួយឱ្យអ្នកអាចសន្សំជាទុន ឬជាសារពើភ័ណ្ឌផ្សេងៗ ដូច្នេះវាជួយបង្កើនប្រាក់ចំណូលពីការលក់ផលិតផលសម្រេច ។ | - អ្នកមិនអាចរកប្រាក់ចំណូលគ្រប់គ្រាន់ដើម្បីសងប្រាក់កម្ចី ។<br>- អ្នកមានប្រភពផ្គត់ផ្គង់ថវិកាផ្សេងៗទៀតដែលមិនសូវយកតម្លៃថ្លៃ ។<br>- អ្នកមិនអាចទទួលបានប្រាក់កម្ចីទាន់ពេលដើម្បីទាញយកផលប្រយោជន៍ឱ្យបានពេញលេញពីឱកាសជាក់លាក់ណាមួយ ។ |
| តំរូវការចាំបាច់ក្នុងគ្រួសារ | | បំណុលគឺនៅតែជាប់ជំពាក់ ក្រោយពីប្រាក់កម្ចីត្រូវបានប្រើប្រាស់រួចហើយ ។ប្រាក់កម្ចីមិនបានបង្កើតប្រាក់ចំណូល ដើម្បីយកទៅទូទាត់បំណុលឡើយ ។ |
| កម្ចីសម្រាប់ភាពបន្ទាន់ | ប្រាក់កម្ចីជួយអ្នកដោះស្រាយបញ្ហាភ្លាមៗដោយមិនបង្កឱ្យមានការលំបាកហួសហេតុ ។ | រយៈពេលសំរាប់សងប្រាក់កម្ចីមានកំណត់ច្បាស់លាស់ មិនអាចបត់បែនទៅតាមសមត្ថភាពសងរបស់អ្នក ។ |

## ជំនួយការបណ្តុះបណ្តាលទី ៧ : ការពិភាក្សាអំពីការប្រើប្រាស់ថវិកាផ្ទាល់ខ្លួន និងថវិកាកម្ចី ដើម្បីធ្វើអាជីវកម្ម



# មេរៀនទី ៥ : គ្រោះថ្នាក់នៃការជាប់បំណុលធ្ងន់ធ្ងរ និងការខកខានមិនបានសង




កំណត់ចំណាំរបស់គ្រូបណ្ដុះបណ្ដាល

## គោលបំណង

នៅចុងបញ្ចប់មេរៀននេះ សិក្ខាកាមទាំងអស់នឹងបាន :

- ពិភាក្សាគ្នាថា ហេតុអ្វីបានជាការខកខានមិនបានសងបំណុល អាចជាដំបញ្ហាធ្ងន់ធ្ងរមួយ
- កំណត់រកមូលហេតុផ្សេងៗ ដែលធ្វើឱ្យអ្នកជំពាក់មិនអាចសងបំណុលខ្លួនបាន
- កំណត់រកជំហ៊ាននានា ដើម្បីជៀសវាងបញ្ហាមិនអាចសងបំណុល

## ប្លង់វគ្គសិក្សា (១៣០ នាទី)

### *ជំហ៊ានទី ១ - ២០ នាទី*

ពិភាក្សា : តើមានមូលហេតុអ្វីខ្លះ ដែលបណ្ដាលឱ្យមានអ្នកខ្លះមិនអាចសងបំណុលបាន ? ឬ តើមានមូលហេតុអ្វីខ្លះ ដែលអ្នកគិតថាអាចបណ្ដាលឱ្យអ្នកខ្ចីប្រាក់ មិនអាចសងបំណុលវិញបាន ? កត់ត្រាចម្លើយ រហូតទាល់តែសិក្ខាកាមបានបញ្ចេញអស់គំនិត ។

**ខ្លឹមសារគន្លឹះសម្រាប់គ្រូបណ្ដុះបណ្ដាល :**

មូលហេតុដែលអាចកើតឡើង មានដូចជា :

- អាជីវកម្មរបស់គាត់កំពុងជួបបញ្ហា
- គាត់ប្រើប្រាស់ប្រាក់កម្ចីសម្រាប់ជាដើមទុនបង្វិល ទៅលើមុខចំណាយផ្ទាល់ខ្លួនរបស់គាត់
- គាត់ត្រូវឱ្យប្រាក់ទៅគ្រួសារសំរាប់ចូលរួមសកម្មភាពសង្គម
- គាត់បាត់បង់ប្រាក់ដោយសារចោរលួច
- គាត់មានជម្ងឺ ដែលមិនអាចឱ្យគាត់ទៅប្រកបអាជីវកម្មបាន
- គ្រោះធម្មជាតិ
- យកប្រាក់កម្ចីទៅទិញសៀវភៅ និងសំលៀកបំពាក់ឱ្យកូន
- យកប្រាក់កម្ចីទៅឱ្យគ្រួសារមួយទៀតដែលជួបបញ្ហា
- សកម្មភាពអាជីវកម្មមានលក្ខណៈប្រថុយប្រថានពេក ដូចជាការលក់ជឿទៅឱ្យអតិថិជន
- ខកខានមិនបានកត់ត្រាទុកនូវរាល់ការសងប្រាក់កម្ចីទាំងអស់
- ខកខានមិនបានដកប្រាក់សន្សំសម្រាប់ការសងប្រាក់កម្ចីនៅក្នុងរយៈពេលទៀងទាត់

### ជំហានទី ២ - ១០ នាទី

ឥឡូវនេះ ចូរយើងក្រឡេកមើលហេតុផលនានាដូចដែលបានលើកឡើងកន្លងមក ហើយសម្រេចថាតើមានហេតុផលណាមួយ ដែលបណ្តាលមកពីអ្នកខ្ចីប្រាក់ធ្វើសេចក្តីសម្រេចមិនបានល្អ និងហេតុផលណាមួយដែលបណ្តាលមក ពីសំណាងមិនល្អ ដែលមិនអាចជៀសវាងបាន ។ ណែនាំសិក្ខាកាមឱ្យដាក់សញ្ញាសំគាល់លើការធ្វើសេចក្តីសម្រេចមិនល្អ ដោយរូបរង្វង់មុខពេប និងលើសំណាងមិនល្អ ដោយសញ្ញាអក្សរ X ។

នៅក្នុងករណីដែលមិនយល់ស្របគ្នា ចូរលើកទឹកចិត្តឱ្យសិក្ខាកាមពន្យល់ទស្សនៈរបស់គេ ។

### ជំហានទី ៣ - ៣០ នាទី

**ការប្រឡងប្រជែង :** បែងចែកសិក្ខាកាមជា ៤ ឬ ៥ ក្រុម ។ ប្រាប់ពួកគេថា ពួកគេនឹងបានឮ បញ្ហាមួយចំនួន ព្រមជាមួយដំណោះស្រាយដែលបានផ្តល់ឱ្យ (ចម្លើយមានជម្រើសច្រើន) ទៅនឹងបញ្ហាទាំងនោះ ។ ចូរធ្វើការសម្រេចចិត្តនៅក្នុងចំណោមសមាជិកក្រុមរបស់អ្នក ថាតើដំណោះស្រាយណាមួយដែលមានភាពត្រឹមត្រូវបំផុត ។ ក្រោយពេលដែលក្រុមរបស់អ្នកបានសម្រេចចិត្តជ្រើសយកជម្រើសត្រឹមត្រូវរួច ហើយចូរលើកដៃឱ្យបានលឿន ។ ក្រុមមួយណាដែលលើកដៃមុនគេ នឹងមានឱកាសឆ្លើយសំណួរមុនគេ។ ប្រសិនបើក្រុមនេះបានជ្រើសរើសចម្លើយត្រឹមត្រូវ ពួកគេនឹងទទួលបាន ១ ពិន្ទុ ។ ប៉ុន្តែប្រសិនបើក្រុមនេះ បានផ្តល់ចម្លើយមិនត្រឹមត្រូវទេនោះ ក្រុមទីពីរនឹងមានឱកាសសាកល្បងឆ្លើយសំណួរវិញម្តង ។ ចូរពិភាក្សា ចម្លើយជាមួយក្រុម ។

គ្រូបណ្តុះបណ្តាល គួរគប្បីគូរតារាងដូចខាងក្រោមនេះ :

| ក្រុម | បញ្ហា ១ | បញ្ហា ២ | បញ្ហា ៣ | បញ្ហា ៤ |
|---|---|---|---|---|
| ១ | | | | |
| ២ | | | | |
| ៣ | | | | |
| ៤ | | | | |

### ដំណោះស្រាយបញ្ហាទី ១

បញ្ហា : **សុធារី**ខ្ចីប្រាក់ចំនួន ៤០០ ០០០រៀល ដើម្បីយកទៅទិញទូត្រជាក់ ដែលត្រូវគេប្រើម្តងហើយ (ជជុះ) មួយគ្រឿងសម្រាប់អាជីវកម្មទឹកសណ្តែករបស់នាង ដែលមានតម្លៃ ២០០ ០០០រៀល ។ ផែនការពី ដំបូងរបស់នាងគឺនឹងប្រើប្រាស់ប្រាក់ចំនួន ២០០ ០០០រៀល ដែលនៅសល់នេះ ដើម្បីយកទៅទិញសណ្តែក ជាចំនួនច្រើនសម្រាប់ការជួញដូរ ហើយរកប្រាក់ចំណូលឱ្យបានគ្រប់គ្រាន់ ដើម្បីសងប្រាក់កម្ចីនៅដំណាក់កាលទីមួយក្នុងចំណោមដំណាក់កាលទាំងបី ។ ក៏ប៉ុន្តែមិត្តភក្តិរបស់នាង គឺនាង **សុខា** បានបញ្ចុះបញ្ចូលសុំខ្ចីបន្ត នូវសាច់ប្រាក់ ២០០ ០០០ រៀលនេះ ដែលនាងសន្យាថា នឹងសងវិញគ្រប់ចំនួននៅមុនពេលការសងប្រាក់កម្ចី លើកទីមួយរបស់ **សុធារី** ។ សុខាបានគេចខ្លួនបាត់ស្រមោលជាមួយនឹងប្រាក់ខ្ចីនោះ ។ តើនាង**សុធារី** អាចធ្វើអ្វីខ្លះ ដើម្បីឱ្យបានប្រសើរជាងនេះ ?

**ជម្រើសទី ១ :** តម្រូវឱ្យមិត្តភក្តិមានដាក់ទ្រព្យបញ្ចាំដែលមានតម្លៃច្រើនជាង នៅពេលផ្តល់ប្រាក់នោះឱ្យខ្ចី (ឧ. ខ្សែរកមាស) ។

**ជម្រើសទី ២ :** បដិសេធនឹងសំណើសុំខ្ចីរបស់មិត្តភក្តិ ហើយស៊ូទ្រាំនឹងការខឹងសម្បាររបស់នាង ។ ✔

**ជម្រើសទី ៣ :** ឱ្យខ្ចីត្រឹមតែចំនួនពាក់កណ្តាលនៃចំនួន ២០០ ០០០រៀល ហើយដាក់វិនិយោគចំនួន ១០០ ០០០ រៀល ដែលនៅសល់ ដើម្បីរកប្រាក់ចំណូលដែលនាងត្រូវការយកទៅសងប្រាក់កម្ចី ។

---

### ដំណោះស្រាយបញ្ហាទី ២

បញ្ហា : ធីតា ខ្ចីប្រាក់ចំនួន ៤០០០០រៀល ដើម្បីយកទៅទិញគ្រាប់ពូជនិងជីរសម្រាប់ច្បារដំណាំរបស់នាង ។ ដំណាំបានដុះយ៉ាងល្អ ហើយនាងបានរីករាយជាខ្លាំង ព្រោះសង្ឃឹមថានឹងរកប្រាក់កម្រៃបានច្រើន ពីការលក់ដំណាំនោះ ។ នាងទិញសំលៀកបំពាក់ថ្មីមួយកំប្លេសម្រាប់ខ្លួនឯង និងបាល់ថ្មីមួយសម្រាប់កូនប្រុសរបស់នាង ។ ប៉ុន្តែនៅចុងខែ ខណៈដែលនាងត្រូវសងប្រាក់កម្ចីវិញនោះ នាងមាននៅសល់ប្រាក់តែចំនួនពាក់កណ្តាលនៃចំនួនប្រាក់ដែលត្រូវសងប៉ុណ្ណោះ ។ តើនាងអាចធ្វើអ្វីខ្លះ ដើម្បីឱ្យបានប្រសើរជាងនេះ ?

**ជម្រើសទី ១ :** បានរៀបចំប្រាក់ទុកសម្រាប់សងប្រាក់កម្ចីរបស់នាងជាមុនសិន មុនពេលទិញរង្វាន់ផ្សេងៗ ។ ✔

**ជម្រើសទី ២ :** ទិញជារង្វាន់ទាំងនោះ ហើយខ្ចីប្រាក់ចំនួនពាក់កណ្តាលទៀតពីប្អូនស្រីរបស់នាង ។

**ជម្រើសទី ៣ :** ខ្ចីប្រាក់ច្រើនជាងនេះនៅពេលចាប់ផ្តើមដំបូង ដូច្នេះនាងអាចដំណើរការអាជីវកម្ម និងអាចទិញរង្វាន់ទាំងនោះបាន ។

### ដំណោះស្រាយបញ្ហាទី ៣

បញ្ហា: **ណារិទ្ធ** បានទទួលប្រាក់កម្ចីពីធនាគារភូមិរបស់គាត់ ដើម្បីយកទៅបើកហាងតូចមួយ។ អាជីវកម្មរបស់គាត់មានលក្ខណៈតូចតាច ប៉ុន្តែមានលំនឹង ហើយគាត់តែងតែបានសងប្រាក់កម្ចីរបស់គាត់ទាន់ពេលវេលា ។ តែនៅពេលមួយ កូនប្រុសរបស់គាត់បានរងរបួសស្នាមដោយឧប្បត្តិហេតុ គាត់បានខ្ចីប្រាក់សម្រាប់ដោះស្រាយ ភាពបន្ទាន់នេះពីធនាគារភូមិរបស់គាត់ដើម្បីទូទាត់ចំណាយថ្លៃព្យាបាល ។ បន្ទាប់មក គាត់បានបិទហាងរបស់គាត់ ដើម្បីនៅផ្ទះមើលថែទាំជម្ងឺកូនប្រុសគាត់ ម្លោះហើយមិនអាចសងប្រាក់កម្ចីទាំងពីរលើកនោះបានទេ ។

---

**ជម្រើសទី ១ :** បានរកពឹងនរណាម្នាក់ ឱ្យនៅមើលថែទាំជមឺកូនប្រុសរបស់គាត់ ដូច្នេះគាត់អាចនៅបន្តបើកហាងរបស់គាត់ទៀតបាន ។

**ជម្រើសទី ២ :** បានលក់ទ្រព្យផ្សេងៗដែលមានតម្លៃ (ឧ. គ្រឿងអលង្ការ ទូរទស្សន៍) ដើម្បីទូទាត់ចំណាយថ្លៃព្យាបាល ជំនួសឱ្យការទៅខ្ចីប្រាក់បន្ថែមទៀត ។ ✔

**ជម្រើសទី ៣ :** បង្កើនតម្លៃលក់ទ្វេរដងទៅលើទំនិញនានានៅក្នុងហាងរបស់គាត់ ដើម្បីរកចំនួនប្រាក់ដែលត្រូវការសម្រាប់យកទៅទូទាត់ថ្លៃព្យាបាល ។

---

### ដំណោះស្រាយបញ្ហាទី ៤

បញ្ហា : ស្រីនីធ្លាក់ខ្លួនឈឺ ហើយត្រូវឈប់សំរាកនៅផ្ទះអស់រយៈពេលពីរ បីសប្តាហ៍ ។ នាងបានទទួលប្រាក់កម្ចីតូចមួយពីស្ថាប័នហិរញ្ញវត្ថុ ដើម្បីទូទាត់សម្រាប់ថ្លៃវេជ្ជបណ្ឌិត និងថ្លៃព្យាបាល ។ ដោយសារតែនាងមិនអាចធ្វើការបាននៅក្នុងរោងចក្រឡតដ្ឋនៅអំឡុងពេលនោះ នាងអាចរកប្រាក់បានតិចតួចប៉ុណ្ណោះ ហើយមិនអាចសងប្រាក់កម្ចីរបស់នាងបានទេ ។ នៅពេលដែលនាងអាចធ្វើការឡើងវិញម្តងទៀត នាងត្រូវជំពាក់បំណុលជាច្រើនដោយសារថ្លៃបង់ពិន័យ ។ នាងកំពុងស្ថិតនៅក្នុងភាពអស់សង្ឃឹម ហើយបារម្ភថាត្រូវតែឱ្យកូនៗរបស់នាងជួយធ្វើការជាមួយនាង នៅក្នុងរោងចក្រឡតដ្ឋដែរ ។

**ជម្រើសទី ១ :** ពិភាក្សាជាមួយសមាជិកគ្រួសារដើម្បីរកមើលថា តើគេអាចរកប្រាក់ពីប្រភពណាយកទៅសងប្រាក់កម្ចី ដើម្បីជៀសវាងការបង់ប្រាក់ការពិន័យ នៅអំឡុងពេលដែលនាងសម្រាកព្យាបាលជម្ងឺ ។

**ជម្រើសទី ២ :** សន្សំប្រាក់បន្តិចបន្តួចនៅក្នុងសប្តាហ៍នីមួយៗ ឬប្រចាំថ្ងៃ ដែលជាចំនួនលើស ឬក្រៅពីចំនួនដែលនាងត្រូវការដើម្បីទុកសងប្រាក់កម្ចី ប្រយោជន៍ទុកការពារខ្លួនឯងផ្ទាល់នៅពេលជួបប្រទះស្ថានភាពដូច្នេះ ។ ✔

**ជម្រើសទី ៣ :** ខ្ចីប្រាក់បន្ថែមទៀត ដើម្បីយកទៅទូទាត់ប្រាក់កម្ចីលើកទីមួយ ។

### ជំហានទី ៤-៣០ នាទី

ប្រាប់សិក្ខាកាមទាំងអស់គ្នាថា ពួកគេនឹងទស្សនាការសម្ដែងរឿងខ្ចីមួយ (សូមមើលជំនួយការបណ្ដុះបណ្ដាលទី៨)។ ប៉ុន្តែមុននឹងចាប់ផ្ដើម សាកសួរពួកគេ ថាតើពួកគេស្គាល់ស្ថាប័នហិរញ្ញវត្ថុណាមួយ ឬឈ្មួញឱ្យប្រាក់ខ្ចីណាម្នាក់ ហើយដាក់ឈ្មោះរបស់អ្នកផ្ដល់ប្រាក់កម្ចីទាំងឡាយនោះ នៅក្នុងសាច់រឿង (អក្សរពណ៌ខ្មៅ) ជាមួយនឹងឈ្មោះអ្នកផ្ដល់ប្រាក់កម្ចីដែលពួកគេបានស្គាល់ ។ បន្ទាប់មក ចូរជ្រើសរើសសិក្ខាកាមបីនាក់ដើម្បីឡើងសម្ដែងរឿងនេះ។

បន្ទាប់ពីការសំដែង ចូរថ្លែងអំណរគុណដល់តួអង្គសម្ដែងទាំងអស់ រួចពិភាក្សាលើសំណួរដូចតទៅ :

- តើ ស៊ីថា កំពុងធ្វើអ្វីខ្លះ ? (ខ្ចីប្រាក់ពីប្រភពបីផ្សេងៗគ្នា)
- ហេតុអ្វីក៏នាងព្យាយាមខ្ចីប្រាក់ពីមនុស្សច្រើនគ្នាយ៉ាងនេះ ? (នាងកំពុងខ្ចីពីម្នាក់ ដើម្បីយកទៅសងបំណុលម្នាក់ផ្សេងទៀត)
- តើនាងស៊ីថា គិតយ៉ាងដូចម្ដេចទៅលើអ្នកផ្ដល់ប្រាក់កម្ចីផ្សេងៗគ្នាទាំងនោះ ដែលនាងសង្ឃឹមថា នឹងបានប្រាក់ខ្ចីពីពួកគេ ? (នាងគិតថានាងអាចខ្ចីពីពួកគេម្នាក់ៗបានដោយងាយស្រួល ហើយគ្មានអ្នកឱ្យខ្ចីណាម្នាក់យកចិត្តទុកដាក់ចង់ដឹងនោះទេ ប្រសិនបើនាងទៅខ្ចីអ្នកផ្សេងទៀត ក្នុងពេលតែមួយ )
- តើស្វាមីរបស់នាង ស៊ីថា កំពុងតែជ្រោមជ្រែងនាងដែរឬទេ ? គាត់មិនបានរក្សាពាក្យសន្យារបស់គាត់ (ហើយទំនងជាមិនទទួលការខុសត្រូវទៀតផង)
- តើអ្នកគិតថា នឹងមានអ្វីខ្លះកើតឡើងដល់នាងស៊ីថា ? ដាយថាហេតុ នាងនឹងមិនអាចសងប្រាក់កម្ចីមួយ ឬពីរក្នុងបណ្ដាប្រាក់កម្ចីទាំងអស់បានទេ ។ ក្រុមរបស់នាង អាចស្នើឱ្យនាងចាកចេញពីក្រុម ឬក៏ទៅផ្ទះរបស់នាង ដើម្បីប្រមូលយកទ្រព្យបញ្ចាំសម្រាប់ប្រាក់កម្ចី ដែលនាងមិនអាចសងបាន។ នាងនឹងក្លាយខ្លួនជាអ្នកខ្ចីប្រាក់ដែលមានកិត្តិនាមមិនល្អ ហើយនាងនឹងបាត់បង់សមត្ថភាពខ្ចីនៅពេលខាងមុខទៀត ។

### ជំហានទី ៥ - ៣០ នាទី

ការកំណត់រកផលវិបាកនានា ដែលបណ្ដាលមកពីការខកខានមិនបានសងប្រាក់កម្ចី

**តើអ្នកស្គាល់នរណាម្នាក់ ដែលបានខកខានមិនសងប្រាក់កម្ចីណាមួយដែរឬទេ ? តើមានអ្វីកើតឡើងចំពោះរូបគេ ?**

ចូរយើងងាកទៅមិត្តភក្ដិរបស់យើង គឺនាង **ស៊ីថា** ម្ដងទៀត ។ យើងសន្មត់ថាគាត់ជួបប្រទះបញ្ហាជាច្រើនដោយសារតែបំណុលជាច្រើន ដែលនាងមិនបានសង ។ ឥឡូវនេះ ចូរយើងសម្លឹងរកមើល ថាតើមានអ្វីខ្លះដែលអាចកើតឡើងដល់**ស៊ីថា** ដែលជាលទ្ធផលនៃការមិនបានសងប្រាក់កម្ចីរបស់នាង ។ ក្រុមនីមួយៗនឹងទទួលបានក្រដាសកាតមួយ ។ អ្នកត្រូវរៀបចំគូរគំនូរដែលបង្ហាញពីផលវិបាកផ្សេងៗ ហើយក្រុមអ្នកប្រើកាយវិការដើម្បីបង្ហាញនូវផលវិបាកទាំងនោះ ។ សិក្ខាកាមដទៃៗទៀតនឹងរង់ចាំសង្កេតមើល និងធ្វើសេចក្ដីសម្រេចទៅលើផលវិបាក ដែលក្រុមអ្នកបង្ហាញ ។

## ក្រដាសកាតសម្រាប់ការសម្តែងរឿង

| |
|---|
| អ្នកគឺជាសមាជិកក្រុម ដែលបានឱ្យនាង**ស៊ីថា** ខ្ចីប្រាក់ ។ អ្នកកំពុងព្យាយាមសម្រេចត្រូវធ្វើអ្វីខ្លះ ចំពោះការខកខានមិនបានសងប្រាក់កម្ចីរបស់ស៊ីថា ។ |

| |
|---|
| អ្នកគឺជាសមាជិកគ្រួសាររបស់នាង **ស៊ីថា** (បងស្រី បងប្អូនសាច់ថ្លៃ ម្តាយមីង ។ល។) ដែលទាំងអស់គ្នាបានឱ្យ ប្រាក់នាងខ្ចី តែនាងមិនដែលបានសងវិញសោះ ។ |

| |
|---|
| អ្នកគឺជាម្ចាស់ហាង ដែលកំពុងពិភាក្សាគ្នាអំពីការផ្តល់ប្រាក់កម្ចីដល់អតិថិជន : តើអតិថិជនប្រភេទណាខ្លះដែលអ្នកឱ្យប្រាក់ខ្ចី និងប្រភេទណាខ្លះដែលអ្នកមិនឱ្យប្រាក់ខ្ចី ។ |

ស្នើឱ្យសិក្ខាកាមឡើងបង្ហាញលទ្ធផលរបស់គេ ។ ក្រោយពីការបង្ហាញនីមួយៗ ចូរសួរ : **នៅក្នុងឆាកនេះ តើមានអ្វីខ្លះជាផលវិបាកចំពោះស៊ីថា** ?

បន្ទាប់ពីបានបង្ហាញអស់ហើយ ចូរនិយាយថា: ការខកខានមិនបានសងប្រាក់កម្ចី មានផលវិបាកអវិជ្ជមានជាច្រើន ។ **តើមានវិធីណាខ្លះ ដើម្បីជៀសវាងការខកខានមិនបានសងប្រាក់កម្ចីនៅគ្រាដំបូងនោះ ដែរឬទេ** ?

សង្ខេបគំនិតនានារបស់សិក្ខាកាម ។ ចូរពន្យល់ចំណុចដូចខាងក្រោមនេះ ប្រសិនបើសិក្ខាកាមមិនបានលើកឡើង ។

- ខ្ចីប្រាក់ត្រឹមចំនួនណាដែលអ្នកអាចសងវិញបាន ។
- ប្រសិនបើអ្នកខកខានមិនបានសង ចូរបង្ហាញភាពស្មោះត្រង់ជាមួយអ្នកផ្តល់ប្រាក់ឱ្យខ្ចី អំពីបញ្ហាផ្សេងៗរបស់អ្នក ។
- ទទួលដំបូន្មានពីអ្នកផ្តល់ប្រាក់កម្ចី មិត្តភក្តិ និងក្រុមគ្រួសារ នូវវិធីនានា ដើម្បីសងប្រាក់កម្ចីរបស់អ្នក ។
- កាត់បន្ថយចំណាយផ្សេងៗមួយចំនួន ដើម្បីជួយក្នុងការសងបំណុលរបស់អ្នក ។
- ចូរពិចារណាអំពីសកម្មភាពអាជីវកម្មរបស់អ្នក ។ តើត្រូវធ្វើយ៉ាងណា ដើម្បីឱ្យមានភាពប្រសើរឡើង ដើម្បីបង្កើនការលក់ផលិតផល និងសេវាកម្មទាំងឡាយ ?

### *ជំហានទី ៦ - ១០ នាទី*

តើអ្វីទៅជាបណ្តាំពីរយ៉ាង ដែលអ្នកនឹងប្រាប់ក្រុមគ្រួសាររបស់អ្នកអំពីប្រាក់កម្ចី ឬការខកខានមិន បានសងប្រាក់កម្ចីនោះ ?

## ជំនួយការបណ្តុះបណ្តាលទី ៨ : រឿងអ្នកខ្ចីប្រាក់បីនាក់

ម៉េង : អ្ហេ! ស៊ីថា ក្រែងថ្ងៃនេះ គឺជាថ្ងៃដែល**ធនាគារភូមិ** ផ្តល់ការយល់ព្រមទៅលើសំណើខ្ចីប្រាក់របស់យើងមែនឬ ?

ស៊ីថា : មែនហើយ ! គណៈកម្មការឥណទានជួបប្រជុំគ្នានៅម៉ោង ១១ :០០ ព្រឹកនេះឯង ។ ខ្ញុំមិនបារម្ភទេ ពីព្រោះថាយើងសុំខ្ចីតែ ២០ ០០០រៀល គឺតិចជាងចំនួនដែលយើងធ្លាប់បានខ្ចីពីមុនផង ។

ម៉េង : ប៉ុន្តែស៊ីថា តើឯងអាចខ្ចីតែចំនួន ២០ ០០០រៀល យ៉ាងដូចម្តេចទៅកើត ? តើឯងភ្លេចហើយឬ នៅសប្តាហ៍ក្រោយនេះ យើងត្រូវសងប្រាក់កម្ចីទៅឱ្យ ACLEDA ផងណា ?

ស៊ីថា : ម៉េង,,, បងបានប្រាប់ខ្ញុំថា បងអាចរកប្រាក់មកសងប្រាក់កម្ចីនោះហើយមែនទេ !

ម៉េង : ខ្ញុំដឹង ,,, តែខ្ញុំមិនអាចរកបានទេ ។ ឯងត្រូវខ្ចីយ៉ាងហោចណាស់ក៏ចំនួន ៤០ ០០០ រៀល ដែរពី **ធនាគារភូមិ** ។

ស៊ីថា : អាអ្ហា ! ខ្ញុំនឹងមិនអាចសងប្រាក់កម្ចីដ៏ច្រើននេះបានទេ !

ម៉េង : កុំព្រួយពេក! ខ្ញុំនឹងឱ្យប្រាក់ដែលឯងត្រូវការនៅពេលក្រោយ ។ ខ្ញុំត្រូវទៅហើយចាំជួប គ្នានៅពេលក្រោយ !

### អង្គប្រជុំរបស់ស៊ីថា ជាមួយធនាគារភូមិ : ស៊ីថា និង សុវណ្ណាដើរចូលមក

ស៊ីថា : អ្ហេសំឡាញ់ ! ឱ្យគ្នាខ្ចី ១០ ០០០រៀលមក ដើម្បីយកទៅសងគេនៅថ្ងៃនេះ បានទេ ?

សុវណ្ណ : អូ ,,, មែនហើយ ស៊ីថា (ទំនងជាខឹង) ។ នេះគឺជាលើកទីពីរហើយ ដែលឯងបានមកខ្ចីគ្នា សម្រាប់យកទៅសងបំណុលរបស់ឯង ។ ឯងមិនទាន់បានសងប្រាក់គ្នាចំនួន ១០ ០០០ រៀលកាលដែលខ្ញុំឱ្យឯងខ្ចីពីពេលមុនផង !

ស៊ីថា : កុំព្រួយ ! គ្នានឹងសងឯង ។ ថ្ងៃនេះ ខ្ញុំនឹងបានទទួលប្រាក់ពី AMK ហើយខ្ញុំនឹងសងឯងភ្លាម ។

សុវណ្ណ : តើឯងកំពុងខ្ចីប្រាក់ពី AMK ឬ ?

ស៊ីថា : មែនហើយ ខ្ញុំត្រូវខ្ចីគេ ពីព្រោះថា ការលក់ដូររបស់ខ្ញុំក្នុងមួយរយៈពេលនេះមិនល្អសោះ ហើយខ្ញុំមានបំណុលយ៉ាងច្រើន ។ ហេតុអ្វីក៏ឯងមិនទៅជាមួយគ្នាតែម្តងទៅ នៅរសៀលនេះ ? កុំគិតច្រើនពេក ! ឯងអាចនឹងទទួលប្រាក់កម្ចីច្រើនៗបានណា នៅទីនោះ !

សុវណ្ណ : គ្នាមិនទាន់ដឹងទេ ។ ចាំខ្ញុំគិតមើលសិន ។

ស៊ីថា : កុំឆោតពេក ។ ខ្ចីប្រាក់គេ វាងាយស្រួលទេ ។ នោះហើយគឺជាអ្វីដែលគ្នាកំពុងធ្វើ ដើម្បីបានប្រាក់យកមកសងឯងហ្នឹងណា ។ ទៅ ឯងនឹងមានប្រាក់គ្រប់គ្រាន់ទៅតាមតម្រូវការរបស់ឯងបាន ។ ខ្ញុំនឹងទៅកាត់តាមផ្ទះរបស់ឯងនៅម៉ោង ១ រសៀល ។ ត្រៀមខ្លួនឱ្យស្រេចទៅណា ។

## ជំនួយការបណ្តុះបណ្តាលទី ៩ : ក្រដាសកាតសម្រាប់ការសម្តែងរឿង

អ្នកគឺជាសមាជិកក្រុមនានាដែលបានឱ្យ **ស៊ីថា** ខ្ចីប្រាក់។ អ្នកកំពុងព្យាយាមសម្រេចត្រូវធ្វើអ្វីខ្លះ ចំពោះការខកខានមិនបានសងប្រាក់កម្ចីរបស់ស៊ីថា ។

អ្នកគឺជាសមាជិកគ្រួសាររបស់នាង**ស៊ីថា** (បងស្រី បងប្អូនសាច់ថ្លៃ ម្តាយមីង ។ល។) ដែលទាំងអស់គ្នាបានឱ្យ ប្រាក់នាងខ្ចី តែនាងមិនដែលបានសងវិញសោះ ។

អ្នកគឺជាម្ចាស់ហាង ដែលកំពុងពិភាក្សាគ្នាអំពីការផ្តល់ប្រាក់កម្ចីដល់អតិថិជន : តើអតិថិជនប្រភេទណាខ្លះដែល អ្នកឱ្យប្រាក់ខ្ចី និងប្រភេទណាខ្លះដែលអ្នកមិនឱ្យប្រាក់ខ្ចី ។

## ជំនួយការបណ្តុះបណ្តាលទី ១០ ៖ ផលវិបាកនៃការមិនបានសងបំណុល

ខ្ញុំគ្មានលទ្ធភាពសងបំណុលទាំងអស់បានទេ
ដូច្នេះខ្ញុំត្រូវបង្ខំចិត្តលក់ដីស្រែ ដែលជា
កេរ្តិ៍ដំណែលពីដូនតា



# មេរៀនទី ៦ : ការប្រៀបធៀបសេវាសន្សំប្រាក់




កំណត់ចំណាំរបស់គ្រូបណ្តុះបណ្តាល

## គោលបំណង

នៅចុងបញ្ចប់មេរៀន សិក្ខាកាមទាំងអស់នឹងបាន :

- កំណត់យន្តការនានា សម្រាប់ការសន្សំប្រាក់របស់សមាជិក នៅក្នុងសហគមន៍របស់ពួកគេ
- ពិភាក្សាពីគុណសម្បត្តិ និងគុណវិបត្តិ របស់វិធីផ្សេងៗនៃការសន្សំប្រាក់
- កំណត់កត្តាផ្សេងៗ ដែលអាចជះឥទ្ធិពលដល់ជម្រើសនៃសេវាសន្សំប្រាក់របស់ពួកគេ
- ផ្តួផ្តងគោលបំណងនានានៃការសន្សំប្រាក់និងប្រភេទបញ្ញើប្រាក់

## ប្លង់វគ្គសិក្សា (១៥០ នាទី)

### *ជំហានទី ១ - ១០ នាទី*

ពិភាក្សា : **តើមនុស្សនៅក្នុងភូមិរបស់អ្នក សន្សំប្រាក់ទុកដោយវិធីណាខ្លះ** ? ជំរុញឱ្យសិក្ខាកាម រិះរកវិធីផ្សេងៗទាំងអស់ ដែលអ្នកភូមិទាំងនោះតែងសន្សំ ដោយរាប់បញ្ចូលការសន្សំទុក " ក្នុងផ្ទះ " " ទិញជាគ្រឿងអលង្ការ " " ទិញជាសត្វចិញ្ចឹម " " ក្នុងក្រុមសន្សំប្រាក់ " " ជាមួយស្ថាប័នហិរញ្ញវត្ថុនានា " ឬ " ក្នុងធនាគារ " ។ ចូរកត់ត្រាចម្លើយទាំងឡាយរបស់គេនៅលើក្រដាសផ្ទាំងធំ (សូមមើលឧទាហរណ៍ខាងក្រោម) ។

សម្រាប់ប្រភេទសន្សំប្រាក់នីមួយៗ ចូរស្នើឱ្យសិក្ខាកាមលើកដៃ ប្រសិនបើពួកគេបានប្រើប្រាស់វិធីសន្សំប្រាក់ផ្សេងពីនេះ ។

### *ជំហានទី ២ - ៣៥ នាទី*

បែងចែកសិក្ខាកាមទាំងអស់ជា ៣ ទៅ ៤ ក្រុមតូចៗ (ចំនួនក្រុម គឺអាស្រ័យទៅលើចំនួនប្រភេទនៃយន្តការសន្សំប្រាក់ដែលសិក្ខាកាមទាំងអស់នោះបានស្គាល់) :

- ក្រុមទី ១: ពិភាក្សាពីគុណសម្បត្តិ និងគុណវិបត្តិនានា នៃការសន្សំប្រាក់ជាមួយធនាគារណាមួយ (ឧ. ACLEDA) ។
- ក្រុមទី ២ ពិភាក្សាពីគុណសម្បត្តិ និងគុណវិបត្តិនានា នៃការសន្សំប្រាក់ជាមួយស្ថាប័នហិរញ្ញវត្ថុ (ឧ. AMK) ។
- ក្រុមទី ៣ ពិភាក្សាពីគុណសម្បត្តិ និងគុណវិបត្តិនានា នៃការសន្សំប្រាក់ជាមួយក្រុមជួយខ្លួនឯង ។
- ក្រុមទី ៤ ពិភាក្សាពីគុណសម្បត្តិ និងគុណវិបត្តិនានា នៃការសន្សំប្រាក់នៅផ្ទះ ឬជាការទិញរបស់ទ្រព្យ ។

| **សេវាសន្សំប្រាក់** | **គុណសម្បត្តិ** | **គុណវិបត្តិ** | **អាត្រានៃហានិយភ័យ** |
| --- | --- | --- | --- |
| សន្សំជាមួយធនាគារ | | | |
| សន្សំជាមួយស្ថាប័នហិរញ្ញវត្ថុ | | | |
| សន្សំជាមួយក្រុមជួយខ្លួនឯង | | | |
| សន្សំនៅផ្ទះ (ជាសាច់ប្រាក់) | | | |
| សន្សំដោយទិញជារបស់ទ្រព្យ (មាស គ្រឿងអលង្ការ សត្វចិញ្ចឹម ដី) | | | |

នៅពេលការពិភាក្សាតាមក្រុមបានត្រូវបញ្ចប់ហើយ ចូរផ្តល់ពេលវេលាឱ្យក្រុមនីមួយៗចំនួន ២ នាទី ដើម្បីឡើងបង្ហាញគំនិតទាំងឡាយរបស់គេ ។ គ្រូបណ្តុះបណ្តាលអាចបន្ថែមចំណុចមួយចំនួន (សូមមើលក្នុងជំនួយការបណ្តុះបណ្តាលទី ១១) ។

### *ជំហានទី ៣ - ១០ នាទី*

ចូរកំណត់ថា តើសេវាសន្សំប្រាក់ណាមួយ ដែលមានសុវត្ថិភាពជាងគេ ។ សួរសិក្ខាកាម : **តើមានរឿងអាក្រក់អ្វីខ្លះ ដែលអាចកើតឡើងចំពោះប្រាក់សន្សំរបស់អ្នក?** (ប្រាក់សន្សំត្រូវគេលួច ឬបាត់បង់តម្លៃ សមាជិកគ្រួសារផ្សេងទៀតយកទៅប្រើប្រាស់ មិនអាចបើកប្រាក់សន្សំ ដោយសារបញ្ហានៅក្នុងធនាគារ ឬស្ថាប័នហិរញ្ញវត្ថុណាមួយ) ។

ស្នើឱ្យសិក្ខាកាមទាំងអស់សង្កេតមើលប្រភេទសេវាសន្សំប្រាក់ផ្សេងៗ ដែលយើងបានពិភាក្សារួចកន្លងមក ហើយកំណត់រកប្រភេទសន្សំប្រាក់ណាមួយ ដែលមានសុវត្ថិភាពជាងគេ ។ ហេតុអ្វី ? ចូរក្រឡេកទៅមើលតារាងខាងលើ ហើយចង្អុលទៅជួរខាងស្តាំដៃបំផុត ដែលមិនទាន់បានបំពេញ ។ ស្នើឱ្យសិក្ខាកាមពិចារណាសេវានីមួយៗ ហើយផ្តល់ពិន្ទុ ១ , ២ , ឬ ៣ ទៅតាមអាត្រាសុវត្ថិភាព ដែលពួកគេគិត ថាវាអាចកើតមាន ។ "១" សុវត្ថិភាពបំផុត និងមានហានិយភ័យតិចតួច ហើយ "៣" សុវត្ថិភាពនិងមានហានិយភ័យខ្ពស់ ។ ជំរុញឱ្យមានការពិភាក្សាថែមទៀត ប្រសិនបើនៅមើលឃើញថា មិនទាន់មានការព្រមព្រៀងគ្នានៅឡើយទេ ។

### ជំហានទី ៤ - ២០ នាទី

កំណត់កត្តានានា ដែលអាចជះឥទ្ធិពលដល់ជម្រើសនៃសេវាសន្សំប្រាក់របស់យើង ។ សួរសិក្ខាកាម : តើមានកត្តាសំខាន់ៗអ្វីខ្លះ ដែលត្រូវពិចារណា ទាក់ទងនឹងការជ្រើសរើសសេវាសន្សំនានា ?

ជំរុញឱ្យសិក្ខាកាមបញ្ចេញយោបល់ ហើយសរសេរចម្លើយទាំងនោះនៅលើក្ដារខៀន ។ ប្រសិនបើចម្លើយទាំងនោះមិនមានលក្ខណៈដូចខាងក្រោមនេះទេ ចូរសរសេរបន្ថែមចំណុចទាំងនេះទៅក្នុងចម្លើយ ដូចដែលបានកត់ត្រានៅលើក្ដារខៀននោះ ។

**ខ្លឹមសារគន្លឹះសម្រាប់គ្រូបណ្ដុះបណ្ដាល :**

ចំណុចដែលគួរពិចារណា នៅពេលធ្វើការជ្រើសរើសយកសេវាសន្សំប្រាក់ណាមួយ :
- សមស្របទៅតាមលទ្ធភាព
- សេវាងាយស្រួលប្រើប្រាស់
- ចំនួនទឹកប្រាក់ដែលត្រូវផ្ញើដំបូង
- សុវត្ថិភាព
- ការប្រាក់

### ជំហានទី ៥ - ២០ នាទី

ចូរពិភាក្សាលើប្រភេទបញ្ញើប្រាក់ទាំងឡាយ ។ សាកសួរតើមាននរណាម្នាក់បានផ្ញើប្រាក់របស់គេ នៅក្នុងធនាគារ ឬជាមួយស្ថាប័នហិរញ្ញវត្ថុណាមួយទេ? ប្រសិនបើមាន ចូរស្នើឱ្យគាត់ពិពណ៌នាពីជម្រើសផ្សេងៗនៃប្រភេទបញ្ញើប្រាក់ ។ សូមមើលជំនួយការបណ្ដុះបណ្ដាលទី ១២ សម្រាប់ជាឧទាហរណ៍នៃប្រភេទបញ្ញើប្រាក់ជាទូទៅ ដែលបានផ្ដល់ដោយធនាគារ និងស្ថាប័នហិរញ្ញវត្ថុទាំងឡាយ ។

### ជំហានទី ៦ - ២០ នាទី

ការជ្រើសរើសប្រភេទបញ្ញើ ដែលសមស្របទៅនឹងគោលបំណងនានានៃការសន្សំប្រាក់ ។ បែងចែកសិក្ខាកាមជាពីរក្រុម ។ ផ្ដល់ស៊ីណារីយ៉ូពីរដល់ក្រុមនីមួយៗ (មើលជំនួយបណ្ដុះបណ្ដាលទី ១៣) ហើយស្នើឱ្យពួកគេកំណត់រកប្រភេទបញ្ញើណា ដែលសមស្របបំផុតទៅនឹងគោលបំណងរបស់អ្នកសន្សំប្រាក់ ។

**ខ្លឹមសារគន្លឹះសម្រាប់គ្រូបណ្តុះបណ្តាល :**

**ស៊ីណារីយ៉ូទី ១**

ចម្លើយ : **គណនីបញ្ញើមានកាលកំណត់**

**ស៊ីណារីយ៉ូទី ២**

ចម្លើយ : **ប្រភេទគណនីចរន្ត** នឹងអនុញ្ញាតឱ្យនាងសន្សំប្រាក់ចំនួនតិចតួចបាននៅពេលណា ដែលនាងអាចផ្ញើ ហើយនាងអាចដកប្រាក់នៅពេលណាដែលនាងត្រូវការ ។ ដោយសារតែនាងមិនដឹងថា នៅពេលណា ដែលនាងអាចត្រូវការដកប្រាក់នោះសម្រាប់ភាពបន្ទាន់ណាមួយ ដូច្នេះនាងប្រហែលជាមិនចង់ឱ្យពេលដកប្រាក់របស់នាងត្រូវតែកំណត់នោះទេ ដែលបង្ខំឱ្យនាងបង់ប្រាក់ជាបទពិន័យ មុនពេលកិច្ចសន្យារបស់នាងនោះ ។

**ស៊ីណារីយ៉ូទី ៣**

ចម្លើយ : ដោយសារតែនាង **សុខុម** នឹងមិនចំណាយប្រាក់នេះនៅក្នុងអំឡុងពេលពីរឆ្នាំខាងមុខ គណនីបញ្ញើតាមតម្រូវការ នឹងទទួលបានប្រាក់ការខ្ពស់ ហើយជួយឱ្យប្រាក់របស់នាងមានសុវត្ថិភាពពីការប៉ុនប៉ងដើម្បីយកទៅចំណាយផ្សេងៗ ពីព្រោះនាងនឹងត្រូវបង់ប្រាក់ពិន័យ ប្រសិនបើនាងដកប្រាក់មកប្រើប្រាស់មុនពេលកំណត់ ។

**ស៊ុំណារីយ៉ូទី ៤**

ចម្លើយ : **គណនីបញ្ញើសំចៃ**

*ជំហានទី ៧ - ១៥ នាទី*

ស្នើឱ្យសិក្ខាកាមទាំងអស់ក្រឡេកទៅមើលគោលបំណងនានា ដែលគេបានបង្កើតឡើងនៅក្នុង**មេរៀនទី២** ។ ស្នើឱ្យពួកគេគិត **ថាតើប្រភេទបញ្ញើណាមួយ ដែលនឹងជួយឱ្យពួកគេសម្រេចគោលបំណងទាំងនោះបានប្រសើរបំផុត? ហេតុអ្វី?**

ពិភាក្សាជាមួយសិក្ខាកាមអំពីសមាជិកណាខ្លះនៅក្នុងគ្រួសារគេ មានការ**ទទួលខុសត្រូវក្នុងការសន្សំប្រាក់ ហើយនរណាខ្លះមានសិទ្ធិដកប្រាក់សន្សំ ។ តើពួកគេចង់ឱ្យមានគណនីបញ្ញើសំចៃរួមគ្នាមួយនៅក្នុងគ្រួសារ ឬឱ្យមានរៀងខ្លួនសម្រាប់ស្វាមី និងភរិយា** ? ចូរពន្យល់ថា នៅស្ថាប័នហិរញ្ញវត្ថុមួយចំនួន ពួកគេអាចបើកគណនីបញ្ញើសំចៃសម្រាប់ទាំងកូនៗទៀតផង ។ នេះគឺអាចជួយឱ្យកុមាររៀនសន្សំប្រាក់ ចាប់តាំងពីពួកគេនៅវ័យកុមារភាព ហើយជួយឱ្យពួកគេរីករាយនឹងផលកម្រៃនានានៅក្នុងជីវិតជាបន្តបន្ទាប់ ។

## ជំហានទី ៩ - ១០ នាទី

រំលឹកឡើងវិញលើអ្វី ដែលយើងបានពិភាក្សា និងរកឃើញនៅក្នុងមេរៀននេះ ។
តើអ្នកបានរៀនសូត្រអ្វីខ្លះពីមេរៀននេះ ?

- តើអ្នករកឃើញអ្វីខ្លះដែលជាការចាប់អារម្មណ៍ និងមានផលប្រយោជន៍សម្រាប់ការគ្រប់គ្រងកិច្ចការហិរញ្ញវត្ថុរបស់អ្នក ?
- តើអ្នកនឹងយកចំណុចអ្វីខ្លះ ទៅអនុវត្តជាក់ស្តែង ?

សង្ខេបចំណុចសំខាន់ៗ :

- **វិធីសន្សំប្រាក់** : ជាមួយធនាគារ ស្ថាប័នហិរញ្ញវត្ថុ ក្រុមជួយខ្លួនឯង នៅផ្ទះ ឬការទិញទ្រព្យសម្បត្តិ ឬជាសត្វចិញ្ចឹម ។
- **គុណសម្បត្តិ និងគុណវិបត្តិ**នៃសេវាសន្សំប្រាក់នីមួយៗ
- ចំណុចដែលគួរពិចារណា នៅពេល**ជ្រើសរើសសេវាសន្សំប្រាក់**
- **ប្រភេទបញ្ញើប្រាក់** ដែលសមស្របទៅតាមគោលបំណងនៃការសន្សំប្រាក់ ។

## ជំនួយការបណ្តុះបណ្តាលទី ១១ : គុណសម្បត្តិ និងគុណវិបត្តិនៃប្រភេទសេវាសន្សំប្រាក់

| សេវាសន្សំប្រាក់ | គុណសម្បត្តិ | គុណវិបត្តិ | អាត្រា ហានិភ័យ |
|---|---|---|---|
| **ធនាគារ ឬ ស្ថាប័នហិរញ្ញវត្ថុ** | - មានសុវត្ថិភាពជាងគេ<br>- មានការប៉ុនប៉ងតិចតួចក្នុងការដកនិងចំណាយប្រាក់<br>- ចំណេញប្រាក់ការ<br>- ទទួលបានប្រភេទបញ្ញើច្រើនយ៉ាង (គណនីបញ្ញើសំចៃ គណនីបញ្ញើមានកាលកំណត់ ។ល។)<br>- ជួយក្នុងការគ្រប់គ្រងប្រាក់ | - ការប្រាក់ទាប<br>- តម្រូវឱ្យមានចំនួនប្រាក់ដាក់ផ្ញើជាអប្បបរិមា ដើម្បីបើកគណនីមួយ អាចជាឧបសគ្គ<br>- អាចតម្រូវឱ្យបង់ថ្លៃសេវាផ្សេងៗ<br>- មានការរង់ចាំ និងមានការយឺតយូរនៅក្នុងធនាគារ<br>- អ្នកដែលមិនអាចអាននិងសរសេរអក្សរបាន នឹងមិនអាចទទួលយកសេវានេះបាន | |
| **ក្រុមជួយខ្លួនឯង** | - ងាយស្រួលទទួលបានសេវា<br>- ការសន្សំជារឿយៗត្រូវភ្ជាប់ ទៅនឹងឥណទាន<br>- អាចទទួលបានប្រាក់ចំណេញនៅលើប្រាក់កម្ចីនានា ដែលបានផ្តល់ឱ្យពីប្រាក់សន្សំ<br>- ច្បាប់របស់ក្រុមស្តីអំពីចំនួនដងនៃការសន្សំនិងចំនួនប្រាក់សន្សំ អាចជួយឱ្យមានទម្លាប់សន្សំសំចៃ | សុវត្ថិភាព គឺអាស្រ័យលើក្រុម | |

| | | | |
|---|---|---|---|
| **សន្សំនៅផ្ទះ (ជាសាច់ប្រាក់)** | - ងាយស្រួល | - មិនមានសុវត្ថិភាព<br>- ងាយស្រួលបំផុតក្នុងការដក ចាយ និងខ្ជះខ្ជាយទៅលើមុខទំនិញមិនចាំបាច់ | |
| **សន្សំជាការទិញសម្បត្តិទ្រព្យ (មាស អលង្ការ សត្វចិញ្ចឹម ដី)** | - តម្លៃអាចកើនឡើងនៅពេលណាមួយខាងមុខ<br>- ត្រូវតែលក់នៅពេលត្រូវការសាច់ប្រាក់<br>- កាត់បន្ថយការប៉ុនប៉ងចំណាយ | - ពិបាកលក់ចេញនៅពេលមានភាពបន្ទាន់ណាមួយ<br>- តម្លៃអាចធ្លាក់ចុះនៅពេលណាមួយខាងមុខ<br>- ប្រឈមប្រថានទៅនឹងចោរកម្ម ឬស្លាប់ (ក្នុងករណីសត្វចិញ្ចឹម) | |

## ជំនួយការបណ្តុះបណ្តាលទី ១២ : ប្រភេទបញ្ញើប្រាក់នៅស្ថាប័នផ្តល់ការ

| ប្រភេទបញ្ញើប្រាក់ | ល័ក្ខខ័ណ្ឌបញ្ញើ | គោលបំណងបញ្ញើ |
|---|---|---|
| គណនីបញ្ញើសំចៃ (គណនីចរន្ត) (Savings Passbook, or Savings Account) | - មិនកំណត់ពេលវេលា និងចំនួនទឹកប្រាក់<br>- ការដកប្រាក់ ធ្វើនៅពេលណាក៏បាន (បើទោះបីនៅពេលខ្លះ អតិថិជនត្រូវផ្តល់ដំណឹងអំពីការស្នើសុំដកប្រាក់ក្នុងរយៈពេល ៣ ឬ ៤ថ្ងៃជាមុនក៏ដោយ)<br>- ជាធម្មតាអាច បានទទួលបានប្រាក់ការ | នៅពេលមានភាពបន្ទាន់នានា និងនៅពេលមានឱកាសផ្សេងៗដែលមិនបានគ្រោងទុក |
| គណនីបញ្ញើមានកាលកំណត់ (Fixed-term account) | - ប្រាក់បញ្ញើមានចំនួនកំណត់សំរាប់រយៈពេលជាក់លាក់ដែលបានកំណត់ជាមុន ។ អតិថិជនអាចសម្រេចទៅលើចំនួនប៉ុន្មាន ដែលត្រូវសន្សំ សម្រាប់រយៈពេលប៉ុណ្ណា ។<br>- មិនអាចដកប្រាក់សន្សំមកវិញបាន រហូតទាល់តែបានបំពេញតាមកិច្ចសន្យា<br>- ដកប្រាក់មុនកិច្ចសន្យា នឹងត្រូវផាកពិន័យជាប្រាក់ការពីអតិថិជន<br>- ប្រាក់ការជាធម្មតាមានអាត្រាខ្ពស់ជាងប្រភេទគណនីបញ្ញើសំចៃ<br>- អាចខ្ចីពីប្រាក់សន្សំរបស់អ្នក | សម្រាប់សេចក្តីត្រូវដែលបានគ្រោងទុក |
| គណនីបញ្ញើតាមតម្រូវការ (Time Deposit) | - ចំនួនប្រាក់បញ្ញើសរុប និងប្រាក់ការមានកំណត់ទុកជាមុនសម្រាប់អំឡុងពេលណាមួយ<br>- តម្រូវឱ្យមានចំនួនប្រាក់បញ្ញើអប្បបរិមា<br>- មិនអាចបត់បែនបាន<br>- បានទទួលប្រាក់ការខ្ពស់ជាងប្រភេទបញ្ញើគណនីមានកាលកំណត់ឬគណនីបញ្ញើសំចៃសម្រាប់ចំនួនប្រាក់ស្មើគ្នា | សម្រាប់សេចក្តីត្រូវការធំៗដែលបានគ្រោងទុកនៅពេលអនាគត ដូចជាពិធីអាពាហ៍ពិពាហ៍ ឬជាដើមទុនធំមួយ |

## ជំនួយការបណ្តុះបណ្តាលទី ១៣ : ការផ្គូផ្គងគោលបំណងសន្សំប្រាក់ជាមួយប្រភេទបញ្ញើប្រាក់

### ស៊ីណារីយ៉ូទី ១

**ដាណែត** ចង់សន្សំប្រាក់ ដើម្បីពិធីអាពាហ៍ពិពាហ៍របស់នាងនៅឆ្នាំក្រោយ ។ នៅពេលនេះ នាងស្ទើរតែគ្មានប្រាក់សន្សំសោះ ប៉ុន្តែប្រសិនបើនាងសន្សំ ៦០០០០រៀលរៀងរាល់ខែ ក្នុងរយៈពេលមួយឆ្នាំ នាងនឹងមានប្រាក់គ្រប់គ្រាន់ល្មម សម្រាប់ពិធីអាពាហ៍ពិពាហ៍របស់នាង ។ នាងមិនចង់យកប្រាក់សន្សំនេះ ដើម្បីទៅធ្វើអ្វីផ្សេងពីនេះឡើយ ។

### ស៊ីណារីយ៉ូទី ២

**សុភា** ទើបតែបានបញ្ចប់ការសិក្សាមេរៀនមួយស្តីអំពីការសន្សំប្រាក់សម្រាប់ពេលមានភាពបន្ទាន់ ។ នៅពេលនេះ នាងបានកំណត់ក្នុងចិត្តថា នឹងសន្សំប្រាក់ជារៀងរាល់ខែ បើទោះបីនាងអាចលៃលកសន្សំ ប្រាក់បានដ៏តិចតួចក្តី ។ នៅពេលនេះ នាងមិនដឹងថា តើនាងអាចនឹងប្រើប្រាស់ប្រាក់សន្សំនោះដើម្បីអ្វីទេ ប៉ុន្តែគ្រាន់តែនាងមិនចង់ឱ្យមានជម្ងឺដង្កាត់ ឬគ្រោះថ្នាក់ផ្សេងៗ ដែលមិនអាចគ្រោងទុកបានមកប៉ះពាល់ ទ្រព្យធនក្រុមគ្រួសាររបស់នាង ។

### ស៊ីណារីយ៉ូទី ៣

**មីង សុខុម** ទើបតែបានទទួលប្រាក់ចំនួន ៦០០០០០ រៀល ពីកូនប្រុសរបស់គាត់ ដែលបានកំពុងធ្វើការនៅភ្នំពេញ ។ គាត់អាចចំណាយប្រាក់នេះទៅលើមុខចំណាយសំខាន់ៗមួយចំនួន ប៉ុន្តែគាត់ចង់សន្សំវាសម្រាប់ការសិក្សារបស់កូនស្រីគាត់នៅមហាវិទ្យាល័យ ។ បើទោះបីកូនស្រីរបស់គាត់ នឹងមិនទៅសិក្សានៅមហាវិទ្យាល័យក្នុងអំឡុងពេលពីរឆ្នាំខាងមុខទៀតក្តី តែគាត់ដឹងថា នាងនឹងត្រូវការប្រាក់ជាច្រើន ។

### ស៊ីណារីយ៉ូទី ៤

**ចិន្តា**ត្រូវការទីកន្លែងមួយ ដើម្បីសន្សំប្រាក់មួយចំណែក ដែលបានពីការលក់ផ្លែឈើរបស់នាង ។ នាងត្រូវការសន្សំ ដើម្បីឱ្យនាងអាចពង្រីកអាជីវកម្មរបស់នាង នៅក្នុងពេលដ៏ខ្លីខាងមុខបាន ។ នាងចង់សន្សំប្រាក់រៀងរាល់សប្តាហ៍ ហើយដកចំនួនប្រាក់ដែលត្រូវការនៅរៀងរាល់ខែ ដើម្បីយកទៅទិញផ្លែឈើផ្សេងៗ ថែមទៀត ។

## ជំនួយការបណ្តុះបណ្តាលទី ១៤ : ការពិភាក្សាជ្រើសរើសសេវាសន្សំប្រាក់



# មេរៀនទី ៧ : ការរៀបចំគំរោងថវិកាសម្រាប់គ្រួសារ



កំណត់ចំណាំរបស់គ្រូបណ្តុះបណ្តាល

## គោលបំណង

នៅចុងបញ្ចប់មេរៀននេះ សិក្ខាកាមទាំងអស់នឹងបាន :

- កំណត់ពីសារៈសំខាន់របស់គំរោងថវិកា
- ពិពណ៌នាបានពីជំហាននានា។ ដើម្បីបង្កើតគំរោងថវិកា
- ទទួលដំបូន្មានអំពីវិធីនានា ដើម្បីប្រកាន់ខ្ជាប់ទៅតាមគំរោងថវិកា
- កំណត់រកវិធីផ្សេងៗ ដើម្បីលើកកំពស់ការគ្រប់គ្រងប្រាក់កាស តាមរយៈការរៀបចំគំរោងថវិកា

## ប្លង់វគ្គសិក្សា (១៦០ នាទី)

### ជំហានទី ១ - ១៥ នាទី

ចូរពន្យល់អត្ថន័យអំពីអ្វីទៅដែលហៅថាគំរោងថវិកា : គំរោងថវិកា គឺជាផែនការមួយ ដែលលាតត្រដាងពីអ្វីដែលអ្នកបំរុងធ្វើជាមួយនឹងប្រាក់កាសរបស់អ្នក ។ គំរោងថវិកាល្អ គឺជួយឱ្យអ្នកធ្វើការចំណាយទៅលើ អ្វីដែលអ្នកត្រូវការ និងសន្សំប្រាក់ទៅតាមចំនួន ដែលអ្នកចង់បានក្នុងជីវិត ។

សួរសិក្ខាកាម : **តើអ្នកធ្លាប់បានរៀបចំ ថវិកាដែរឬទេ** ? ប្រសិនបើធ្លាប់ ចូរស្នើឱ្យពួកគេចែករំលែក អំពីបទពិសោធន៍អំពីរបៀបដែលគេរៀបគំរោងចំថវិការបស់គេ ដល់សិក្ខាកាមដទៃទៀត ។ ស្នើឱ្យសិក្ខាកាមម្នាក់ ឬពីរនាក់ ឡើងសរសេរនៅលើក្តារខៀន (ប្រសិនបើគេអាចសរសេរបាន) ឬពិពណ៌នា (ប្រសិនបើគេមិនអាចសរសេរបាន) ចូរធ្វើឱ្យប្រាកដប្រជាថា គំរោងថវិកាមានប្រភេទចំណាយ និងប្រភពចំណូលផ្សេងៗគ្នា ។

### ជំហានទី ២ - ៣៥ នាទី

ស្នើឱ្យសិក្ខាកាមទាំងអស់នឹកស្រមៃគិតថា កូនស្រីរបស់គេនឹងរៀបអាពាហ៍ពិពាហ៍នៅខែក្រោយ ដូច្នេះពួកគេត្រូវគ្រោងថវិកាមួយនៅពេលនេះ ដើម្បីរៀបចំពិធីមង្គលការរបស់នាង ។

បែងចែកសិក្ខាកាមជា ៣ ឬ៤ក្រុម ។ ពិភាក្សា : **តើអ្នកត្រូវការព័ត៌មានអ្វីខ្លះ ដើម្បីរៀបចំគំរោងថវិកានេះ?** គ្រូបណ្តុះបណ្តាលអាចផ្តល់ការជួយគាំទ្រខ្លះៗ នៅពេលចាំបាច់ ។

ផ្តល់ពេលវេលាឱ្យក្រុមនីមួយៗចំនួន ៥ នាទីដើម្បីរៀបចំគំរោងថវិកានេះ និង ២នាទីទៀត ដើម្បីបង្ហាញគំរោងថវិកានេះដល់សិក្ខាកាមក្នុងក្រុមឯទៀត ។

### ជំហ៊ានទី ៣ - ២៥ នាទី

ស្នើឱ្យសិក្ខាកាមទាំងឡាយពិនិត្យមើលគំរោងថវិការបស់គេ ។ ចូរសួរសំណួរដូចខាងក្រោមនេះ ៖

- តើអ្នកបានរៀបចំគំរោងថវិកានេះទៅតាមជំហ៊ានអ្វីខ្លះ ?
- តើគំរោងថវិកាណាមួយ ដែលបានដាក់បញ្ចូលប្រភពទាំងអស់នៃប្រាក់ចំណូល (អំណោយពីភ្ញៀវ បងប្អូន សមាជិកគ្រួសារ ឬពីមិត្តភក្តិ ។ល។)
- តើគំរោងថវិការបស់ក្រុមមួយណា ដែលបានប៉ាន់ស្មានប្រាក់ចំណូល មានលក្ខណៈប្រាកដប្រជា ?
- តើគំរោងថវិការបស់ក្រុមមួយណា ដែលបានកំណត់ប្រភេទចំណាយផ្សេងៗទាំងអស់ និងប៉ាន់ស្មានចំនួនពិតប្រាកដសម្រាប់រាល់ចំណាយទាំងអស់ ?
- តើគំរោងថវិកាមួយណាដែលមានសមតុល្យល្អ រវាងចំណូលនិងចំណាយ ?
- ប្រសិនបើអ្នករៀបចំថវិកានេះម្តងទៀត តើអ្នកនឹងធ្វើអ្វីខ្លះឱ្យខុសពីមុន ?

**ខ្លឹមសារគន្លឹះសម្រាប់គ្រូបណ្តុះបណ្តាល ៖**

ជំហ៊ាននានាសំរាប់រៀបចំគំរោងថវិកា
១. ពិនិត្យឡើងវិញលើគោលបំណងថវិការបស់អ្នក
២. ប៉ាន់ស្មានចំនួនប្រាក់ចំណូលពីប្រភពនីមួយៗ
៣. កត់ត្រាចំណាយនានា និងចំនួនប្រាក់ដែលត្រូវការ
៤. ធ្វើឱ្យប្រាកដប្រជាថា ចំណាយទាំងឡាយរបស់អ្នក នឹងមិនលើសពីចំណូលរបស់អ្នក
៥. សម្រេចទៅលើចំនួនប៉ុន្មាន ដែលអ្នកនឹងសន្សំទុក
៦. ពិនិត្យឡើងវិញ និងធ្វើការកែតម្រូវបើចាំបាច់

### ជំហ៊ានទី ៤ - ៥០ នាទី

នៅពេលនេះ អ្នកនឹងអនុវត្តជាក់ស្តែង ក្នុងការរៀបចំគំរោងថវិកាសម្រាប់គ្រួសាររបស់អ្នក។ ស្នើឱ្យសិក្ខាកាមធ្វើការជាដៃគូ ដើម្បីរៀបចំគំរោងថវិកាមួយសំរាប់រយៈពេល ៦ខែ សម្រាប់គ្រួសាររបស់ពួកគេ ។

ចែកជំនួយការបណ្តុះបណ្តាលទី ១៦ និងទី១៧ និងពន្យល់ពីវិធីប្រើប្រាស់វា ។

**ចំណូល**

១. នៅក្នុងតារាងថវិកា ចូរបញ្ជាក់ពីប្រភពផ្សេងៗនៃប្រាក់ចំណូលគ្រួសាររបស់អ្នក ហើយកត់ត្រាវាទៅក្នុងជួរទីមួយនៅក្រោម " ប្រាក់ចំណូល " ។ ក្នុងចំណោមប្រភពចំណូលទាំងនេះ ភាគខ្លះអាចផ្តល់ប្រាក់ចំណូលរៀងរាល់ខែ រៀងរាល់ថ្ងៃ ឬរៀងរាល់សប្តាហ៍ ហើយប្រភពខ្លះទៀត អាចផ្តល់ប្រាក់ចំណូល តែនៅក្នុងអំឡុងពេលជាក់លាក់ណាមួយប៉ុណ្ណោះនៃឆ្នាំ ។

២. ប៉ាន់ប្រមាណប្រាក់ចំណូលប្រចាំខែសម្រាប់ប្រភពនីមួយៗ ហើយកត់ត្រាវាទៅក្នុង ជួរផ្សេងៗ នៅក្នុងតារាង ។ ប្រាក់ចំណូលមួយចំនួនរបស់អ្នក អាចបានមកម្តងម្កាល តែមានចំនួនច្រើន។ ដើម្បីគណនាប្រាក់ចំណូលមិនប្រក្រតីនេះជារៀងរាល់ខែ ចូរកំណត់ថាតើចំនួនប្រាក់ចំណូលមិនប្រក្រតី ដែលអ្នកទទួលប្រចាំឆ្នាំនោះមានចំនួនប៉ុន្មាន ហើយចែកចំនួននោះនឹងចំនួន ១២ ខែ ( សូមមើលជំនួយបណ្តុះបណ្តាល ទី ១៧) ។ បញ្ចូលចំនួនប្រាក់ចំណូលមិនប្រក្រតីប្រចាំខែ ដែលអ្នកបានគណនានោះទៅក្នុងតារាងថវិកា ។

**ចំណាយ**

១. កត់ត្រាចំណាយទាំងឡាយរបស់អ្នកសម្រាប់ប្រភេទចំណាយនីមួយៗ : ការសងបំណុល ចំណាយលើវត្ថុចាំបាច់ ចំណាយលើវត្ថុដែលមិនសូវចាំបាច់ ចំណាយនៅពេលមានភាពបន្ទាន់នានាជាដើម ។ល។

២. ប៉ាន់ស្មានចំណាយរបស់អ្នក សម្រាប់ប្រភេទចំណាយនីមួយៗក្នុងខែនីមួយៗ ។ អ្នកអាចបង់លើមុខចំណាយមួយចំនួនសម្រាប់ពេលតែម្តងក្នុងមួយឆ្នាំ ឬសម្រាប់រៀងរាល់បីខែម្តង ។ ប្រសិនបើអ្នកមានមុខចំណាយមិនប្រក្រតី វាមានប្រយោជន៍ណាស់ ក្នុងការបំបែកវាទៅតាមខែទាំងឡាយ នៅក្នុងតារាងថវិការបស់អ្នក ។ ដើម្បីរកប្រាក់ចំណាយមិនប្រក្រតីនេះជារៀងរាល់ខែ ចូរគណនាចំនួនប្រាក់ចំណាយមិនប្រក្រតីសរុបក្នុងមួយឆ្នាំ ហើយចែកចំនួននោះនឹងចំនួន ១២ ខែ ( សូមមើលជំនួយការបណ្តុះបណ្តាលទី ១៧) ។

***ជំហានទី ៥ - ២៥នាទី***

នៅពេលបញ្ចប់ការគណនានេះរួចហើយ ស្នើឱ្យដៃគូពីរឬបី ចែករំលែកលទ្ធផលនានាជាមួយក្រុមធំ ហើយជំរុញឱ្យពីសិក្ខាកាមដទៃទៀត ផ្តល់យោបល់ទៅលើតំរោងថវិកាដែលបានបង្ហាញនោះ ។ ចូរធ្វើឱ្យប្រាកដប្រជាថា សិក្ខាកាមទាំងឡាយបានបញ្ចូលប្រភពចំណូលទាំងអស់ទៅក្នុងតារាងថវិកា ហើយតារាងនេះមានសមតុល្យល្អរវាងប្រាក់ចំណូល និងប្រាក់ចំណាយ និងមានប្រាក់សន្សំមួយចំនួនផងដែរ ។

ពិភាក្សាសំណួរដូចខាងក្រោម :

- តើអ្នកបានប៉ាន់ស្មានប្រាក់ចំណូលដោយវិធីណា ?
- តើអ្នកបានប៉ាន់ស្មានប្រាក់ចំណាយដោយវិធីណា ?
- តើអ្នកមានអារម្មណ៍យ៉ាងណា នៅពេលអ្នករៀបចំថវិកានេះ ?
- តើការរៀបចំថវិកានេះ មានផលប្រយោជន៍អ្វីខ្លះ ?

## ជំហានទី ៦ - ១០ នាទី

រៀបរាប់ពីផលប្រយោជន៍នានានៃគំរោងថវិកា :

- ងាយស្រួលធ្វើសេចក្តីសម្រេចលើការចំណាយ និងការសន្សំ
- ជួយឱ្យមានការប្រុងប្រយ័ត្ននៅពេលធ្វើការចំណាយ
- ជួយឱ្យមានទំលាប់ល្អក្នុងការសន្សំប្រាក់
- ប្រសិនបើបានគោរពទៅតាមបន្ទាត់ថវិកា វាជួយឱ្យអ្នកសម្រេចបានគោលបំណងហិរញ្ញវត្ថុ
- ជួយអ្នកឱ្យគ្រប់គ្រងប្រាក់កាសរបស់អ្នកបាន

រំលឹកឡើងវិញលើអ្វី ដែលយើងបានពិភាក្សា និងស្វែងរកនៅក្នុងមេរៀននេះ :

- តើអ្នកបានរៀនសូត្រអ្វីខ្លះពីមេរៀននេះ ?
- តើអ្នករកឃើញអ្វីខ្លះ ដែលគួរឱ្យចាប់អារម្មណ៍ និងមានផលប្រយោជន៍សម្រាប់ការគ្រប់គ្រងកិច្ចការហិរញ្ញវត្ថុរបស់អ្នក ?
- តើអ្នកនឹងយកចំណុចអ្វីខ្លះ ទៅអនុវត្តជាក់ស្តែង ?

### សង្ខេបចំណុចសំខាន់ៗ :

- ជំហាននានាដើម្បីរៀបចំគំរោងថវិកា
- របៀបរៀបចំគំរោងថវិកា
- វិធីប៉ាន់ស្មានប្រាក់ចំណូល និងប្រាក់ចំណាយ
- សារៈសំខាន់នៃការគ្រោងថវិកា

## ជំនួយការបណ្តុះបណ្តាលទី ១៥ : ជំហ៊ាននានាដើម្បីរៀបចំគំរោងថវិកា

ពិនិត្យគោលបំណងហិរញ្ញវត្ថុរបស់អ្នក

↓

ប៉ាន់ស្មានចំនួនថវិកាចំណូលទៅតាមប្រភពនីមួយ

↓

កត់ត្រាចំណាយនានានិងចំនួនប្រាក់ដែលត្រូវការ

↓

ធ្វើឱ្យប្រាកដថាចំណាយមិនលើសចំណូលរបស់អ្នក

↓

សម្រេចទៅលើចំនួនប៉ុន្មានដែលអ្នកនឹងសន្សំទុក

↓

ពិនិត្យឡើងវិញនិងធ្វើការកែតម្រូវបើចាំបាច់

## ជំនួយការបណ្តុះបណ្តាលទី ១៦ : គំរោងថវិកាគ្រួសារខ្ញុំ

**គំរោងថវិកាគ្រួសារខ្ញុំ**
**ថ្ងៃទី ១ ខែមករា ដល់ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ២០០៩**

| | មករា | កុម្ភៈ | មិនា | មេសា | ឧសភា | មិថុនា |
|---|---|---|---|---|---|---|
| **ប្រាក់ចំណូល** | | | | | | |
| ប្រាក់ខែ ... | | | | | | |
| អាជីវកម្ម ..... | | | | | | |
| លក់បន្លែនិងផ្លែឈើដាំនៅក្នុងផ្ទះ | | | | | | |
| លក់មាន់ ជ្រូក (ចិញ្ចឹម) | | | | | | |
| ចំណូលផ្សេងៗ | | | | | | |
| | | | | | | |
| **សរុបប្រាក់ចំណូល** | | | | | | |
| **ប្រាក់ចំណាយ** | | | | | | |
| ចំណាយលើការប្រើប្រាស់ចាំបាច់ក្នុងគ្រួសារ | | | | | | |
| អាហារ | | | | | | |
| ការសិក្សា | | | | | | |
| សុខភាព | | | | | | |
| ផ្ទះសម្បែង | | | | | | |
| សំលៀកបំពាក់ | | | | | | |
| ចំណាយលើកិច្ចការអាជីវកម្ម : | | | | | | |
| | | | | | | |
| ចំណាយពេលមានភាពបន្ទាន់ | | | | | | |
| ចំណាយផ្សេងៗ | | | | | | |
| | | | | | | |
| **សរុបប្រាក់ចំណាយ** | | | | | | |
| ប្រាក់សន្សំ | | | | | | |

# ជំនួយការបណ្តុះបណ្តាលទី ១៧ : តារាងប្រាក់ចំណូលនិងចំណាយមិនប្រក្រតី : ការប៉ាន់ប្រមាណប្រចាំខែ

## ប្រាក់ចំណូលមិនប្រក្រតី

| ប្រាក់ចំណូល | ចំនួនដងដែលបានទទួល | ចំនួនប្រាក់ចំណូល | ចំនួនប្រាក់ចំណូលប្រចាំឆ្នាំ | ប្រាក់ចំណូលប្រចាំខែ ( ប្រាក់ប្រចាំឆ្នាំចែកនឹង១២) |
|---|---|---|---|---|
| | | | | |
| | | | | |
| | | | | |

## ចំណាយមិនប្រក្រតី

| ប្រាក់ចំណាយ | ចំនួនដងដែលបានចំណាយ | ចំនួនប្រាក់ចំណាយ១ដង | ចំនួនប្រាក់ចំណាយប្រចាំឆ្នាំ | ប្រាក់ចំណាយប្រចាំខែ ( ចំណាយប្រចាំឆ្នាំចែកនឹង១២) |
|---|---|---|---|---|
| | | | | |
| | | | | |
| | | | | |

## ជំនួយការបណ្តុះបណ្តាលទី ១៨ : គំរោងថវិកាគ្រួសារខ្ញុំ



# មេរៀនទី ៨ : ការអនុវត្តទៅតាមគំរោងថវិការបស់អ្នក




កំណត់ចំណាំរបស់គ្រូបណ្តុះបណ្តាល

## គោលបំណង

នៅចុងបញ្ចប់មេរៀននេះ សិក្ខាកាមទាំងអស់នឹងបាន :

- កំណត់រកវិធីនានា ដើម្បីដោះស្រាយការលំបាកទាំងឡាយ ដែលត្រូវធ្វើឱ្យស្របទៅតាមគំរោងថវិកា
- អនុវត្តជាក់ស្តែងក្នុងការកំណត់រកវិធីនានាដើម្បីកាត់បន្ថយចំណាយ ដោយការផ្តល់អាទិភាពលើចំណាយ

## ប្លង់វគ្គសិក្សា (១២៥ នាទី)

## ជំហ៊ានទី ១ - ៣០ នាទី

ស្នើឱ្យសិក្ខាកាមទាំងអស់ ធ្វើបញ្ជីចំណាយនានាប្រចាំថ្ងៃ ។ ផ្តល់ពេលវេលាពីរនាទីដល់ពួកគេ ដើម្បីធ្វើកិច្ចការនេះ ។ នៅពេលបញ្ចប់ការចុះបញ្ជីចំណាយនេះ ស្នើឱ្យសិក្ខាកាមម្នាក់ ដែលមានបញ្ជីចំណាយនេះ វែងជាងគេ និងសិក្ខាកាមម្នាក់ទៀតដែលមានបញ្ជីចំណាយខ្លីជាងគេ ឡើងមកចែករំលែកលទ្ធផលដល់ក្រុម ។ **ពិភាក្សា: បញ្ជីចំណាយទាំង២នេះខុសគ្នាយ៉ាងខ្លាំង តើដោយសារមូលហេតុអ្វី** ?

ប្រសិនបើអ្នកចាំបាច់ត្រូវអនុវត្តទៅតាមគំរោងថវិការបស់អ្នក តើអ្នកអាចធ្វើអ្វីខ្លះជាមួយនឹងចំណាយប្រចាំថ្ងៃទាំងឡាយនោះ ?

ស្នើឱ្យពួកគេចាត់អាទិភាពលើចំណាយទាំងឡាយរបស់ពួកគេ : **កំណត់រកចំណាយជាអាទិភាពសំខាន់ៗ ៣ ឬ៤** ។

**ខ្លឹមសារគន្លឹះសម្រាប់គ្រូបណ្តុះបណ្តាល :**

វិធីនានាដើម្បីកាត់បន្ថយចំណាយ :

- កាត់បន្ថយការប្រើប្រាស់លើវត្ថុមិនចាំបាច់ ( អាហារសម្រន់)
- ចំណាយតិចតួចលើពិធីជប់លៀង និងពិធីបុណ្យផ្សេងៗ
- ចំណាយតិចតួចលើព្រឹត្តិការណ៍ផ្សេងៗប្រចាំជីវិត ដូចជា ពិធីមង្គលការ និងបុណ្យកំណើត

- សន្សំឱ្យបានគ្រប់គ្រាន់ដើម្បីទិញវត្ថុចាំបាច់ទាំងឡាយដោយចំនួនច្រើន នៅពេលតម្លៃរបស់វាចុះថោក ។
- ធ្វើផែនការជាមុន ដើម្បីទិញវត្ថុចាំបាច់នានា នៅពេលតម្លៃរបស់វាចុះថោក
- បន្ថយការទិញជឿឬបណ្តាក់
- ទុកប្រាក់នៅនឹងខ្លួនតិចតួច ឬសន្សំវានៅកន្លែងសុវត្ថិភាព ដូច្នេះវានឹងមិនមានការប៉ុនប៉ងចំណាយប្រាក់នោះឡើយ

ពិភាក្សាសំណួរដូចខាងក្រោមនេះ :

១. **តើមានសម្ពាធអ្វីខ្លះពីមួយថ្ងៃទៅមួយថ្ងៃ ដែលបណ្តាលឱ្យមានការលំបាកដល់ការអនុវត្តទៅតាមអាទិភាពចំណាយនានាដូចដែលបានស្នើឡើង** ? (ឧ. ប្រាក់ចំណូលអាចទូទាត់បានតែវត្ថុចាំបាច់ភាគ ច្រើនប៉ុណ្ណោះ ហើយមិនមានប្រាក់សល់សម្រាប់ទូទាត់បំណុល ឬសម្រាប់សន្សំឡើយ សម្ពាធរបស់ស្វាមី បណ្តាលឱ្យមានការចំណាយលើសពីអ្វីដែលបានគ្រោងទុក ។
២. **តើការអនុវត្តទៅតាមគំរោងថវិកា មានការលំបាកអ្វីខ្លះ** ?

### *ជំហានទី ២ - ២៥ នាទី*

បែងចែកសិក្ខាកាមជាបួនក្រុម ដែលក្រុមនីមួយៗមានសមាជិកបួននាក់ ។ ក្រុមនីមួយៗជ្រើសរើសយកការលំបាកចំនួនពីរ (**លទ្ធផលក្នុងជំហានទី ១**) ហើយស្វែងរកដំណោះស្រាយនានា ដែលអាចមាន និងអាចយកទៅអនុវត្តបាន ។

ផ្តល់ពេលវេលាដល់ក្រុមនីមួយៗចំនួនពីរនាទី ដើម្បីឡើងបង្ហាញគំនិតទាំងឡាយរបស់គេ ។ ចូរធ្វើឱ្យប្រាកដប្រជាថា គំនិតទាំងនោះនឹងមានអត្ថន័យខុសៗគ្នា ហើយពិភាក្សានៅលើដំណោះស្រាយណា ដែលមិនទំនងជាអាចយកទៅអនុវត្តបាន។ កត់ត្រាវិធីនានាដើម្បីជួយឱ្យមានការអនុវត្តទៅតាមគំរោងថវិកា ។

### *ជំហានទី ៣ - ៣០ នាទី*

ស្នើសិក្ខាកាមទាំងអស់ឱ្យផ្តង់អារម្មណ៍ស្តាប់រឿងពីរលោតរបស់ នារី និង ចន្ថា (មើលជំនួយការបណ្តុះបណ្តាលទី ១៩) ។ អ្នកអាចស្នើឱ្យសិក្ខាកាមពីរនាក់អានអត្ថបទរឿងនោះ ។ នៅចុងបញ្ចប់ដំណាលរឿង នីមួយៗ ពិភាក្សាថា តើ នារី ឬ ចន្ថា ចាត់ចែងដោយវិធីណាខ្លះ ដើម្បីឱ្យនាងអាចអនុវត្តទៅតាមគំរោងថវិការបស់គាត់ ។

**តើនារីបានធ្វើអ្វីខ្លះ ដើម្បីឱ្យនាងអាចអនុវត្តទៅតាមគំរោងថវិការបស់នាង** ? (ចងចាំពីអ្វីដែលបានគ្រោងទុកនៅក្នុងថវិការបស់នាង និងអនុវត្តទៅតាមផែនការរបស់នាង ដាក់ប្រាក់សន្សំឱ្យផុតពីភាពងាយដកយកមកប្រើវិញបាន ដូច្នេះវាមិនងាយស្រួលធ្លាក់ទៅលើការចំណាយផ្សេងៗ ដកប្រាក់មួយចំនួនទុកសម្រាប់ការចំណាយផ្សេងៗ ដែលមិនបានគ្រោងទុក ) ។

តើនាង**ចន្ធា** បានធ្វើអ្វីខ្លះ ដើម្បីឱ្យនាងអាចអនុវត្តទៅតាមគំរោងថវិការបស់នាង ? (នាងបានតាមដានការចំណាយរបស់នាង ដូច្នេះនាងមិនបានចំណាយលើសពីថវិកាដែលគ្រោងទុក ។ នៅពេលនាងបានចំណាយលើសទៅលើខ្ទង់មួយចំនួន នាងបានកាត់បន្ថយចំណាយទៅលើអ្វីផ្សេងទៀត ។)

បន្ថែមគំនិតផ្សេងៗទៀតទៅក្នុងបញ្ជីចម្លើយ ដែលបានបង្កើតឡើងនៅក្នុងជំហ៊ានទី ៣ ។

## ជំហ៊ានទី ៤ - ២០ នាទី

ពិភាក្សាសំណួរដូចខាងក្រោមនេះ :

១. តើ នារី និងចន្ធា គ្រប់គ្រងការប៉ុនប៉ងការចំណាយរបស់គេ ដោយវិធីណាខ្លះ ?

២. តើអ្នកធ្លាប់បានព្យាយាមអនុវត្តទៅតាមវិធីស្រដៀងគ្នាទាំងនោះ ដើម្បីឱ្យអ្នកអាចអនុវត្តទៅតាមរង្វង់ថវិការបស់អ្នក ដែរឬទ ? តើវិធីទាំងនោះមានប្រសិទ្ធភាពដែរឬទេ ? បើមាន ហេតុអ្វី ? បើមិនមាន ហេតុអ្វី ?

៣. តើបុរសឬស្ត្រី ដែលជាអ្នកមានការប្តេជ្ញាចិត្តច្រើនជាង ក្នុងការអនុវត្តទៅតាមគំរោងថវិការបស់គេ ? ហេតុអ្វី ?

**ខ្លឹមសារគន្លឹះសម្រាប់គ្រូបណ្តុះបណ្តាល :**

វិធីនានាដើម្បីអនុវត្តទៅតាមគំរោងថវិការបស់អ្នក :

- ក្រើនរំឭកខ្លួនឯងជារឿយៗ នូវអ្វីដែលអ្នកបានគ្រោងទុក សម្រាប់ធ្វើការចំណាយ
- ដាក់ទៅក្នុងគំរោងថវិកា នូវចំនួនប្រាក់ចំណាយ ដែលអាចកើតឡើងដោយមិនបានគ្រោងទុក ។
- ដាក់ប្រាក់សន្សំឱ្យនៅឆ្ងាយពីភាពងាយស្រួលដកយកមកប្រើប្រាស់វិញ ដូច្នេះអ្នកមិនអាចដកវាមកចាយបាន ។
- តាមដានរាល់អ្វីមួយៗ ដែលអ្នកបានចំណាយ
- ធ្វើឱ្យប្រាកដប្រជាថា អ្នកមិនចំណាយលើសពីថវិកាដែលបានគ្រោងទុក
- ប្រសិនបើអ្នកបានចំណាយលើសចំនួនទៅលើអ្វីមួយ ចូរអ្នកកាត់បន្ថយចំណាយលើវត្ថុដទៃទៀតវិញ
- ធ្វើបញ្ជីអំពីវិធីនានាដើម្បីកាត់បន្ថយចំណាយទាំងឡាយ ដែលបានគ្រោងទុក
- ឱ្យសមាជិកគ្រួសារចូលរួមក្នុងការរៀបចំគំរោងថវិកា និងគោរពទៅតាមគំរោងថវិកា
- នៅពេលដាក់ប្រាក់វិនិយោគទៅក្នុងអាជីវកម្ម ចូរពិចារណារិះរកវិធីនានា ដើម្បីបង្ការទុក ប្រសិនបើការវិនិយោគជួបនឹងការបរាជ័យ ។

## *ជំហានទី ៥ - ១០ នាទី*

ស្នើសិក្ខាកាមឱ្យងាកទៅរកសិក្ខាកាមម្នាក់ ដែលអង្គុយនៅក្បែរគ្នា ហើយសួរសំណួរ : **តើថ្ងៃនេះអ្នកបានរៀនសូត្រអ្វីខ្លះ (ដែលអ្នកអាចយកទៅអនុវត្តនៅឯផ្ទះបាន) ដើម្បីឱ្យអ្នកអាចអនុវត្តទៅ តាមគំរោងថវិកា របស់អ្នកបាន ?**

## ជំនួយការបណ្តុះបណ្តាលទី ១៩ : រឿងស្ត្រីពីរនាក់ខិតខំអនុវត្តនៅតាមគំរោងថវិកាពួកគេ

### រឿងរបស់នារី

**នារី**បានរៀបចំគំរោងថវិកាមួយ ជាមួយក្រុមគ្រួសាររបស់នាង ។ កាលពីសប្តាហ៍មុន នាងបានទៅផ្សារ ហើយមិត្តភ័ក្តិជិតដិតរបស់នាង ចង់លក់សំលៀកបំពាក់ដ៏ស្រស់ស្អាតមួយចំនួន ដែលនាងទើបតែបានទិញពីទីក្រុង នៅពេលថ្មីៗកន្លងទៅនេះដល់នាង ។ **នារី**បានចង់ទិញសំលៀកបំពាក់ទាំងនោះណាស់ ប៉ុន្តែបាននឹកឃើញថា នាងមិនមានប្រាក់សម្រាប់សំលៀកបំពាក់ថ្លៃៗ ដូច្នេះឡើយនៅក្នុងគំរោងថវិការបស់នាង ។ នាងរីករាយណាស់ ដោយនាងបានដាក់ប្រាក់សន្សំរបស់នាងទៅក្នុងគណនីមួយរបស់ធនាគារភូមិ ដូច្នេះ នាងមិនអាចយកប្រាក់នោះ បានភ្លាមៗទេ ។ នៅថ្ងៃក្រោយមកទៀតក្នុងសប្តាហ៍នោះ កូនរបស់នាងបានធ្វើឱ្យឆ្នាំងដាំបាយរបស់នាងធ្លាក់បែក ។ នាងអាចទិញឆ្នាំងថ្មីជំនួសវិញបាន ជាមួយនឹងប្រាក់ដែលនាងបានទុកបំរុងសម្រាប់ការចំណាយនានា ដែលមិនបាន គិតទុកជាមុន ។

### រឿងរបស់ចន្ធា

ចន្ធាបានចាយវាយជាច្រើននៅអំឡុងបុណ្យចូលឆ្នាំខ្មែរ ។ នាងបានគ្រោងការចំណាយទាំងនេះ នៅក្នុង គំរោងថវិការបស់នាង ។ នៅអំឡុងពេលបុណ្យនោះ នាងបានទិញអំណោយជាច្រើនសម្រាប់ជូនដល់ក្រុមគ្រួសារ មិត្តភ័ក្តិនានា ព្រមទាំងចំណាយសម្រាប់ម្ហូបអាហារពិសេសៗជាច្រើនទៀត ។ យូរៗម្តង នាងបានបូក សរុបប្រាក់ចំណាយទាំងអស់របស់នាង ដើម្បីគណនារកចំនួនប្រាក់ ដែលមាននៅសល់ក្នុងខ្ទង់ថវិការបស់នាង ។ នាងបានដឹងថា នាងបានចំណាយច្រើនទៅលើអំណោយផ្សេងៗជាងការគ្រោងទុក ដូច្នេះនាងពិនិត្យមើល ថវិការបស់នាងដោយប្រុងប្រយ័ត្ន ។ នៅក្នុងគំរោងថវិកា នាងបំរុងទិញសំលៀកបំពាក់ថ្មីមួយកំប្លេ តែនាង បានសម្រេចចិត្តទិញសំលៀកបំពាក់នោះក្នុងតម្លៃមួយ ទាបជាងការគិតរបស់នាងពីមុនមក ដើម្បីយកទៅ បង្គ្រប់ចំនួនប្រាក់ដែលបានចាយលើសលើអំណោយ និងម្ហូបអាហារផ្សេងៗ ។

## ជំនួយការបណ្តុះបណ្តាលទី ២០ : វិធីទប់ស្កាត់ ការប៉ុនប៉ងចំណាយ



# មេរៀនទី ៩ : ការរៀបចំផែនការសន្សំប្រាក់



កំណត់ចំណាំរបស់គ្រូបណ្តុះបណ្តាល

## គោលបំណង

នៅចុងបញ្ចប់មេរៀន សិក្ខាកាមទាំងអស់នឹងបាន :

- អនុវត្តការធ្វើផែនការសន្សំប្រាក់
- រៀបចំផែនការសកម្មភាពសម្រាប់បង្កើនប្រាក់សន្សំរបស់គេ

## ប្លង់វគ្គសិក្សា (៧០ នាទី)

### ជំហានទី ១ - ១៥ នាទី

នៅក្នុងមេរៀនទី ២ សិក្ខាកាមទាំងអស់បានបង្កើតគោលបំណងហិរញ្ញវត្ថុរបស់ខ្លួន ហើយនៅក្នុងមេរៀនទី ៦ ពួកគេបានកំណត់ប្រភេទបញ្ញើសន្សំប្រាក់ ដែលសមស្របទៅនឹងគោលបំណងសន្សំប្រាក់ទាំងនោះ ។

សួរសំណួរដូចខាងក្រោមនេះ :

- **តើអ្នកមានផែនការសន្សំប្រាក់ពេញលេញមួយហើយឬនៅ?** តើអ្នកត្រូវធ្វើអ្វីទៀត ដើម្បីឱ្យផែនការសន្សំប្រាក់សម្រាប់គ្រួសាររបស់អ្នកមានលក្ខណៈពេញលេញ ?
- **តើនៅមានចំណុចអ្វីផ្សេងទៀតដែលនៅមិនទាន់បានដាក់បញ្ចូល** ? (ចំនួនប្រាក់សរុបសម្រាប់គោលបំណងនីមួយៗ ពេលវេលាដែលត្រូវការចំនួនប្រាក់សន្សំដែលត្រូវលែកទុករៀងរាល់ខែ ឬរៀងរាល់សប្តាហ៍)

### ជំហានទី ២ - ៣៥ នាទី

ស្នើឱ្យសិក្ខាកាមម្នាក់ៗ ឬជាដៃគូ បន្តធ្វើផែនការសន្សំប្រាក់ឱ្យបានពេញលេញដោយយោងទៅលើឧទាហរណ៍ក្នុងជំនួយការបណ្តុះបណ្តាលទី ២១ ។

នៅពេលបានបញ្ចប់លំហាត់នេះហើយ ចូរពិភាក្សាសំណួរដូចតទៅ :

- ចូរសង្កេតមើលចំនួនប្រាក់សរុប ដែលអ្នកត្រូវការ ។ **តើអ្នកគិតថា អ្នកនឹងអាចសន្សំចំនួនប្រាក់ ដែលត្រូវការសម្រាប់គោលបំណងនីមួយៗ ទៅតាមពេលវេលាជាក់លាក់នោះបានដែរឬទេ?**
- **តើអ្នកគិតថាគ្រួសាររបស់អ្នកអាចមានលទ្ធភាពអ្វីខ្លះ ដើម្បីសម្រេចឱ្យបានគោលបំណងទាំងនេះ?**

### ជំហានទី ៣ - ២០ នាទី

ស្នើឱ្យសិក្ខាកាមប្រៀបធៀបគំរោងថវិកា ជាមួយនឹងផែនការសន្សំប្រាក់របស់ពួកគេ ។ ឱ្យពួកគេពិនិត្យមើលប្រាក់ចំណាយ និងប្រាក់ចំណូលប្រចាំខែ ថាតើវា**មានលក្ខណៈវិជ្ជមាន ឬអវិជ្ជមាន** ។ **តើពួកគេត្រូវការកែតម្រូវអ្វីខ្លះ** ? បន្ថយការចំណាយលើវត្ថុមិនចាំបាច់ ខិតខំធ្វើការជាងមុនដើម្បីរកប្រាក់ថែមទៀត ? ហើយនៅក្នុងករណីនោះ តើនរណាអាចធ្វើការច្រើនថែមទៀតបាន ប្តី ប្រពន្ធ ឬសមាជិកគ្រួសារដទៃៗទៀត ? ផ្តល់ពេលវេលាដល់សិក្ខាកាម ដើម្បីឱ្យពួកគេអាចរកចម្លើយបានច្រើនថែមទៀត ។

នៅពេលបានបញ្ចប់ការពិភាក្សាខាងលើនេះហើយ ស្នើឱ្យសិក្ខាកាមម្នាក់ឬពីរនាក់ ឡើងមកបង្ហាញផែនការសន្សំប្រាក់របស់គេ ។ ជំរុញឱ្យសិក្ខាកាមដទៃទៀតសង្កេតមើល និងផ្តល់យោបល់ឱ្យបានច្រើន តាមដែលគេអាចធ្វើទៅបាន ។

## ជំនួយការបណ្ដុះបណ្ដាលទី ២១ : ផែនការសន្សំប្រាក់របស់ខ្ញុំ

| គោលបំណងសន្សំប្រាក់ | ចំនួនថវិកាសរុបដែលត្រូវការ | ពេលវេលាដែលត្រូវការ | ចំនួនប្រាក់សន្សំក្នុងមួយខែ | ចំណាត់ថ្នាក់នៃភាពសំខាន់ |
|---|---|---|---|---|
| **រយៈពេលខ្លី** | | | | |
| ថ្លៃបង់សាលារៀន | | | | |
| ថវិកានៅពេលមានភាពបន្ទាន់ | | | | |
| | | | | |
| | | | | |
| **រយៈពេលវែង** | | | | |
| ការជួសជុលផ្ទះ | | | | |
| | | | | |
| | | | | |
| សរុបប្រាក់សន្សំដែលត្រូវការ | | | | |

# ខ្លឹមសារមេរៀន

## ក. សមភាពយេនឌ័រ

សមភាពយេនឌ័រ គឺជាការផ្តល់ឱ្យនូវសិទ្ធិ ការទទួលខុសត្រូវ និងអំណាចធ្វើការសម្រេចស្មើភាពគ្នារវាងបុរសនិងស្ត្រី ។ ជាធម្មតា ស្ត្រីកម្ពុជាជាអ្នកទទួលខុសត្រូវចាត់ចែងថវិកាគ្រួសារ ។ នេះមិនមែនមានន័យថាពួកគេមានអំណាច ដើម្បីធ្វើការសម្រេចលើការចំណាយផ្សេងៗនៅក្នុងគ្រួសារឡើយ ។ នៅក្នុងគ្រួសារមួយចំនួនភរិយាគឺជាអ្នកទុកដាក់ប្រាក់កាស រីឯស្វាមីគឺជាអ្នកធ្វើការសម្រេចចិត្តទៅលើកិច្ចការហិរញ្ញវត្ថុសំខាន់ៗ ។

វាជាការសំខាន់សម្រាប់ស្ត្រី ក្នុងការចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តជាមួយបុរសទៅលើការបែងចែកធនធានានានៅក្នុងគ្រួសារ ពីព្រោះថាសុខុមាលភាពគ្រួសារ គុណភាពនៃជីវិត និងសុភមង្គល គឺអាស្រ័យលើការបែងចែកធនធានទាំងនោះ ប្រកបដោយសមភាព ។ គ្រួសារមួយដែលមានសុភមង្គល គឺសមាជិកម្នាក់ៗរីករាយនឹងការបែងចែកធនធានស្មើៗគ្នា និងសមរម្យ ហើយសមាជិកគ្រួសារទាំងនោះ អាចបញ្ចេញមតិនៅក្នុងរាល់បញ្ហានានា ដែលជះឥទ្ធិពលដល់ការចិញ្ចឹមជីវិត និងអនាគតរបស់ពួកគេ ។

ជាធម្មតា ស្ថាប័នហិរញ្ញវត្ថុទាំងឡាយមានអតិថិជនស្ត្រីច្រើនជាងបុរស ។ ស្ត្រីនៅទូទាំងពិភពលោកបានបង្ហាញយ៉ាងច្បាស់ថា ពួកគេគឺជាអ្នកសងប្រាក់កម្ចីវិញបានប្រសើរជាង ។ ជាថ្មីម្តងទៀត នេះមិនមែនមានន័យថា ស្ត្រីទាំងនោះជាអ្នកសម្រេចទៅលើការប្រើប្រាស់ប្រាក់កម្ចីនោះទេ ។ មានករណីកើតឡើងជាច្រើនដែលស្វាមីជាអ្នកសម្រេចលើការប្រើប្រាស់ប្រាក់កម្ចីនោះ ហើយទុកឱ្យភរិយាជាអ្នកទទួលខុសត្រូវសងបំណុល ។ នៅពេលដែលប្រាក់កម្ចីត្រូវបានប្រើប្រាស់មិនចំគោលដៅល្អ នៅទីបំផុតភរិយាត្រូវបង្កើនបន្ទុកការងារដើម្បីជម្រះបំណុល ។

ការធ្វើសេចក្តីសម្រេចទៅលើកិច្ចការហិរញ្ញវត្ថុនានានៅក្នុងគ្រួសារ ត្រូវតែធ្វើឡើងដោយស្វាមី និងភរិយានៅលើល័ក្ខខ័ណ្ឌស្មើភាពគ្នា ។ ល័ក្ខខ័ណ្ឌស្មើភាពគ្នាមានន័យថា ទាំងស្វាមីនិងភរិយាមានលទ្ធភាពទទួលបានព័ត៌មានស្មើគ្នា និងមានមតិស្មើគ្នានៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត ។ វគ្គបណ្តុះបណ្តាលនេះគឺមានគោលដៅ ដើម្បីធ្វើឱ្យប្រសើរឡើងនូវអំណាចធ្វើសេចក្តីសម្រេចរបស់ស្ត្រីនៅក្នុងគ្រួសារ ដោយការបង្កើនចំណេះដឹងស្តីអំពីការគ្រប់គ្រងហិរញ្ញវត្ថុដល់ស្ត្រី និងការជួយឱ្យស្ត្រីនិងបុរសយល់ដឹងអំពីវិសមភាពនានា ដែលបានកំពុងកើតមាន លទ្ធផលនៃវិសមភាពទាំងនោះ ព្រមទាំងវិធីនានា ដែលពួកគេអាចកាត់បន្ថយ ឬ លុបបំបាត់ឱ្យវិសមភាពទាំងនោះ ។

## ៩. គំរោងថវិកា

និយមន័យ:" **គំរោងថវិកាគឺជាផែនការមួយ ដែលបង្ហាញពីអ្វីដែលអ្នកនឹងធ្វើជាមួយប្រាក់កាសរបស់អ្នក**" ។

គំរោងថវិកាគឺជាឧបករណ៍សាមញ្ញមួយ៉ាង ដែលនរណាក៏ដោយ អ្នកមាន ឬអ្នកក្រ អាចប្រើប្រាស់ដើម្បីគ្រប់គ្រងប្រាក់កាសរបស់គេ ។ គំរោងថវិកាមានតួនាទីដូចជាផែនការមេ សម្រាប់ពេលអនាគត ។ គំរោងថវិកាទាំងឡាយ គឺជាផែនទីបង្ហាញផ្លូវមួយ ដែលអាចជួយអ្នកឱ្យចាកចេញពីស្ថានភាពបច្ចុប្បន្នឈានទៅសំរេចតាមគោលបំណងហិរញ្ញវត្ថុ ។ គោលបំណងហិរញ្ញវត្ថុអាចមានក្នុងរយៈពេលខ្លី ដូចជាការរួចផុតពីបំណុលដោះស្រាយចំណាយប្រចាំថ្ងៃដោយមិនចាំបាច់ខ្ចីប្រាក់ ការបង់ថ្លៃសាលា ឬក៏ការសន្សំប្រាក់ទុកសម្រាប់សេចក្តីត្រូវការឬបំណងពិសេសណាមួយ ។ គោលបំណងទាំងនេះ អាចមានក្នុងរយៈពេលវែង ដូចជាការសន្សំប្រាក់ទុកសម្រាប់សាងសង់ផ្ទះ ឬការចូលនិវត្ត ។ ការគ្រោងថវិកាមួយ នឹងជួយអ្នកចាត់ចែងធនធានរបស់អ្នកដើម្បីសម្រេចបាននូវគោលបំណងច្រើនយ៉ាង ។

អ្នកអាចធ្វើរឿងបីយ៉ាង ជាមួយនឹងប្រាក់កាសរបស់អ្នក: **ចំណាយវា សន្សំវាទុក ឬវិនិយោគវា** :

- អ្នកចំណាយប្រាក់សម្រាប់សេចក្តីត្រូវការពីមួយថ្ងៃទៅមួយថ្ងៃ ដូចជា ស្បៀងអាហារ លំនៅដ្ឋាន ការធ្វើដំណើរ សំលៀកបំពាក់ ការថែទាំសុខភាព ការសងបំណុល ព្រមទាំងការចំណាយមួយចំនួនទៀត ដូចជាទឹកតែ ទស្សនាភាពយន្ត ឬការកំសាន្តផ្សេងៗ ។
- អ្នកសន្សំប្រាក់ទុកសម្រាប់ពេលមានភាពបន្ទាន់ណាមួយ ដែលអាចកើតមានឡើង ដោយមិនបានគិតទុកជាមុន ឬដើម្បីសម្រេចគោលបំណងហិរញ្ញវត្ថុក្នុងរយៈពេលខ្លី ឬក្នុងរយៈពេលមធ្យម
- អ្នកវិនិយោគប្រាក់ទៅក្នុងការអាជីវកម្មនានា ដើម្បីរកប្រាក់ចំណូលនៅក្នុងរយៈពេលវែងឆ្ងាយខាងមុខ ។

ដំបូន្មានដ៏ល្អបំផុតសម្រាប់គ្រប់គ្រងផ្នែកទាំងបីនៃជីវិតហិរញ្ញវត្ថុរបស់អ្នក គឺវាមានភាពងាយស្រួលនិយាយ ប៉ុន្តែវាពិបាកសម្រេចបាន ។

**ចាយដោយប្រុងប្រយ័ត្ន**
**សន្សំឱ្យទៀងទាត់**
**វិនិយោគដោយប្រុងប្រយ័ត្ន**

ទាំងនេះគឺជាមូលដ្ឋានគ្រឹះសម្រាប់ការគ្រប់គ្រងថវិកា ។ គំរោងថវិកា នឹងជួយឱ្យអ្នកចាត់ចែងប្រាក់កាសរបស់អ្នកទៅតាមប្រភេទទាំងបីនេះ ហើយជួយឱ្យអ្នកធ្វើសេចក្តីសម្រេចងាយស្រួលលើការប្រើប្រាស់ប្រាក់កាសប្រចាំថ្ងៃរបស់អ្នក ។

គំរោងថវិកាល្អ គឺជួយអ្នកឱ្យចំណាយលើអ្វីដែលអ្នកត្រូវការ និងសន្សំប្រាក់ទុកសំរាប់អ្វី ដែលអ្នកចង់បាននៅក្នុងជីវិត" ។

**ផលប្រយោជន៍នានារបស់គំរោងថវិកា**

- ងាយស្រួលធ្វើសេចក្តីសម្រេចលើការចំណាយ និងការសន្សំ
- ជួយឱ្យមានការប្រុងប្រយ័ត្ន នៅពេលធ្វើការចំណាយ
- ជួយឱ្យការសន្សំប្រាក់មានរបៀបរៀបរយល្អ
- ប្រសិនបើគោរពបានទៅតាមបន្ទាត់ថវិកា វាជួយឱ្យអ្នកគ្រប់គ្រងប្រាក់កាសរបស់អ្នកបាន

## តើអ្នករៀបចំថវិកាតាមវិធីណា ?

### ១. តាមដានប្រាក់ចំណូលនិងប្រាក់ចំណាយរបស់អ្នក

ជំហ៊ានដំបូងនេះ គឺត្រូវរក្សាកំណត់ត្រានៃប្រាក់ចំណូលក្នុងគ្រួសាររបស់អ្នក (ចំណូលមកពីគ្រប់ប្រភពទាំងអស់) និងប្រាក់ចេញ (ចំណាយទាំងឡាយ) ឱ្យបានល្អ ។ បន្ទាប់មក អ្នកអាចប្រើប្រាស់ព័ត៌មានទាំងនេះដើម្បីរៀបចំរបាយការណ៍លំហូរសាច់ប្រាក់មួយ ដែលបង្ហាញពីប្រភពថវិកាចំណូល និងប្រភពទាំងឡាយ ដែលប្រាក់របស់អ្នកហូរចេញទៅ នៅក្នុងអំឡុងពេលជាក់លាក់មួយ ។ នេះមានន័យថា ជាការតាមដានពីលំហូរប្រាក់ចំណូលរបស់អ្នក ។ ការវិភាគរបាយការណ៍លំហូរសាច់ប្រាក់ គឺអាចជួយឱ្យអ្នកគណនាបាន ថាតើចំណាយច្រើនជាងចំណូលឬយ៉ាងណា ។ វានឹងជួយអ្នកកំណត់រកមុខចំណាយណា ដែលអ្នកអាចកាត់បន្ថយបាន និងកំណត់រកវិធីនានាដែលអ្នកអាចបង្កើនការសន្សំបានថែមទៀត ។

ដើម្បីរៀបចំរបាយការណ៍លំហូរសាច់ប្រាក់មួយ ចូរជ្រើសរើសយកអំឡុងពេលថ្មីមួយ ក្នុងមួយសប្តាហ៍ ឬក្នុងមួយខែ សម្រាប់ធ្វើការវិភាគ ។ កត់ត្រាប្រភពនិងចំនួនប្រាក់ចំណូលទាំងអស់របស់អ្នកនៅក្នុងអំឡុងខែនេះ ។ ប្រាក់ចំណូលសរុបរបស់អ្នក គួររាប់បញ្ចូលប្រភេទប្រាក់ចំណូលដូចតទៅនេះ ដែលទាក់ទិននឹងគ្រួសាររបស់អ្នក : ប្រាក់ខែរបស់អ្នកក្រោយពីការកាត់ចេញផ្សេងៗ ប្រាក់ចំណូលអាជីវកម្មជាមធ្យម ប្រាក់ចំណូលរបស់ស្វាមី ប្រាក់ចំណូលរបស់សមាជិកគ្រួសារដទៃទៀត ប្រាក់ចំណូលពីការជួល ប្រាក់ដែលបានទទួលពីការផ្ញើមកឱ្យ និងប្រភពប្រាក់ចំណូលផ្សេងៗទៀត ។ ប្រសិនបើអ្នកមានប្រភពប្រាក់ចំណូលមួយ ដែលបានមកក្នុងពេលម្តងម្កាល (ឧ. ប្រចាំត្រីមាស ឬប្រចាំឆមាស) អ្នកអាចប៉ាន់ស្មានវា សម្រាប់រយៈពេលមួយឆ្នាំ ដោយចែកចំនួននោះនឹង ១២ ខែ ដើម្បីគណនារកប្រាក់ចំណូលក្នុងមួយខែ ។

នៅជំហ៊ានបន្ទាប់ កត់ត្រារាល់ចំណាយទាំងឡាយរបស់អ្នក ដោយរាប់បញ្ចូលចំណាយចាំបាច់នានា (ស្បៀងអាហារ លំនៅដ្ឋាន សំលៀកបំពាក់ ការធ្វើដំណើរ ។ល។) ការសងបំណុល និងចំណាយផ្សេងៗទៀត ។ ចូរកុំកត់ត្រាបញ្ចូលចំណាយទាំងឡាយដែលមានលក្ខណៈពិសេស ឬចំណាយតែម្តងសម្រាប់រយៈពេលយូរ គឺកត់ត្រាសម្រាប់ចំណាយទាំងឡាយណា ដែលអ្នកបានធ្វើនៅក្នុងអំឡុងពេលនេះតែប៉ុណ្ណោះ ។

នៅជំហ៊ានចុងក្រោយ ដកប្រាក់ចំណាយសរុប ចេញពីប្រាក់ចំណូលសរុប ។ លទ្ធផលគឺជាប្រាក់ចំណូលសុទ្ធរបស់អ្នក ដែលជាចំនួនខុសគ្នារវាងប្រាក់ចំណូល និងប្រាក់ចំណាយនៅក្នុងអំឡុងពេលនេះ ។

ធ្វើការកត់ត្រារបៀបនេះជាបន្តទៀតសម្រាប់អំឡុងពេលវេលាខាងមុខ (ប្រចាំខែ ឬសប្តាហ៍) ដូច្នេះអ្នកអាចកំណត់រកភាពខុសគ្នានានារវាងអំឡុងពេលទាំងនោះ និងបានដឹងពីការប្រែប្រួលក្នុងប្រាក់ចំណូល និងប្រាក់ចំណាយទាំងឡាយ ។ តើនៅពេលណា ដែលអ្នកទំនងជាត្រូវចាយច្រើនជាងប្រាក់ចំណូល ? តើប្រាក់ចំណូលរបស់អ្នកកើនឡើងនៅពេលណា ? តើអ្នកអាចសន្សំប្រាក់បានច្រើនថែមទៀតនៅក្នុងអំឡុងពេលទាំងនោះបានដែរឬទេ ? តើប្រាក់ចំណាយរបស់អ្នកកើនឡើងនៅពេលណា ? តើមានចំណាយណាខ្លះមិនប្រក្រតី ? តើចំណាយទាំងនេះ ចាំបាច់ដែរឬទេ ?

## ២, បង្កើតខ្ទង់ផ្សេងៗនៅក្នុងគំរោងថវិកា ដែលសមរម្យសម្រាប់អ្នក

បន្ទាប់ពីបានប៉ាន់ស្មានប្រាក់ចំណូលសុទ្ធប្រចាំខែរបស់អ្នក (ជំហ៊ានទី ១ ខាងលើ) នៅជំហ៊ានបន្ទាប់គឺត្រូវគិតអំពីខ្ទង់ផ្សេងៗ នៅក្នុងគំរោងថវិការបស់អ្នក ។ អ្នកត្រូវសម្រេចលើប្រភេទខ្ទង់នីមួយៗ ឱ្យមានលក្ខណៈជាក់លាក់ ឬមានលក្ខណៈទូទៅ ។ ប្រភេទខ្ទង់ថវិកានេះត្រូវមានលក្ខណៈសាមញ្ញ ។ ប្រភេទខ្ទង់ថវិកាសំខាន់ ជាងគេពីរយ៉ាងគឺ ការចំណាយ និងការសន្សំ ។ តារាងទី ១ បង្ហាញពីប្រភេទថវិកាជាក់លាក់មួយចំនួននៅក្រោម ប្រភេទខ្ទង់ទាំងពីរនេះ ។

### តារាងទី ១ : ប្រភេទថវិកាដែលអាចរាប់បញ្ចូល

| ចំណាយ | សន្សំ |
|---|---|
| - វត្ថុចាំបាច់ (លំនៅដ្ឋាន ថ្លៃសាលា សុខភាព ទឹកភ្លើង ស្បៀងអាហារ ការធ្វើដំណើរ សំលៀកបំពាក់)<br>- គ្រប់គ្រងបំណុល (ប្រាក់កម្ចី ថ្លៃឈ្នួល បំណុលផ្សេងៗ)<br>- ចំណាយសម្រាប់សកម្មភាពសង្គម (ការកំសាន្ត ការចូលរួមសកម្មភាពសង្គម) | - ថវិកាសំរាប់ពេលមានភាពបន្ទាន់<br>- ថវិកាសន្សំក្នុងរយៈពេលខ្លី<br>- ថវិកាសន្សំក្នុងរយៈពេលមធ្យម<br>- ថវិកាសន្សំក្នុងរយៈពេលវែង |

## ៣. បង្កើតគោលបំណងហិរញ្ញវត្ថុរបស់អ្នក

គោលបំណងអាចមានភាពខុសប្លែកគ្នា - ចាប់ពីការដោះស្រាយសេចក្តីត្រូវការជាមូលដ្ឋាន ឆ្ពោះទៅរកការរួចផុតពីបំណុល ការសិក្សារបស់កូន និងការទិញផ្ទះ។ គោលបំណងមួយចំនួនអាចសំរេចបានក្នុងរយៈពេលខ្លី តែគោល-បំណងផ្សេងទៀត អាចត្រូវការពេលវេលាយូរដើម្បីសម្រេចបាន ។ នៅពេលអ្នកសម្រេចយកគោលបំណងជាអាទិភាពរបស់អ្នករួចហើយ ចូរគណនាថាតើអ្នកត្រូវការថវិកាប៉ុន្មាន ដើម្បីសំរេចគោលបំណងនីមួយៗ ហើយកំណត់ពេលវេលា ដើម្បីសម្រេចគោលបំណងទាំងនោះ ។ ប្រសិនបើចំនួនថវិកា ដែលត្រូវការច្រើនជាងចំនួនដែលអ្នកគិតថាអាចប្រឹងប្រែងរកបាន ចូរធ្វើការកែតម្រូវ ដូចជាពន្យារពេល ដែលអ្នកត្រូវការ ដើម្បីសន្សំចំនួនប្រាក់ដែលអ្នកចង់បាន កាត់បន្ថយចំណាយ ឬផ្លាស់ប្តូរគោលបំណង ។

**តារាងទី ២** ផ្តល់ជាឧទាហរណ៍អំពីគោលបំណងហិរញ្ញវត្ថុនានា ។ ឧទាហរណ៍ អ្នកចង់សន្សំប្រាក់ ចំនួន ៩ ០០០ រៀលក្នុងមួយខែ ដើម្បីសម្រេចគោលបំណងរយៈពេលខ្លី ។ ចូរក្រឡេកមើលចំនួនប្រាក់ដែលអ្នកមានដើម្បីធ្វើការសន្សំ - តើមានការខ្វះខាតនៅចន្លោះពេលណាមួយដែរឬទេ ។ អ្នកប្រហែលជាមិនអាចសន្សំជារៀងរាល់ខែ ឱ្យបានច្រើនតាមចិត្តដែលអ្នកប្រាថ្នានោះទេ ជាមួយនឹងប្រាក់ចំណូល និងប្រាក់ចំណាយ បច្ចុប្បន្នរបស់អ្នក ។ ដូច្នេះអ្នកត្រូវកែតម្រូវគោលបំណងសន្សំប្រាក់របស់អ្នក ដោយការសន្សំចំនួនតិចតួច សម្រាប់គោលបំណងជាក់លាក់នីមួយៗ ហើយពន្យារពេលវេលាដើម្បីជួយឱ្យអ្នកអាចសម្រេចបាន ។ អ្នកអាចពិនិត្យមើលថែមទៀតទៅលើមុខចំណាយនានា ដើម្បីរកចន្លោះណាមួយដែលអាចកាត់បន្ថយបាន ដូច្នេះអ្នកអាចបង្កើនចំនួនប្រាក់សន្សំបានថែមទៀត ពីប្រាក់ចំណូលរបស់អ្នក ។

### តារាងទី ២ : គោលបំណងហិរញ្ញវត្ថុរយៈពេលខ្លីរបស់អ្នក

| គោលបំណង | តម្លៃ | រយៈពេល | ចំនួនប្រាក់សន្សំក្នុងមួយខែ |
|---|---|---|---|
| ១) ការជួសជុលផ្ទះ | ៥០ ០០០ រៀល | ១០ ខែ | ៥ ០០០ រៀល |
| ២) ថ្លៃសាលា | ២០ ០០០ រៀល | ១០ ខែ | ២ ០០០ រៀល |
| ៣) ព្យាបាលកូនប្រុស | ២០ ០០០ រៀល | ១០ ខែ | ២ ០០០ រៀល |
| **សរុបប្រាក់សន្សំក្នុងមួយខែ ៩០០០ រៀល** | | | |

### ៤. ចាត់ចែងប្រាក់ចំណូលរបស់អ្នកសម្រាប់ខ្ទង់ថវិកានីមួយៗ

ប្រសិនបើរបាយការណ៍លំហូរសាច់ប្រាក់របស់អ្នក ផ្តល់ការប៉ាន់ស្មានដ៏ពិស្តារមួយពីប្រាក់ចំណូល និងប្រាក់ចំណាយបច្ចុប្បន្នរបស់អ្នក អ្នកគួរតែអាចកំណត់រកឱកាសនានាបាន ដើម្បីកាត់បន្ថយការចំណាយ និងបង្កើនការសន្សំ ។ នៅពេលអ្នកចាត់ចែងប្រាក់កាសរបស់អ្នកទៅតាមខ្ទង់ថវិកានីមួយៗ ចូរពិចារណាទៅលើអាទិភាពនានា និងគោលបំណងហិរញ្ញវត្ថុរបស់អ្នក ។ ប្រសិនបើអ្នកមិនមានប្រាក់ចំណូលគ្រប់គ្រាន់ សំរាប់ចំណាយទៅលើវត្ថុចាំបាច់ប្រចាំថ្ងៃ សងបំណុល និងធ្វើការសន្សំសម្រាប់គោលបំណងជាក់លាក់ណាមួយនោះទេ អ្នកត្រូវធ្វើការកែតម្រូវគំរោងថវិកាឡើងវិញ ។ អ្នកអាចកាត់បន្ថយចំណាយនានារបស់អ្នក ឧ. ប្រើប្រាស់គ្រឿងសំណង់ដែលមានតម្លៃទាប (ដើម្បីជួសជុលផ្ទះរបស់អ្នក) ឬពន្យារពេលវេលា ដើម្បីសម្រេចគោលបំណងទាំងឡាយរបស់អ្នក (ផ្តល់ពេលវេលាដល់ខ្លួនឯងចំនួន ១២ ខែ ជាជាង ១០ ខែ ដើម្បីធ្វើការសន្សំសម្រាប់ការជួសជុលផ្ទះនោះ) ។ ចូរគ្រោងថវិកាឱ្យប្រាកដប្រជា ។ សូមមើលតារាងទី ៣ សម្រាប់ជាឧទាហរណ៍អំពីថវិកា ។

#### តារាងទី ៣ : ការព្យាករណ៍ពីថវិកាដែលមានលក្ខណៈចម្រុះ

| ការចំណាយ | | ការសន្សំ | |
|---|---|---|---|
| - វត្ថុចាំបាច់ (លំនៅដ្ឋាន អាហារ ។ល។) | ៦០% | - ថវិកាសំរាប់ពេលបន្ទាន់ | ១០% |
| - ដោះបំណុល | ១០% | - ប្រាក់សន្សំក្នុងរយៈពេលខ្លី | ៥% |
| - ចំណាយសម្រាប់សកម្មភាពសង្គម | ១០% | - ប្រាក់សន្សំក្នុងរយៈពេលវែង | ៥% |
| **សរុបប្រាក់ចំណាយ :** | **៨០%** | **សរុបប្រាក់សន្សំ :** | **២០%** |

### តើមានកត្តាអ្វីផ្សេងទៀតដែលនឹងជះឥទ្ធិពលដល់គំរោងថវិការបស់អ្នក ?

### ១. ចរិតលក្ខណៈរបស់អ្នកចំពោះប្រាក់កាស

ឥរិយាបថក្នុងការគ្រប់គ្រងប្រាក់កាសរបស់អ្នកពីអតីតកាល គឺជាការឆ្លុះបញ្ចាំងពីចរិតរបស់អ្នកចំពោះប្រាក់កាស ។ តើអ្នកជាមនុស្សរកប្រាក់យកមកទុក ? ជាអ្នកចាយវាយ ? ជាអ្នកគេចវេសពីប្រាក់កាស (មនុស្សប្រភេទនេះចូលចិត្តចាយវាយ ប៉ុន្តែយល់ដឹងតិចតួចអំពីប្រាក់កាស) ? ជាអ្នកប្រឹងប្រែងខិតខំរកប្រាក់ ? ជាអ្នកទទួលយកហានិយភ័យ ? ជាអ្នកគេចវេសពីហានិយភ័យ ?

មនុស្សភាគច្រើន មានចរិតលក្ខណៈលាយឡំគ្នា ច្រើនជាងមានលក្ខណៈតែម្យ៉ាងខាងលើនេះ ។ ការយល់ដឹងពី " ចរិតលក្ខណៈ" របស់អ្នក គឺអាចជួយឱ្យអ្នករារាំងបានពីនិន្នាការនានា ដែលអាចកើតមានឡើងនៅតាមផ្លូវឆ្ពោះទៅរកការសម្រេចគោលបំណងនានារបស់អ្នក ។

### ២, " ដំណាក់កាលហិរញ្ញវត្ថុ " នៃជីវិតរបស់អ្នក

ចំនួនប្រាក់ដែលហូរចូលមក និងចំនួនប្រាក់ដែលអ្នកលៃលកសម្រាប់ការចំណាយ ការសន្សំ ឬការវិនិយោគ គឺមានការខុសប្លែកគ្នាទៅតាមដំណាក់កាលនានានៃជីវិត ។ នៅពេលអ្នកមានវ័យក្មេង អ្នកនឹងចំណាយប្រាក់របស់អ្នកស្ទើរតែទាំងអស់ទៅលើការអប់រំ និងព្រឹត្តិការណ៍សង្គមផ្សេងៗ ។ នៅពេលអ្នកឈានដល់វ័យកណ្តាល អ្នកនឹងអាចបង្កើនការសន្សំបានច្រើន ។ ប្រសិនបើអ្នកក្លាយជាមនុស្សចាស់ ហើយប្រាក់ចំណូលធ្លាក់ចុះ វាអាចបង្ខំឱ្យអ្នកសន្សំបានចំនួនតិចតួចប៉ុណ្ណោះ ហើយត្រូវចំណាយច្រើនទៀតផង ។ ដូច្នេះ នៅពេលអ្នកគ្រោងថវិកា ចូរត្រិះរិះពីដំណាក់កាលនៃជីវិតរបស់អ្នក ។

ក្នុងពេលខាងមុខណាមួយនោះ ការប្រែប្រួលកាលៈទេសៈ អាចតម្រូវឱ្យអ្នកធ្វើការកែលំអថវិកាគំរោងរបស់អ្នក ។ ប្រសិនបើប្រាក់ចំណូលរបស់អ្នកកើនឡើង អ្នកអាចលៃលកបង្កើនចំនួនប្រាក់សន្សំថែមទៀត។ ប្រសិនបើប្រាក់ចំណូលរបស់អ្នកធ្លាក់ចុះ អ្នកអាចសន្សំបន្តិចបន្តួច ដើម្បីបង់ថ្លៃចំណាយទៅលើវត្ថុចាំបាច់នានា ។ ប្រសិនបើអ្នកមានកូនមួយថែមទៀត អ្នកត្រូវបង្កើនការសន្សំ សម្រាប់ស្បៀងអាហារ និងការអប់រំ ។ ប្រសិនបើតម្លៃសម្រាប់វត្ថុចាំបាច់នានា កើនឡើងនៅអាត្រាខ្ពស់ជាងកំណើនប្រាក់ចំណូល អ្នកត្រូវធ្វើការកែតម្រូវគំរោងថវិការបស់អ្នក ។ ចូរពិនិត្យមើលគំរោងថវិការបស់អ្នកជាទៀងទាត់ ដូច្នេះអ្នកបានត្រៀមលក្ខណៈជាមុន ដើម្បីកែតម្រូវវា ដោយឆ្លើយតបទៅនឹងការប្រែប្រួលកាលៈទេសៈនានា ។

ការធ្វើផែនការថវិកាដ៏ល្អមួយ នៅពេលខ្លះក៏នឹងត្រូវបរាជ័យដែរ ។ ការបរាជ័យជាទូទៅដោយ សារ ១) ការមានភាពបន្ទាន់ធ្ងន់ធ្ងរពេក ( មហន្តរាយធម្មជាតិ ឬការធ្លាក់ខ្លួនឈឺដោយភ្លាមៗ ) ដែលបង្ខំ ឱ្យមានការចំណាយដែលមិនបានគ្រោងទុក ២) កង្វះខាតការប្តេជ្ញាចិត្ត ឬកង្វះខាតការរៀបចំខ្លួន វិន័យ) ដោយខ្លួនអ្នកផ្ទាល់ ឬសមាជិកគ្រួសាររបស់អ្នក ឬ ៣) មានគោលបំណងនានា ដែលមិនជាក់លាក់ ។ សម្រាប់ចំណាយនៅពេលមានភាពបន្ទាន់នានា អ្នកអាចការពារខ្លួនអ្នកពីឥទ្ធិពលអវិជ្ជមាននៃព្រឹត្តិការណ៍ ដែលមិនបានគ្រោងទុកបាន ដោយការរក្សាថវិកាទុកពេលមានភាពបន្ទាន់ ដែលជាផ្នែកមួយនៃគំរោងថវិការបស់អ្នក ។ នៅពេលអ្នកបានរៀន និងយល់ដឹងអំពីប្រាក់កាស និងកិច្ចការហិរញ្ញវត្ថុ អ្នកនឹងអាចបង្កើតគោលបំណងហិរញ្ញវត្ថុជាក់លាក់ និងរៀបចំខ្លួនឱ្យត្រឹមត្រូវ (វិន័យ) ដើម្បីសម្រេចគោលបំណងទាំងនោះ ។

**តើអ្នកអនុវត្តទៅតាមគំរោងថវិការបស់អ្នកដោយវិធីណា? ការរៀបចំខ្លួនឱ្យបានល្អ (វិន័យ) !** ការគ្រោងថវិកាគឺជាការពិភាក្សាគ្នាដ៏សាមញ្ញមួយ ។ នរណាក៏អាចធ្វើវាបានដែរ ។ ប៉ុន្តែការអនុវត្ត និងការគោរពទៅតាមបន្ទាត់ថវិកា គឺមានការលំបាកច្រើនណាស់ ។ វាទាមទារឱ្យមានវិន័យ ! អ្នកត្រូវតែគោរព ទៅតាមខ្ទង់នីមួយៗនៃគំរោងថវិកា ចាប់ពីការបង្កើតគោលបំណងហិរញ្ញវត្ថុ ទៅដល់ការត្រួតពិនិត្យមើលការចំណាយរបស់អ្នក និងការផ្តល់តំលៃចំពោះការប្តេជ្ញាចិត្តរបស់អ្នកដើម្បីសន្សំប្រាក់ ។ សេចក្តីណែនាំដូចខាងក្រោមនេះ នឹងជួយឱ្យអ្នករកឃើញវិន័យដែលអ្នកត្រូវការ សម្រាប់បន្ទាត់ថវិកានីមួយៗរបស់អ្នក ។

## សម្រាប់ការបង្កើតគោលបំណងហិរញ្ញវត្ថុនានា:

- បង្កើតគោលបំណងថវិកាជាក់លាក់សម្រាប់រយៈពេលខ្លី និងរយៈពេលវែង ។
- បង្កើតគោលបំណងយ៉ាងតិចមួយ ដែលអ្នកត្រូវធ្វើឱ្យបានសំរេចភ្លាមៗ ដើម្បីផ្តល់រង្វាន់ដល់ទម្លាប់សន្សំប្រាក់នៅក្នុងគ្រួសាររបស់អ្នក ។
- ត្រួតពិនិត្យឡើងវិញលើគោលបំណងនានា និងគំរោងថវិកានៅក្នុងពេលណាមួយខាងមុខ ។

## សម្រាប់ការចំណាយ:

- កាត់បន្ថយចំណាយអ្វីមួយដែល " **ប្រាក់ត្រូវចេញ** " គឺជាចំណុចសំខាន់នៃការសន្សំ ។ ការចំណាយដោយប្រុងប្រយ័ត្ន គឺជួយអ្នកឱ្យអាចសន្សំបាន ។
- កត់ត្រាវិធីនានាដែលអាចធ្វើទៅបាន ដើម្បីកាត់បន្ថយចំណាយប្រចាំថ្ងៃ ។ អ្នកអាចបង្កើនការសន្សំនៅក្នុងពេលណាមួយខាងមុខ ដោយការកាត់បន្ថយចំណាយប្រចាំថ្ងៃទាំងឡាយ ជាជាងការកាត់បន្ថយចំណាយទៅលើមុខចំណាយធំណាមួយ ។
- តាមដានពីចំនួនប្រាក់ដែលអ្នកបានចាយទៅលើមុខចំណាយនីមួយៗ ។

## សម្រាប់ការសន្សំ:

- **សន្សំមុនគេបង្អស់** ! ចូរគោរពតាមច្បាប់ ១០% មានន័យថាសន្សំចំនួន ១០% នៃប្រាក់ចំណូលគ្រួសាររបស់អ្នក។ យុទ្ធសាស្ត្រមួយគឺថាត្រូវសន្សំមុនគេបង្អស់ ហើយបន្ទាប់មកទើបគិតគូរពីការចំណាយទៅលើចំនួនប្រាក់នៅសេសសល់។ វាងាយស្រួលនិយាយជាងធ្វើ ។ យុទ្ធសាស្ត្រនេះគឺជាវិធីល្អមួយដើម្បីសម្រេចគោលបំណងហិរញ្ញវត្ថុរបស់អ្នក ។
- ដាក់ប្រាក់សន្សំមានតម្លៃសម្រាប់គ្រួសារក្នុងរយៈពេលពី ៣ ទៅ ៦ ខែទៅក្នុងថវិកាសំរាប់ពេលមានភាពបន្ទាន់ ហើយត្រូវរក្សាវាទុកក្នុងកន្លែងសុវត្ថិភាពមួយ មុនពេលអ្នកលៃលកការសន្សំសម្រាប់គោលបំណងផ្សេងៗទៀត ។វានឹងការពារអ្នក នៅពេលមានការឈឺថ្កាត់នៅក្នុងគ្រួសារ ឬពេលគ្មានការងារធ្វើ ហើយកាត់បន្ថយការពឹងពាក់ទៅលើបំណុលរយៈពេលខ្លី ដើម្បីដោះស្រាយសេចក្តីត្រូវការ នៅពេលមានភាពបន្ទាន់នានា ។
- **រក្សាទុកប្រាក់សន្សំនៅឱ្យឆ្ងាយពីដៃ**។ ប្រសិនបើអ្នករក្សាប្រាក់សន្សំរបស់អ្នកនៅក្នុងផ្ទះ អ្នកទំនងជាទទួលសម្ពាធពីសមាជិកគ្រួសារនានា ដើម្បីប្រើប្រាស់ប្រាក់នោះសម្រាប់ការកំសាន្តផ្សេងៗ ។

## សម្រាប់ការវិនិយោគ:

- នៅពេលដែលអ្នកកំពុងពិចារណាទៅលើការវិនិយោគណាមួយ ចូរកំណត់ប្រភេទហានិយភ័យ ដែលនឹងអាចកើតឡើង ។ អ្នកអាចចាត់ទុកហានិយភ័យ ដូចជាឱកាស ឬបញ្ហា ហើយសួរខ្លួនឯង ថា " តើមាន

ឱកាសអ្វីខ្លះ ដែលខ្ញុំនឹងរកឱ្យបានប្រាក់ចំណេញច្រើន ឬ ខ្ញុំត្រូវខាតបង់ធំ ? ប៉ុន្តែទិដ្ឋភាពទីពីរនៃហានិយភ័យ គឺមានសារៈសំខាន់ណាស់ ។ " តើមានផលវិបាកអ្វីខ្លះពីការទទួលយកហានិយភ័យនេះ ? " ឬន័យម្យ៉ាងទៀតថា " តើនឹងមានអ្វីកើតឡើងខ្លះ ប្រសិនបើការវិនិយោគរបស់ខ្ញុំត្រូវបរាជ័យ ?

- ស្វែងរកការអត់ធ្មត់របស់អ្នកសម្រាប់ហានិយភ័យនោះ ។ ចូរចងចាំពីឱកាសផ្សេងៗទៀត ក្នុងជីវិតរបស់អ្នក ដែលបានជួបប្រទះនឹងហានិយភ័យទាំងនោះ ។ តើអ្នកបានទប់ទល់ហានិយភ័យទាំងនោះដោយវិធីណាខ្លះ ? តើហានិយភ័យទាំងនោះ ធ្វើឱ្យអ្នកមានអារម្មណ៍យ៉ាងណា ?

## គ. ការសន្សំប្រាក់: អ្នកអាចធ្វើបាន!

### និយមន័យការសន្សំប្រាក់

ប្រាក់សន្សំ គឺជាប្រាក់កាស ដែលត្រូវបានដាក់នៅទីកន្លែងមួយដាច់ដោយឡែក ដោយនរណាម្នាក់ ឬ គ្រួសារមួយ សម្រាប់ទុកប្រើប្រាស់នៅពេលអនាគត ។ វាជាកត្តាគន្លឹះសម្រាប់ការគ្រប់គ្រងប្រាក់កាសឱ្យបានល្អ ប្រាក់សន្សំជួយមនុស្សម្នាក់ៗ និងគ្រួសារទាំងឡាយក្នុងការគ្រប់គ្រងហានិយភ័យ ដោះស្រាយនៅពេលមានភាពបន្ទាន់នានា ។ វាជួយឱ្យប្រាក់ចំណូលមានជាបន្តបន្ទាប់ បង្កើនទ្រព្យសម្បត្តិទាំងឡាយ និង សម្រេចបាននូវគោលបំណងហិរញ្ញវត្ថុផ្សេងៗ ។

### មូលហេតុនៃការសន្សំប្រាក់

ជាញឹកញាប់ ជនក្រីក្រត្រូវការចំនួនប្រាក់ច្រើនជាងអ្វី ដែលគេមាននៅក្នុងដៃ ។ សេចក្តីត្រូវការសម្រាប់ " ចំនួនប្រាក់ដ៏ច្រើន តែមានប្រយោជន៍" ទាំងនេះកើតឡើងពីព្រឹត្តិការណ៍ផ្សេងៗក្នុងជីវិត ដូចជាពេលសំរាលទារក ការអប់រំ អាពាហ៍ពិពាហ៍ និងមរណៈភាព ពោលគឺសំរាប់ស្ថានការណ៍បន្ទាន់ និងឆ្លើយតប ទៅនឹងឱកាសនានា ដើម្បីធ្វើវិនិយោគជាទ្រព្យសម្បត្តិ ឬជាអាជីវកម្មនានា ។ មានតែវិធីម្យ៉ាងគត់ ដែលអាចជឿជាក់ និងមាននិរន្តរភាពបានសម្រាប់ឱ្យពួកគេបានទទួលប្រាក់ចំនួនច្រើនដូច្នេះ គឺថាពួកគេត្រូវតែបង្កើនប្រាក់ទុកតាមវិធីណាមួយ ឬតាមរយៈការសន្សំប្រាក់របស់ពួកគេ ។

អ្នកអាចប្រើប្រាស់ប្រាក់សន្សំ ដើម្បីដោះស្រាយសេចក្តីត្រូវការនានា ដែលបានគ្រោងទុក និងមិនបានគ្រោងទុក ។ វាជួយឱ្យលំហូរសាច់ប្រាក់របស់អ្នកមានលក្ខណៈរលូន ផ្តល់ឱ្យមានជម្រើសក្នុងការចំណាយ ព្រមទាំងវិនិយោគជាទ្រព្យសម្បត្តិ និងអាជីវកម្មនានាបានទៀតផង ។ ក្នុងករណីដែលមានភាពបន្ទាន់ និងវិបត្តិទាំងឡាយ ប្រាក់សន្សំជួយអ្នកឱ្យអាចឆ្លើយតបបានភ្លាមៗ ហើយការពារអ្នកពីការបាត់បង់ប្រាក់ចំណូល ឬការពារអ្នកពីភាពក្រីក្រ ។

ប្រាក់សន្សំ ដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្រេចបាននូវគោលបំណងហិរញ្ញវត្ថុទាំងឡាយ ។ នេះអាចរាប់បញ្ចូលទាំងគោលបំណងរយៈពេលខ្លី (សប្តាហ៍ ឬខែ) ដូចជាការទិញស្តុក សម្រាប់អាជីវកម្មមួយ ឬការបង់ថ្លៃសាលា ។ គោលបំណងរយៈពេលមធ្យម (១ ទៅ ៣ ឆ្នាំ) ដូចជាចំណាយលើការជួសជុលផ្ទះ ឬទៅសួរសុខទុក្ខគ្រួសារ ឬគោលបំណងរយៈពេលវែង (លើសពី ៣ ឆ្នាំ) ដូចជាដើម្បីទិញផ្ទះមួយ ឬដើម្បីសន្សំទុកសម្រាប់ពេលចូលនិវត្ត ។

## វិធីសន្សំប្រាក់

អ្នកអាចជ្រើសរើសការសន្សំប្រាក់តាមរយៈស្ថាប័នផ្លូវការ ស្ថាប័នពាក់កណ្តាលផ្លូវការ ឬស្ថាប័នក្រៅផ្លូវការ ហើយប្រាក់សន្សំអាចស្ថិតក្នុងទម្រង់ជាសាច់ប្រាក់ ឬមិនមែនសាច់ប្រាក់ ។

ទម្រង់មិនមែនសាច់ប្រាក់គឺ ទ្រព្យសម្បត្តិនានា ដូចជាគ្រឿងអលង្ការ ឬសត្វចិញ្ចឹម ដែលអាចងាយស្រួលប្តូរទៅជាសាច់ប្រាក់ ហើយជាទូទៅរក្សាតម្លៃរបស់វាបាន ។ ដីធ្លីគឺជាទ្រព្យសម្បត្តិមួយប្រភេទ ដែលអ្នកអាចវិនិយោគ ហើយរក្សាទុកការសន្សំប្រាក់របស់អ្នកបាន ។ ដីធ្លីរក្សាតម្លៃរបស់វា ប៉ុន្តែវាពិបាកលក់ និងទិញម្តងទៀត ជាងសត្វចិញ្ចឹម ។

ប្រាក់សន្សំក្រៅផ្លូវការ គឺរាប់បញ្ចូលការសន្សំសាច់ប្រាក់នៅក្នុងផ្ទះ ដែលអ្នកងាយស្រួលយកមក ប្រើប្រាស់បាន ហើយអនុញ្ញាតឱ្យអ្នកជៀសវាងបានពីការចំណាយទៅលើថ្លៃប្រតិបត្តិការទាំងឡាយ ដែលអាចកើតមាននៅពេលធ្វើការសន្សំនៅជាមួយស្ថាប័នផ្លូវការនានា ។ ទម្រង់សន្សំប្រាក់ក្រៅផ្លូវការនេះមានគុណវិបត្តិសំខាន់ពីរយ៉ាងគឺ : ការប៉ុនប៉ងចំណាយប្រាក់កាស និងហានិយភ័យទៅលើចោរកម្ម ។ អ្នកត្រូវតែមានវិន័យរឹងមាំដើម្បីជៀសវាងការចំណាយប្រាក់សន្សំទាំងនេះដោយខ្លួនអ្នកផ្ទាល់ និងដោយសមាជិកគ្រួសារដទៃៗទៀត ។ លើសពីនេះទៅទៀត ការសន្សំប្រាក់នៅក្នុងផ្ទះ គឺមិនអាចរកប្រាក់ការបានឡើយ ហើយវាអាចបាត់បង់តម្លៃរបស់វានៅក្នុងពេលណាមួយខាងមុខ ។

ប្រាក់សន្សំពាក់កណ្តាលផ្លូវការគឺ សំដៅទៅលើអ្នកទទួលទុកប្រាក់បញ្ញើ និងយន្តការសន្សំប្រាក់ជាច្រើនទៀតដោយរាប់បញ្ចូល សមាគមសន្សំប្រាក់និងឥណទានវិលជុំ **(Rotating Credit and Savings Associations, ROSCAs)** ធនាគារភូមិ ក្រុមសាមគ្គី និងក្រុមជួយខ្លួនឯងទាំងឡាយ ។ ទម្រង់ដែលមាន លក្ខណៈសាមញ្ញ និងងាយស្រួលយល់នោះ គឺយន្តការក្រុមដែលលើកទឹកចិត្តឱ្យមានវិន័យ ការពិនិត្យពិច្ច័យ និងការគាំទ្រនៅក្នុងចំណោមសមាជិកនានា ។ គុណសម្បត្តិរបស់ **ROSCAs** គឺថាសមាជិកម្នាក់ៗ នឹងទទួលបានប្រាក់សរុបចំនួនច្រើនក្នុងពេលមួយ ដោយគ្មានការបង់ប្រាក់កម្ចី ឬបង់ប្រាក់ការ ។ ទោះជាយ៉ាងនេះក្តី ចន្លោះខ្វះខាតនោះគឺថា សមាជិកទាំងឡាយនឹងមិនបានទទួលប្រាក់ការរបស់ពួកគេទេ នៅលើចំនួនប្រាក់ដែលពួកគេបានសន្សំ ។ សមាជិកក្រុមជួយខ្លួនឯង ខ្ចីប្រាក់ពីប្រាក់សន្សំរួមគ្នា ដោយមានកាតព្វកិច្ចត្រូវបង់ប្រាក់ការ ប៉ុន្តែពួកគេនឹងបានទទួលភាគលាភនៅអំឡុងពេលណាមួយ ។ ចន្លោះខ្វះខាតរបស់ក្រុមសន្សំប្រាក់នេះ គឺរាប់បញ្ចូលអស្ថេរភាពរបស់ក្រុម ការមិនចុះសម្រុងគ្នានៅក្នុងចំណោមសមាជិកនានា និងលទ្ធភាពទទួលប្រាក់កម្ចីមានកម្រិតតិចតួច ។

ប្រាក់សន្សំផ្លូវការ (ក្នុងប្រព័ន្ធ) មានរាប់បញ្ចូលស្ថាប័នហិរញ្ញវត្ថុ ធនាគារ សហជីពឥណទាន សហករណ៍ ឬស្ថាប័នហិរញ្ញវត្ថុទាំងឡាយ ដែលផ្តល់ឱ្យមានជម្រើសច្រើនយ៉ាងសម្រាប់ការសន្សំប្រាក់ ។ ប្រាក់សន្សំនៅក្នុងស្ថាប័នហិរញ្ញវត្ថុទាំងនេះ ជាទូទៅមានសុវត្ថិភាព ហើយអាចទទួលប្រាក់ការបាន ។ ពួកគេផ្តល់ឱ្យមានគណនីបញ្ញើសន្សំច្រើនប្រភេទទៅតាមតម្រូវការហិរញ្ញវត្ថុខុសៗគ្នា ។ ទោះជាយ៉ាងនេះក្តី មានតម្រូវការមួយចំនួនសម្រាប់ការបើកនិងថែរក្សាគណនី ដូចជាត្រូវមានចំនួនប្រាក់ដាក់ផ្ញើអប្បបរិមា ថ្លៃប្រើប្រាស់សេវា ហើយតម្រូវការដកប្រាក់មកវិញអាចមានតម្លៃខ្ពស់ ។ ចូរពិចារណាចំណុចទាំងនេះ ដោយប្រុងប្រយ័ត្ន ប្រសិនបើអ្នក

ដាក់ប្រាក់ផ្ញើ ឬដកប្រាក់មកវិញជារឿយៗ ។ ម៉ោងធ្វើការដែលមានកំណត់របស់ធនាគារទាំងឡាយ គឺធ្វើឱ្យអ្នកពិបាកទទួលបានប្រាក់កាសភ្លាមៗ នៅក្នុងករណីមានភាពបន្ទាន់ណាមួយ ។ ជាទីបំផុត នៅពេលធនាគារទាំងឡាយបានក្ស័យធន គេបាត់បង់ទំនុកចិត្តទៅលើធនាគារទាំងនោះ ។

## ជម្រើសសម្រាប់ការសន្សំនៅស្ថាប័នហិរញ្ញវត្ថុ

ស្ថាប័នហិរញ្ញវត្ថុផ្សេងៗការទាំងឡាយ ផ្តល់ប្រភេទបញ្ញើសន្សំជាច្រើនយ៉ាង ។

**សៀវភៅប្រាក់បញ្ញើ ឬគណនីបញ្ញើសំចៃ** គឺជាប្រភេទគណនីដែលត្រូវគេប្រើប្រាស់ទូលំទូលាយមួយ សម្រាប់ប្រតិបត្តិការជាទៀងទាត់ ដោយសារតែពេលវេលា និងចំនួនប្រាក់ដាក់សន្សំមានការប្រែប្រួល ។ ការដកប្រាក់គឺជាធម្មតាមានលក្ខណៈបត់បែនផងដែរ ទោះបីជាយ៉ាងនេះក្តី នៅពេលខ្លះអ្នកត្រូវការផ្តល់ដំណឹង ២ ឬ ៣ ថ្ងៃជាមុនដែរ ។ ជាពិសេស អ្នកបានទទួលប្រតិបត្តិការ "មិនបាច់បង់ប្រាក់ " មួយ ចំនួនជារៀងរាល់ខែ តែនឹងត្រូវបង់ប្រាក់សម្រាប់ប្រតិបត្តិការណា ដែលលើសពីចំនួននោះ។ ជាថ្នូរចំពោះការប្រើប្រាស់ប្រតិបត្តិការជាញឹកញាប់នោះ ធនាគារឱ្យការប្រាក់មានកម្រិតទាបសម្រាប់គណនីបញ្ញើសំចៃ ។ ប្រតិបត្តិការគណនី ត្រូវបានតាមដានដោយសៀវភៅសន្សំ ឬ **passbook** ហើយចំនួនប្រាក់អប្បបរិមា ដែលជាធម្មតាតម្រូវឱ្យមានដើម្បីបើកគណនីនោះ ។ គណនីនេះ គឺមានលក្ខណៈសមស្រប នៅពេលអ្នកត្រូវការដាក់ប្រាក់ និងដកប្រាក់ជាទៀងទាត់ ហើយបង្កលក្ខណៈងាយស្រួលដល់ការសន្សំប្រាក់របស់អ្នក ។

**គណនីបញ្ញើសំចៃតាមកិច្ចសន្យា** **(Contractual Savings)** គឺជាទម្រង់ផ្សេងមួយទៀតនៃការសន្សំប្រាក់ ដែលតម្រូវឱ្យអ្នកដាក់ផ្ញើនូវចំនួនកំណត់ណាមួយជាទៀងទាត់ សម្រាប់អំឡុងពេលដែលបានកំណត់ទុកជាមុន ។ ថ្វីបើគណនីបញ្ញើសំចៃតាមកិច្ចសន្យា អាចត្រូវធ្វើឡើងក្នុងវិធីជាច្រើនយ៉ាងក្តី ក៏ការទទួលយកប្រាក់សន្សំមកប្រើប្រាស់វិញនោះ ជារឿយៗមិនត្រូវអនុញ្ញាតឱ្យឡើយ រហូតទាល់តែកិច្ចសន្យាត្រូវបានបញ្ចប់ ហើយអ្នកនឹងត្រូវបង់ប្រាក់ពិន័យ ប្រសិនបើអ្នកដកប្រាក់មុនពេលកំណត់ក្នុងកិច្ចសន្យា ។ គណនីប្រភេទនេះនឹងមានផលប្រយោជន៍ ប្រសិនបើអ្នកមានប្រភពប្រាក់ចំណូលជាទៀងទាត់ ដែលជួយឱ្យអ្នកអាចបំពេញការប្តេជ្ញាចិត្តសន្សំប្រាក់នៅក្នុងអន្តរកាលទៀងទាត់ណាមួយសម្រាប់គោលបំណងអនាគត ។

**គណនីបញ្ញើតាមកាលកំណត់** ទាមទារឱ្យមានចំនួនទឹកប្រាក់ដើម្បីដាក់ផ្ញើសម្រាប់រយៈពេលជាក់លាក់ណាមួយ និងចំនួនប្រាក់ការដូចដែលបានកំណត់ជាមុន ។ ប្រាក់សន្សំនោះ នឹងមិនអាចដកយកមកប្រើប្រាស់វិញ បានទេនៅក្នុងអំឡុងពេលនេះ ប៉ុន្តែជាទូទៅ វាទទួលបានប្រាក់ការខ្ពស់ច្រើនជាងគណនីប្រាក់សន្សំតាមកិច្ចសន្យា ។ អ្នកអាចចាប់អារម្មណ៏នឹងគណនីប្រភេទនេះ ប្រសិនបើអ្នកទទួលបានប្រាក់ដុលសរុប ដែលអ្នកមិនត្រូវការនៅពេលភ្លាមៗនេះទេ ។ អ្នកអាចប្រើប្រាស់គណនីប្រភេទនេះដើម្បីគោលបំណងអនាគតមួយ និងទទួលបានប្រាក់ការជាអតិបរិមា ដែលប្រាក់កាសរបស់អ្នកគឺស្ថិតនៅឆ្ងាយពីដៃសម្រាប់ រយៈពេលមួយ ដូចដែលបានកំណត់ជាមុន ។ អ្នកអាចជ្រើសរើសយករយៈពេលប៉ុណ្ណានោះ គឺអាស្រ័យទៅលើការប៉ាន់ស្មានពេលវេលាណា ដែលអ្នកត្រូវការប្រាក់យកមកប្រើប្រាស់ ។ គណនីបញ្ញើតាមតម្រូវការ គឺ មានពេលវេលាខុសគ្នាពី ៦ ខែ ទៅ ១០ ឆ្នាំ ហើយជាពិសេស បើអ្នកជ្រើសរើសយករយៈពេលកាន់តែវែង អ្នកនឹងបានទទួលអាត្រាប្រាក់ការកាន់តែខ្ពស់ ។

## គន្លឹះសំខាន់សម្រាប់ជ្រើសរើសទីកន្លែងដើម្បីសន្សំប្រាក់

នៅពេលធ្វើការសម្រេចចិត្តយកទីកន្លែងណាមួយដើម្បីសន្សំប្រាក់ ចូរពិចារណានៅលើចំណុចដូចខាងក្រោមនេះ ៖

- **តម្រូវការចំនួនប្រាក់ដាក់ផ្ញើសម្រាប់គណនីសំចៃ** ។ តើត្រូវមានចំនួនប្រាក់អប្បបរិមាមួយ ដែលត្រូវការដើម្បីបើកគណនីនេះទេ ? តើវាតម្រូវឱ្យមានសមតុល្យប្រាក់អតិបរិមាមួយដើម្បីថែរក្សាគណនីនេះដែរឬទេ ? តើគេទទួលយកប្រាក់ផ្ញើតិចតួចដែរឬទេ ? តើចំនួនប្រាក់ដាក់ផ្ញើដែលមានចំនួនខុសគ្នាពីមួយលើក ទៅមួយលើក អាចត្រូវដាក់ផ្ញើបានដែរឬទេ ? តើការដាក់ផ្ញើប្រាក់នេះ អាចត្រូវធ្វើឡើងជារឿយៗបានដែរឬទេ ? តើត្រូវបំពេញបែបបទឯកសារអ្វីខ្លះ ?

- **ល័ក្ខខ័ណ្ឌប្រើប្រាស់** ៖ តើកម្មវិធីសន្សំប្រាក់ជាកាតព្វកិច្ចត្រូវបំពេញ ឬក៏ការសន្សំប្រាក់ជាការស្ម័គ្រចិត្ត ? តើអ្នកត្រូវតែដាក់ចំនួនប្រាក់សន្សំនៅក្នុងចន្លោះពេលទៀងទាត់ណាមួយ ឬក៏សម្រាប់រយៈពេលណាមួយខាងមុខ ? តើល័ក្ខខ័ណ្ឌទាំងនេះចែងពីចំនួនប៉ុន្មានដែលអ្នកត្រូវដាក់សន្សំ និងពេលវេលាដែលអ្នកត្រូវដាក់សន្សំដែរឬទេ ? តើល័ក្ខខ័ណ្ឌទាំងនេះចែងពីចំនួនប៉ុន្មានដែលអ្នកអាចដក ប្រាក់សន្សំ និងពេលវេលាដែលអ្នកអាចដាក់ប្រាក់សន្សំដែរឬទេ ? តើអ្នកអាចដកប្រាក់សន្សំនៅទីណាក៏បាន ដោយគ្មានតម្រូវឱ្យបង់ប្រាក់ពិន័យដែរឬទេ ?

- **តម្លៃ** ៖ តើអ្នកត្រូវបង់ប្រាក់ប៉ុន្មានសម្រាប់ការដាក់ផ្ញើ ការដកប្រាក់ ឬសម្រាប់សៀវភៅសន្សំប្រាក់? ទម្រង់នៃការសន្សំប្រាក់មួយចំនួន អាចធ្វើឱ្យបាត់បងតម្លៃប្រាក់សន្សំនៅអំឡុងពេលអតិផរណា ឬអស្ថេរភាពសេដ្ឋកិច្ច ។ អ្នកចាំបាច់គួរពិចារណាទៅលើតម្លៃទាំងនោះ បើទោះបីតម្លៃនោះមិនពាក់ព័ន្ធនឹងការបង់ប្រាក់ជាក់ស្តែងក្តី ។

- **លទ្ធភាពទទួលបាន ឬងាយស្រួលប្រើប្រាស់** ៖ តើគណនីនេះមានលក្ខណៈងាយស្រួលដែរឬទេ ? តើពេលម៉ោងប្រតិបត្តិការរបស់ស្ថាប័ននោះមានសភាពសមស្របដែរឬទេ ? តើស្ថាប័ននោះស្ថិតនៅឆ្ងាយប៉ុន្មានពីផ្ទះ ឬកន្លែងធ្វើការរបស់អ្នក ? តើប្រតិបត្តិការមានលក្ខណៈរហ័ស និងមានការទុកចិត្តបានដែរឬទេ ? តើគុណភាពសេវាមានសភាពយ៉ាងដូចម្តេចដែរ ? តើបរិយាសនៅទីនោះ មានការកក់ក្តៅ និងមានការរាក់ទាក់ដែរឬទេ ? តើអតិថិជនត្រូវចូលក្នុងជួរដ៏វែងនៅពេលដាក់ផ្ញើ ឬដកប្រាក់ដែរឬទេ ? តើព័ត៌មានអំពីគណនី ងាយស្រួលរកឃើញដែរឬទេ ? តើគណនីនោះផ្តល់របាយការណ៍ជាបន្តបន្ទាប់ដែរឬទេ ? តើវាងាយស្រួលយល់ដែរឬទេ ? តើនីតិវិធីនានាសម្រាប់ការ ដាក់ពាក្យសុំបើកគណនី ងាយស្រួលធ្វើតាមដែរឬទេ ? តើវាមានបណ្តាញ **ATM** ដែរឬទេ ?

- **សុវត្ថិភាព** ៖ តើស្ថាប័ននោះមានកេរ្តិ៍ឈ្មោះយ៉ាងណាដែរ ? តើស្ថាប័ននោះមានការធានារ៉ាប់រង ឬទ្រព្យធានាផ្សេងៗទៀតដើម្បីផ្តល់សុវត្ថិភាពដល់ប្រាក់សន្សំដែរឬទេ ? តើប្រតិបត្តិការនានាតាមទូរស័ព្ទ ឬតាមមធ្យោបាយអេឡិចត្រូនិកមានសុវត្ថិភាពដែរឬទេ ? តើធនាគារ ឬសាខារបស់វា មានទីតាំងស្ថិតនៅកន្លែងដែលមានសុវត្ថិភាពដែរឬទេ ?

- **ការផ្ទេរបញ្ជី** ៖ តើការដកប្រាក់ពីគណនីមានលក្ខណៈងាយស្រួលយ៉ាងដូចម្ដេចដែរ ? តើអាចដកប្រាក់ទាំងអស់បានដែរឬទេ ? តើត្រូវបង់ថ្លៃដែរឬទេ ប្រសិនបើមានការដកប្រាក់មុនពេលកំណត់ជាក់លាក់ណាមួយ ?

- **ប្រាក់ការ** ៖ តើប្រាក់សន្សំរបស់អ្នកបានទទួលប្រាក់ការដែរឬទេ ? ប្រសិនបើបាន តើចំនួនប៉ុន្មាន? តើប្រាក់ការត្រូវបានទទួលដោយរបៀបណា និងនៅពេលណា ? តើអត្រាប្រាក់ការនោះមានភាពខុសប្លែកគ្នាយ៉ាងណាដែរ ជាមួយនឹងប្រភេទបញ្ញើដទៃៗទៀត ឬជាមួយនឹងផែនការសន្សំផ្សេងៗទៀត ?

## វិធីធ្វើផែនការសន្សំប្រាក់

ផែនការសន្សំប្រាក់ គឺជាឧបករណ៍សំខាន់មួយសម្រាប់ការគ្រប់គ្រងប្រាក់កាស ដើម្បីសម្រេចគោលបំណងហិរញ្ញវត្ថុនានាក្នុងរយៈពេលខ្លី ពេលមធ្យម និងពេលវែង ។ ដើម្បីធ្វើផែនការសន្សំប្រាក់មួយ ចូរអនុវត្តទៅតាមជំហាននានាដូចខាងក្រោមនេះ ៖

១. បង្កើតគោលបំណងសន្សំប្រាក់
២. គណនាចំនួនប្រាក់ដែលអ្នកត្រូវសន្សំសម្រាប់អំឡុងពេលណាមួយខាងមុខ ដើម្បីសម្រេចគោលបំណងសន្សំ ប្រាក់របស់អ្នក ។ បង្កើតចំណុចជាទិសដៅសម្រាប់ការសន្សំប្រាក់ ។
៣. គណនាចំនួនប្រាក់ប៉ុន្មានដែលអ្នកអាចរកបាននៅអំឡុងពេលណាមួយខាងមុខ ចំនួនប្រាក់រកបានជាទៀងទាត់ (ឬចំនួនប្រាក់រកបានមិនប្រក្រតី) ព្រមទាំងគណនាចំនួនប្រាក់ប៉ុន្មានដែលអ្នកគិតថានឹងដាក់សន្សំជាទៀងទាត់ ។
៤. កំណត់រកមុខចំណាយណាមួយដែលអ្នកអាចកាត់ចោលបាន (ឧទាហរណ៍ដូចជា ការជួលកាសែតវីឌីអូ ការទិញបារី ឬថ្លៃទឹកតែ ) ហើយបង្វិលប្រាក់ទាំងនេះសម្រាប់ការសន្សំរបស់អ្នកវិញ ។
៥. សម្រេចយកទីកន្លែងណាមួយដែលអ្នកនឹងដាក់ប្រាក់សន្សំ ។ កំណត់រកប្រភេទបញ្ញើនានាដែលអាចមាន និងដើម្បីដាក់ប្រាក់សន្សំ ព្រមទាំងពិចារណាលើគុណសម្បត្តិ និងគុណវិបត្តិនានារបស់ប្រភេទនីមួយៗនោះផង ។
៦. ធ្វើផែនការលើចំនួនប្រាក់ប៉ុន្មាន និងរយៈពេលញឹកញាប់ប៉ុណ្ណាដែលអ្នកនឹងដាក់ប្រាក់សន្សំ ។ ឧទាហរណ៍ អ្នកអាចដាក់ប្រាក់មួយចំនួនទៅក្នុងស្រោមសំបុត្រ នៅពេលណាដែលអ្នកបានទទួលប្រាក់ ឬនៅចុងថ្ងៃនីមួយៗនៃការធ្វើអាជីវកម្មរបស់អ្នក ហើយរក្សាវាទុកនៅកន្លែងសុវត្ថិភាពមួយរង់ចាំរហូតទាល់តែអ្នកអាចយកវាទៅផ្ញើនៅធនាគារបាន ។ ទៅធនាគារនៅថ្ងៃណាមួយដូចដែលបានកំណត់ទុករៀងរាល់សប្ដាហ៍ ឬរៀងរាល់ខែ ។ ប្រសិនបើអ្នកជានិយោជិតបានទទួលប្រាក់បៀវត្សរ៍ ហើយនិយោជករបស់អ្នកបានបង់ប្រាក់ខែតាមរយៈធនាគារ ដូច្នេះអ្នកត្រូវពិចារណាដើម្បីកាត់ប្រាក់មួយចំនួនពីមូលប្បទានប័ត្ររបស់អ្នក ដែលជាការដាក់ផ្ញើជាស្វ័យប្រវត្តិទៅក្នុងគណនីបញ្ញើសំចៃរបស់អ្នក ។

៧. តាមដានប្រាក់សន្សំរបស់អ្នក ។ ត្រួតពិនិត្យមើលជាទៀងទាត់លើការវិវឌ្ឍឆ្ពោះទៅរកចំណុចទិសដៅនៃការសន្សំរបស់អ្នក ដោយការឆែកមើលចំនួនប្រាក់ដែលអ្នកបានសន្សំ និងចំនួនប្រាក់ប៉ុន្មានទៀតដែលនឹងត្រូវសន្សំដើម្បីឱ្យបានសម្រេចគោលបំណងរបស់អ្នក ។ ពិនិត្យមើលរបាយការណ៍ធនាគារ សៀវភៅសន្សំ ឬប្រភពព័ត៌មានផ្សេងៗទៀតស្តីពីការសន្សំរបស់អ្នក ។

## វិធីសាស្ត្រដែលបានមកពីបទពិសោធន៍សម្រាប់ការសន្សំប្រាក់ (Rules of Thumb for Savings)

ក្នុងខណៈដែលមានគោលការណ៍ជាមូលដ្ឋានសំរាប់ការគ្រប់គ្រងប្រាក់កាស ហើយអាចអនុវត្តទៅលើបុគ្គលម្នាក់ៗបាន ដូច្នេះសេចក្តីសម្រេចនានាដើម្បីធ្វើការសន្សំ ឬការប្រើប្រាស់ គឺអាស្រ័យជាសំខាន់ទៅលើកម្រិតប្រាក់ចំណូលរបស់អ្នក លទ្ធភាពទទួលបានប្រាក់កម្ចី លទ្ធភាពប្រើប្រាស់ប្រភេទបញ្ញើសមស្របនានា និងវិន័យលើខ្លួនឯង ។ ទោះជាយ៉ាងណាក៏ដោយ នៅមានវិធីសាស្ត្រដែលបានមកពីបទពិសោធន៍មួយចំនួន ហើយអ្នកអាចយកទៅប្រើប្រាស់ ដើម្បីធ្វើសេចក្តីសម្រេចចិត្តអំពីការសន្សំប្រាក់ និងការប្រើប្រាស់ថវិកា។

- សន្សំនៅពេលអ្នករកប្រាក់បាន ។
- សន្សំប្រាក់ឱ្យបានច្រើនតាមដែលអ្នកអាចធ្វើបាន ហើយសន្សំឱ្យបានឆាប់រហ័សតាមដែលអ្នកអាចធ្វើបាន ។ សន្សំប្រាក់កាន់តែច្រើន ជីវភាពរបស់អ្នកកាន់តែប្រសើរ ។
- ព្យាយាមដាក់ប្រាក់សន្សំចំនួន ១០% នៃប្រាក់ចំណូលរបស់អ្នក បើទោះបីអ្នកមិនត្រូវការទិញ ឬការវិនិយោគជាក់លាក់ណាមួយក៏ដោយ ជាមួយនឹងប្រាក់សន្សំនេះ ។
- ដកប្រាក់ចំនួន ១០% ពីប្រាក់ចំណូលរបស់អ្នកសម្រាប់ការសន្សំ មុនពេលអ្នកធ្វើអ្វីណាមួយផ្សេងទៀត ។ ប្រសិនបើអ្នកមិនអាចដកប្រាក់ចំនួន ១០% នេះបានទេ ចូរដកប្រាក់ចំនួនតិចតួច ប៉ុន្តែត្រូវសន្សំនូវចំនួនណាមួយ ។
- គណនាចំនួនប្រាក់របស់អ្នកដែលអាចកើនឡើងនៅពេលណាមួយខាងមុខ ប្រសិនបើអ្នកធ្វើការសន្សំជាទៀងទាត់នៅក្នុងគណនីមួយដែលអាចបានទទួលប្រាក់ការ ។
- កុំយកប្រាក់ជាប់នឹងខ្លួនចំនួនច្រើន ជៀសវាងការប៉ុនប៉ងចំណាយណាមួយ !
- ចាយវាយដោយប្រុងប្រយ័ត្ន ។ ប្រសិនបើអ្នកទិញវត្ថុធំដុំនានា ចូរពិចារណាថាតើ វត្ថុទាំងនោះ នឹង-មានតម្លៃប៉ុន្មាន ប្រសិនបើអ្នកលក់វាចេញវិញនោះ ? ចូរស្វែងរកឱកាសនានាដើម្បីសន្សំប្រាក់ដោយការទិញវត្ថុដែលមិនងាយខូចគុណភាពជាចំនួនដុល ។
- ទូទាត់បំណុលនានារបស់អ្នក ។ មានអ្នកខ្លះផ្តល់មតិថា អ្នកត្រូវសងបំណុលរបស់អ្នកសិន មុនពេលអ្នកធ្វើការសន្សំ រីឯអ្នកខ្លះទៀតផ្តល់មតិថា ត្រូវធ្វើការសន្សំក្នុងខណៈពេលកំពុងសងបំណុល ពីព្រោះថា វាមានសារៈសំខាន់ដើម្បីចាប់ផ្តើមកសាងទ្រព្យសម្បត្តិឱ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន ។ ជម្រើសនេះអាស្រ័យទៅលើអាទិភាព ស្ថានភាព និងមធ្យោបាយនានារបស់បុគ្គល ម្នាក់ៗ ។
- សន្សំសម្រាប់ការចំណាយទៅលើជីវភាពប្រចាំថ្ងៃសម្រាប់រយៈពេលពី ៣ ទៅ ៦ ខែទៅក្នុងថវិកាសំរាប់ពេលបន្ទាន់ នៅគ្រប់ពេលទាំងអស់ ។ គេអាចប្រើប្រាស់វាក្នុងករណីមិនមានការងារធ្វើ មានជម្ងឺ

ដែលមិនបានគ្រោងទុកជាមុន និងដើម្បីដោះស្រាយសេចក្តីត្រូវការនៅពេលមានភាពបន្ទាន់ដទៃៗទៀត ។ ប្រាក់សន្សំសម្រាប់ពេលមានភាពបន្ទាន់នានា នឹងជួយកាត់បន្ថយសេចក្តីបារម្ភរបស់អ្នក ។

- រក្សាទុកថវិកាសំរាប់ពេលមានភាពបន្ទាន់នៅក្នុងគណនីដោយឡែកមួយ ។ ចូរបើកគណនីពីរគឺ គណនីទីមួយសម្រាប់ពេលមានភាពបន្ទាន់ដែលងាយស្រួលដកយកមកប្រើប្រាស់វិញ ហើយមិនមានការបង់ប្រាក់ពិន័យសម្រាប់ការដកនោះ និងគណនីមួយទៀតសម្រាប់ប្រាក់សន្សំ ដើម្បីគោលបំណងនានាដែលពិបាកដកយកមកប្រើប្រាស់វិញ (ហើយដូច្នេះ មិនមានការប៉ុនប៉ងដកប្រាក់យកមកប្រើប្រាស់វិញ) ។ ការរក្សាទុកប្រាក់សន្សំ " នៅឆ្ងាយពីដៃ " គឺមានសារៈសំខាន់ណាស់ ។

## ឃ. ការគ្រប់គ្រងបំណុល : ដោះស្រាយដោយយកចិត្តទុកដាក់

នៅពេលអ្នកខ្ចីប្រាក់ អ្នកចូលទៅក្នុងពិភពនៃបំណុល ។ បំណុលមានច្បាប់ មានអ្នកលេង និងមានយុទ្ធសាស្រ្តជាច្រើន ។ យុទ្ធសាស្រ្តមួយដ៏ប្រសើរបំផុតនៅក្នុងបណ្តាយុទ្ធសាស្រ្តនានា ដែលអាចយកទៅអនុវត្តបានសម្រាប់ខ្លួនអ្នកនោះ គឺអ្នកត្រូវរៀនពីវិធីប្រើប្រាស់បំណុលឱ្យបានប្រសើរ ។

### សមាសភាពឥណទាន

ប្រសិនបើអ្នកខ្ចីប្រាក់ពីធនាគារមួយ ឬពីអ្នកឱ្យខ្ចីប្រាក់ណាម្នាក់ អ្នកនឹងស្តាប់ឮល័ក្ខខ័ណ្ឌនានាដែលភ្ជាប់ជាមួយនឹងប្រាក់កម្ចីរបស់អ្នកដូចតទៅនេះ ។ វាមានសារសំខាន់ក្នុងការយល់ដឹងអំពីអត្ថន័យល័ក្ខខ័ណ្ឌនីមួយៗសម្រាប់ប្រាក់កម្ចីជាក់លាក់របស់អ្នក ។

- ទំហំប្រាក់ឥណទាន : ចំនួនប្រាក់ដែលអ្នកខ្ចី ។
- រយៈពេលកម្ចី :អំឡុងពេលដែលអ្នកមានដើម្បីប្រើប្រាស់សាច់ប្រាក់កម្ចី និងការសង។
- អាត្រាការប្រាក់ : ភាគរយនៃចំនួនប្រាក់កម្ចីទាំងអស់ដែលត្រូវបង់ ដោយអ្នកខ្ចីប្រាក់សម្រាប់ប្រើប្រាស់ប្រាក់ដែលបានខ្ចីនោះ ។ ប្រាក់ការជាទូទៅត្រូវបង់ជាប្រចាំខែ ។
- ប្រាក់ឈ្នួល : ថ្លៃរដ្ឋបាលនានាដែលត្រូវបង់បន្ថែមលើប្រាក់ការ ដែលជាទូទៅត្រូវបង់ក្នុងពេលតែម្តងខណៈដែលអ្នកទៅខ្ចីប្រាក់ ។
- អំឡុងពេលអនុគ្រោះ : អំឡុងពេលមួយបន្ទាប់ពីទទួលបានប្រាក់កម្ចី និងមុនពេលសងលើកដំបូង ។
- កាលវិភាគសងប្រាក់ : ភាពញឹកញាប់នៃការសងប្រាក់កម្ចី (ឧ. ប្រចាំសប្តាហ៍ រៀងរាល់ពីរ សប្តាហ៍ម្តង រៀងរាល់ខែ ) ។

### ហេតុអ្វីកំត្រូវខ្ចី ?

យើងត្រូវការខ្ចីប្រាក់សម្រាប់មូលហេតុជាច្រើន។ មូលហេតុភាគច្រើន គឺយើងខ្ចីប្រាក់ ដើម្បី:

១. ធ្វើវិនិយោគ

២. ឆ្លើយតបនឹងពេលមានភាពបន្ទាន់ដែលមិនបានគ្រោងទុក

៣. ដោះស្រាយសេចក្តីត្រូវការចាំបាច់ក្នុងគ្រួសារ (ការទិញវត្ថុអ្វីមួយដែលយើងមិនមានប្រាក់គ្រប់គ្រាន់នៅពេលបច្ចុប្បន្ន) ។

ប្រាក់កម្ចីផ្តល់ដល់អ្នកនូវចំនួនប្រាក់ដុលមួយដែលអ្នកអាចពិបាករក ។ វាជួយអ្នកឱ្យអាចឆក់យកឱកាសអាជីវកម្មនានា ឆ្លើយតបនឹងពេលមានភាពបន្ទាន់ទាំងឡាយ ធ្វើការជួសជុលផ្ទះ ឬការទិញអ្វីមួយ ដែលអ្នកត្រូវការ ។ ប៉ុន្តែការខ្ចីប្រាក់អាចត្រូវបង់សោហ៊ុយខ្ពស់ ហើយមានកាតព្វកិច្ចជាច្រើនដើម្បីសង ប្រាក់កម្ចីនេះទាន់ពេលវេលា ។ ដោយសារមូលហេតុទាំងនេះ ការទទួលប្រាក់កម្ចី គឺមិនដូចការប្រើប្រាស់ប្រាក់ផ្ទាល់ខ្លួនរបស់អ្នកដែលអ្នកអាចមានតាមរយៈប្រាក់ខែ ប្រាក់កម្រៃអាជីវកម្ម ឬប្រាក់សន្សំនោះឡើយ ។ តារាងខាងក្រោមនេះគឺបង្ហាញពីគុណសម្បត្តិ និងគុណវិបត្តិនានានៃការទទួលយកប្រាក់កម្ចី ។

| | **ការប្រើថវិកាកម្ចី** | **ប្រើថវិកាប្រាក់របស់អ្នក** |
|---|---|---|
| **គុណសម្បត្តិ** | - អ្នកអាចមានលទ្ធភាពទទួលប្រាក់គ្រប់ចំនួន ដែលច្រើនជាងប្រាក់សន្សំ ។<br>- អ្នកទទួលប្រាក់បានលឿន នៅពេលអ្នកត្រូវការវាសម្រាប់ភាពបន្ទាន់នានា ។ | - អ្នកជៀសផុតពីការចំណាយផ្សេងៗសំរាប់ខ្ចីប្រាក់ ។<br>- អ្នកមានសេរីភាពប្រើប្រាស់ប្រាក់របស់អ្នកតាមដែលចិត្តចង់ ។<br>- អ្នកមានការប្រឈមមុខនឹងហានិយភ័យតិចតួច នៅពេលអ្នកផ្គត់ផ្គង់ថវិកាដល់អាជីវកម្មបន្ថែមបន្តិចម្តងៗ ដែលពឹងផ្អែកលើលទ្ធភាពដែលអ្នកអាចវិនិយោគ ។<br>- អ្នកជៀសផុតពីកាតព្វកិច្ចនៃការសងប្រាក់កម្ចីនៅពេលអនាគត ។ |
| **គុណវិបត្តិ** | - អ្នកត្រូវបង់ថ្លៃចំណាយផ្សេងៗសំរាប់ការខ្ចីនេះ (ប្រាក់ការ ថ្លៃរដ្ឋបាល និងពេលវេលាស្នើសុំខ្ចី) ។<br>- អ្នកទទួលខុសត្រូវចំពោះការសងប្រាក់កម្ចី របស់អ្នកឱ្យទាន់ពេលវេលា និងប្រឈមមុខនឹងការផាកពិន័យចំពោះការសងយឺតយ៉ាវ ។<br>- អ្នកត្រូវបំពេញទៅតាមតម្រូវការនានារបស់សមាជិកភាពក្នុងក្រុម (ចូលរួមប្រជុំទាន់ពេល ។ល។) ប្រសិនបើប្រាក់កម្ចីនោះត្រូវធ្វើឡើងទៅតាមរយៈក្រុម ។ | - អ្នកខ្វះលទ្ធភាពដើម្បីទទួលបានដើមទុនដែលត្រូវការ ។<br>- អាជីវកម្មរបស់អ្នករីកចម្រើនយឺត ។<br>- លទ្ធភាពឆ្លើយតបទៅនឹងឱកាសនានាមានកំរិត ។ |

## ហានិភ័យ

បំណុលគឺជាហានិភ័យមួយ សម្រាប់អ្នកខ្ចីប្រាក់ម្នាក់ៗ ។ ប្រសិនបើអ្នកមិនអាចសងបំណុលរបស់អ្នកបានទេ វានឹងមានផលវិបាកជាច្រើន ! បើទោះបីជាមានការធ្វើផែនការដោយប្រុងប្រយ័ត្នក៏ដោយ អ្នកអាចមានបញ្ហាជាច្រើនក្នុងការសងប្រាក់កម្ចី ។ មានព្រឹត្តិការណ៍ជាច្រើនដែលកើតឡើងដោយមិនបានគ្រោងទុក ដែលអាចធ្វើឱ្យហានិភ័យនេះឱ្យក្លាយជាការពិតបាន ដូចជា :

- នៅពេលប្រាក់ចំណូលរបស់អ្នកត្រូវចាយវាយទៅលើជម្ងឺ ឬពេលអវត្តមានពីការងារ
- នៅពេលការធ្វើវិនិយោគប្រាក់កម្ចីជួបនឹងការខាតបង់
- នៅពេលចំណាយក្នុងគ្រួសារ និងចំណាយក្នុងអាជីវកម្មមានចំនួនច្រើនជាងប្រាក់ចំណូលរបស់អ្នក
- នៅពេលមានព្រឹត្តិការណ៍កើតឡើង ដោយមិនបានគ្រោងទុក បង្កើតឱ្យមានតម្រូវការសាច់ប្រាក់ជាបន្ទាន់ (ឧ. ដើម្បីបង់ថ្លៃវេជ្ជបណ្ឌិត ថ្លៃបុណ្យសព ។ល។)

ស្ថានភាពដូច្នេះ គឺកើតមានជាទូទៅនៅក្នុងចំណោមជនក្រីក្រ ។ ប្រាក់កម្ចីត្រូវតែសងវិញ ដោយមិនគិតថាអ្នកគឺជាជនក្រីក្រ ឬជាអ្នកមានទ្រព្យធនឡើយ ។ ប្រសិនបើអ្នកប្រឈមមុខនឹងការលំបាកក្នុងការសងប្រាក់កម្ចីរបស់អ្នកនោះ តើអ្នកមានជម្រើសអ្វីខ្លះ ?

ដើម្បីទទួលបានប្រាក់កាសសម្រាប់ទូទាត់ប្រាក់កម្ចីនានា អ្នកចាំបាច់ត្រូវកាត់បន្ថយការចំណាយ ឬ ត្រូវលក់វត្ថុអ្វីមួយដែលមានតម្លៃ ។ អ្នកអាចស្នើសុំឱ្យមិត្តភ័ក្តិ និងបងប្អូនទាំងឡាយជួយអ្នក ប៉ុន្តែវាមានហានិភ័យដោយសារអ្នក " ប្រើប្រាស់ " សន្តានចិត្តរបស់គេដើម្បីខ្លួនអ្នក ហើយនឹងអាចបាត់បង់កេរ្តិ៍ឈ្មោះ ល្អរបស់អ្នក ។

ប្រសិនបើអ្នកខកខានមិនបានសងប្រាក់កម្ចីទាំងព្រមគ្នាទេ ឬមិនបានគោរពតាមកិច្ចសន្យា តើមានផលវិបាកអ្វីខ្លះ ? អ្នកអាចបាត់បង់លទ្ធភាពទទួលបានប្រាក់កម្ចីពីប្រភពឥណទាននានានៅពេលអនាគត ។ អ្នកអាចធ្វើឱ្យទំនាក់ទំនងជាមួយសមាជិកក្រុមឥណទានរបស់អ្នក មានភាពល្អក់កករ អ្នកអាចឈឺចាប់ពីការអាម៉ាស់មុខក្នុងសហគមន៍ ហើយបាត់បង់សន្តានចិត្តល្អពីមិត្តភ័ក្តិ និងក្រុមគ្រួសាររបស់អ្នក ។ ការមិនបានគោរពទៅតាមកិច្ចសន្យាសងប្រាក់កម្ចី អាចបណ្តាលឱ្យបាត់បង់ទំនុកចិត្ត និងការគោរពខ្លួនឯង ។

## ខ្ចីប្រាក់ដោយឈ្លាសវៃ

ហានិភ័យទាំងឡាយដែលកើតឡើងពីការទទួលប្រាក់កម្ចី ជួយឱ្យអ្នកគិតពិចារណាអំពីការខ្ចីប្រាក់ដោយប្រុងប្រយ័ត្ន នៅពេលណា និងចំនួនប្រាក់ប៉ុន្មានដែលត្រូវខ្ចី ។ ប្រាក់កម្ចីទាំងឡាយអាចជួយ ឱ្យបើកទ្វារថ្មីៗបាន ប៉ុន្តែអ្នកចាំបាច់ត្រូវយល់ដឹងថា នៅពេលណាដែលទទួលយកប្រាក់កម្ចី គឺជាការសម្រេចចិត្តដ៏ប្រុងប្រយ័ត្នមួយ ។ ការប្រើប្រាស់ប្រាក់កម្ចីជាដើមទុនល្អសម្រាប់ការធ្វើវិនិយោគទៅក្នុងអាជីវកម្ម មានរាប់បញ្ចូលដូចខាងក្រោមនេះ :

- ការទិញសំភារៈ និងវត្ថុធាតុដើម ជាចំនួនដុលនៅតម្លៃទាប ដែលនឹងបង្កើនប្រាក់ចំណេញបាន ។

- ការទិញទ្រព្យសម្បត្តិដែលមានផលិតភាពដូចជា គ្រឿងម៉ាស៊ីនទាំងឡាយដែលជួយអ្នកឱ្យបង្កើនផលិតភាព ។ ឧទាហរណ៍ : ស្នប់បូមទឹកដែលជួយអ្នកឱ្យបង្កើនទិន្នផល ឬគ្រឿងឧបករណ៍សម្រាប់កែឆ្នៃម្ហូបអាហារ ដែលបន្ថែមតម្លៃទៅលើកសិផលណាមួយ ។
- ការទិញទ្រព្យសម្បត្តិណាមួយ ដែលជួយឱ្យអាជីវកម្មថ្មីថ្មោង អាចដំណើរការទៅបាន ដូចជាទូរស័ព្ទមួយគ្រឿង ឬទូត្រជាក់មួយគ្រឿង ។

ក្រៅអំពីប្រាក់កម្ចីសម្រាប់កិច្ចការអាជីវកម្មទាំងនេះ គ្រួសារទាំងឡាយ ជួនកាលត្រូវការខ្ចីប្រាក់សម្រាប់ពេលមានភាពបន្ទាន់នានា ។ វាជាប្រាក់កម្ចីប្រកបដោយហានិភ័យ ពីព្រោះថាវាមិនបាននាំមកនូវប្រាក់ចំណូលបន្ថែម ដើម្បីយកទៅទូទាត់ប្រាក់កម្ចីទាំងនោះឡើយ ។ ប៉ុន្តែ នៅក្នុងករណីជាច្រើន ផលវិបាកនៃការមិនខ្ចីប្រាក់នៅក្នុងពេលដែលសមាជិកគ្រួសារណាម្នាក់ត្រូវឈឺថ្កាត់ ឬបានទទួលគ្រោះថ្នាក់ណាមួយនោះ អាចមានសភាពអាក្រក់ជាងការដែលខ្ចីប្រាក់ទៅទៀត ។

| **ការប្រើប្រាស់បំណុល** | **បំណុលល្អ** | **បំណុលអាក្រក់** |
|---|---|---|
| ការទិញសំភារៈសម្រាប់កិច្ចការអាជីវកម្ម | ទ្រព្យឬសំភារៈដែលបានទិញមានអាយុកាលប្រើប្រាស់យូរអង្វែងសម្រាប់ទូទាត់ទៅឱ្យម្ចាស់បំណុល ។ ចំណូលដែលរកបានពីទ្រព្យនោះ គឺខ្ពស់ជាងចំណាយទៅលើប្រាក់កម្ចី ។ | បំណុលគឺនៅតែជាប់ជំពាក់ ក្រោយពីទ្រព្យនោះត្រូវអស់អាយុកាលប្រើប្រាស់ ហើយខូចខាតឬប្រាក់ចំណូលពីទ្រព្យសម្បត្តិនោះមានចំនួនតិចតួចជាងថ្លៃប្រាក់កម្ចី ។ |
| ដើមទុនបង្វិល | ប្រាក់កម្ចីអាចឱ្យអ្នកចាប់យកឱកាសអាជីវកម្មណាមួយ ដែលអាចរកកម្រៃគ្រប់គ្រាន់ដើម្បីសងប្រាក់កម្ចីវិញ និងមានប្រាក់មួយចំនួននៅសេសសល់ ។ ប្រាក់កម្ចី ដែលជួយឱ្យអ្នកអាចសន្សំជាទុន ឬជាសារពើភ័ណ្ឌផ្សេងៗ ដូច្នេះវាជួយបង្កើនប្រាក់ចំណូលរបស់អ្នកពីការលក់ផលិតផលសម្រេច ។ | - អ្នកមិនអាចរកប្រាក់ចំណូលគ្រប់គ្រាន់ដើម្បីសងប្រាក់កម្ចី ។<br>-អ្នកមានប្រភពផ្គត់ផ្គង់ថវិកាផ្សេងៗទៀត ដែលមិនសូវយកតម្លៃថ្លៃ ។<br>-អ្នកមិនអាចទទួលបានប្រាក់កម្ចីទាន់ពេលដើម្បីទាញយកផលប្រយោជន៍ឱ្យបានពេញលេញពីឱកាសជាក់លាក់ណាមួយ ។ |
| សេចក្តីត្រូវការចាំបាច់ក្នុងគ្រួសារ | | បំណុលគឺនៅតែជាប់ជំពាក់ ក្រោយពីប្រាក់កម្ចីត្រូវបានប្រើប្រាស់រួចហើយ ។ ប្រាក់កម្ចីមិនបានបង្កើតប្រាក់ចំណូល ដើម្បីយកទៅទូទាត់បំណុលឡើយ ។ |
| កម្ចីសម្រាប់ពេលមានភាពបន្ទាន់ | ប្រាក់កម្ចីជួយអ្នកដោះស្រាយបញ្ហាភ្លាមៗដោយមិនបង្កឱ្យមានការលំបាកហួសហេតុ ។ | រយៈពេលសំរាប់សងប្រាក់កម្ចីមានកំណត់ច្បាស់លាស់ មិនអាចបត់បែនទៅតាមសមត្ថភាពសងរបស់អ្នក ។ |

## ថ្លៃឈ្នួលខ្ចីប្រាក់

ថ្លៃឈ្នួលដែលកើតមានចំពោះប្រាក់កម្ចីសំខាន់ជាងគេនោះ គឺប្រាក់ការដែលត្រូវបង់ ។ ជាធម្មតា វាត្រូវគេគណនាជាចំនួនភាគរយនៃចំនួនប្រាក់កម្ចីសរុប ហើយអ្នកត្រូវសងវារៀងរាល់ខែ ដែលជាផ្នែកមួយនៃការសងប្រាក់កម្ចី ។ លើសពីនេះទៅទៀត មានអ្នកឱ្យខ្ចីប្រាក់ជាច្រើនតម្រូវឱ្យអ្នកបង់ថ្លៃរដ្ឋបាល ដែលជាធម្មតាអ្នកត្រូវបង់តែមួយលើកទេ គឺពេលដែលអ្នកទទួលយកប្រាក់កម្ចីនោះ ។ អ្នកត្រូវបង់ប្រាក់ឈ្នួល និងប្រាក់ការដោយផ្ទាល់ទៅឱ្យអ្នកផ្តល់ប្រាក់ឱ្យខ្ចី ។ "ថ្លៃឈ្នួលខ្ចីប្រាក់" ដោយផ្ទាល់ទាំងនេះ គឺជាធម្មតាត្រូវបង់ជាចំនួនសាច់ប្រាក់ ។

ប៉ុន្តែ នៅមានចំណាយជាច្រើនផ្សេងទៀតដែលកើតមានចំពោះការខ្ចីប្រាក់ ដែលអ្នកអាចមិនសូវចាប់អារម្មណ៍ទេ ។ ជួនកាល ការស្នើសុំខ្ចីប្រាក់ និងការទៅទទួលយកប្រាក់កម្ចី បង្ខំអ្នកឱ្យចាយវាយ សម្រាប់ការធ្វើដំណើរទៅចូលរួមអង្គប្រជុំនានា ឬទៅធនាគារដើម្បីបំពេញទម្រង់ស្នើសុំខ្ចី ។ សកម្មភាពទាំងនេះអាចតម្រូវឱ្យអ្នកត្រូវចាកចោលអាជីវកម្មរបស់អ្នក បង្ខំឱ្យអ្នកបិទទ្វារអាជីវកម្ម ឬបង្ខំឱ្យអ្នកជួលនរណាម្នាក់ដើម្បី "មើលការខុសត្រូវហាង" ក្នុងពេលដែលអ្នកមិននៅ ។ ថ្វីបើ "ចំណាយប្រយោល" ទាំងនេះអាចមិនមែនជាផ្នែកមួយនៃការសងសាច់ប្រាក់កម្ចីក្តី តែវាជាចំណាយជាក់ស្តែង ហើយអ្នកគួរពិចារណានៅពេលធ្វើការជ្រើសរើសអ្នកឱ្យខ្ចីប្រាក់ណាម្នាក់ ។

## ការជ្រើសរើសអ្នកឱ្យខ្ចីប្រាក់

ថ្លៃឈ្នួលប្រាក់កម្ចី គឺខុសគ្នាដោយអាស្រ័យលើប្រភេទប្រាក់កម្ចីដែលអ្នកស្វែងរក ហើយនិងគោលការណ៍នានារបស់អ្នកឱ្យខ្ចីប្រាក់ ដែលទាក់ទិននឹងអាត្រាការប្រាក់ ថ្លៃឈ្នួល តម្រូវការសន្សំប្រាក់ និងទ្រព្យបញ្ចាំ។ មុនពេលអ្នកខ្ចីប្រាក់ ចូរប្រៀបធៀបថ្លៃចំណាយសម្រាប់ប្រាក់កម្ចី ដែលអ្នកចង់បាននៅក្នុងចំណោម អ្នកឱ្យខ្ចីមួយចំនួន ។

ការជ្រើសរើសអ្នកឱ្យប្រាក់ខ្ចី គឺមិនមែនគ្រាន់តែពិនិត្យទៅលើថ្លៃចំណាយ សម្រាប់ប្រាក់កម្ចីប៉ុណ្ណោះទេ ។ ប៉ុន្តែ អ្នកអាចពិចារណាទៅលើចំណុចមួយចំនួនទៀត ដូចខាងក្រោមនេះ ។

- ទីតាំង (តើអ្នកឱ្យប្រាក់ខ្ចីស្ថិតនៅជិតផ្ទះ ឬជិតទីតាំងអាជីវកម្មរបស់អ្នកដែរឬទេ ?)
- ប្រភេទប្រាក់កម្ចី (តើស្ថាប័នហិរញ្ញវត្ថុផ្តល់ប្រភេទប្រាក់កម្ចី ឬសេវាសន្សំប្រាក់នានាដែលធ្វើឱ្យអ្នកចាប់អារម្មណ៍ដែរឬទេ ?)
- សេវាបម្រើអតិថិជន (តើអ្នកមានអារម្មណ៍កក់ក្តៅដែរឬទេ ជាមួយនឹងស្ថាប័នហិរញ្ញវត្ថុនោះ ? តើបុគ្គលិកនៅទីនោះមានភាពរាក់ទាក់ និងជួយជ្រោមជ្រែងដែរឬទេ ?

### សំនួរត្រូវសួរចល់អ្នកឱ្យប្រាក់ខ្ចីណាម្នាក់ :

- តើមានប្រភេទប្រាក់កម្ចីអ្វីខ្លះ ?
- តើមានតម្រូវការទ្រព្យបញ្ចាំអ្វីខ្លះ ?
- តើមានតម្រូវការប្រាក់សន្សំអ្វីខ្លះ ?
- តើមានអាត្រាការប្រាក់ប៉ុន្មាន ?
- តើត្រូវបង់ថ្លៃរដ្ឋបាលប៉ុន្មាន សម្រាប់ការខ្ចីប្រាក់នោះ ?
- តើមានការបង់ប្រាក់ពិន័យអ្វីខ្លះ នៅពេលមានការសងយឺតយ៉ាវ ?
- តើត្រូវប្រើរយៈពេលប៉ុន្មានដើម្បីទទួលបានប្រាក់កម្ចីនោះ ?
- តើអ្នកត្រូវទៅកាន់ការិយាល័យផ្តល់ប្រាក់កម្ចីនោះប៉ុន្មានលើក ដើម្បីបំពេញទម្រង់ស្នាមស្នើសុំប្រាក់កម្ចី ?

### តើបំណុលប៉ុន្មានដែលអ្នកអាចដោះស្រាយបាន ?

បំណុលធ្ងន់ធ្ងរពេកអាចបណ្តាលឱ្យមានបញ្ហាពិបាក ។ ពាក្យថា " ការជាប់បំណុលធ្ងន់ធ្ងរ " គឺសំដៅលើបំណុលគ្រួសារដែលមានបំណុលខ្ពស់ បើប្រៀបធៀបទៅនឹងប្រាក់ចំណូលគ្រួសារ ។ តើអ្នកគណនាយ៉ាងដូចម្តេច ដើម្បីដឹងថាតើបំណុលមានទម្ងន់ធ្ងន់ប៉ុណ្ណោះនោះ ? ជាអកុសល វាមិនមានវិធីសាស្ត្រអ្វី ក្រៅពីផ្អែកលើបទពិសោធន៍នានាអំពីសុវត្ថិភាពបំណុល ដែលប្រៀបធៀបនឹងអាត្រាប្រាក់ចំណូលឡើយ ។ បើទោះបីជាយ៉ាងនេះក្តី គេច្រើនប្រើប្រាស់បំណុល ដែលមានចំនួនពី ២០ ទៅ ៣០ ភាគរយនៃប្រាក់ចំណូលគ្រួសារប៉ុណ្ណោះ។ តើគ្រួសាររបស់អ្នកគួរតែជៀសវាងការទទួលចំនួនប្រាក់កម្ចីច្រើនជាងមួយ ក្នុងពេលតែមួយឬ ? វាមិនចាំបាច់ទេ ។ អ្នកអាចទទួលប្រាក់កម្ចីជាកិច្ចសន្យាបន្ថែមទៀតបាន ប្រសិនបើអ្នកប្រឈមមុខនឹងវិបត្តិ ហើយត្រូវការសាច់ប្រាក់ជាបន្ទាន់ណាមួយ ។

មុនពេលទទួលយកប្រាក់កម្ចី អ្នកគួរគប្បីពិចារណាទៅលើថ្លៃចំណាយ និងហានិយភ័យនៃការខ្ចីប្រាក់ ។ ចូរឆ្លើយសំណួរដូចខាងក្រោមនេះ ដោយផ្អែកលើស្ថានភាពរបស់អ្នកផ្ទាល់ :

១. តើថវិកាគ្រួសារ ឬថវិកាអាជីវកម្មរបស់ខ្ញុំប៉ុន្មានភាគរយ ដែលខ្ញុំអាចរកបានសម្រាប់ការសងបំណុល ? តើខ្ញុំនឹងមានប្រាក់សេសសល់គ្រប់គ្រាន់ ដើម្បីប្រើប្រាស់សម្រាប់ការចំណាយនានាក្នុងគ្រួសារដែរឬទេ ?
២. តើអ្នកធានាទាំងឡាយរបស់ខ្ញុំអាចសងប្រាក់កម្ចីរបស់ខ្ញុំបានដែរឬទេ ? តើពួកគេនឹងមានអារម្មណ៍យ៉ាងណាចំពោះខ្ញុំ ប្រសិនបើពួកគេត្រូវសងជំនួសខ្ញុំនោះ ?
៣. តើមានផលវិបាកអ្វីខ្លះ ប្រសិនបើខ្ញុំមិនអាចសងប្រាក់កម្ចីរបស់ខ្ញុំបាន? តើទ្រព្យបញ្ចាំមានតម្លៃប៉ុន្មាន (ឧ. ម៉ូតូ ផ្ទះ ។ល។) ដែលខ្ញុំបានដាក់ទៅក្នុងកិច្ចសន្យាសងនោះ ?

## ការគ្រប់គ្រងបំណុល

ក្នុងនាមជាអ្នកខ្ចីប្រាក់ម្នាក់ វាអាចធ្វើឱ្យអ្នកធ្លាក់ទៅក្នុងអន្ទាក់បំណុលនេះបាន ។ ពីព្រោះវាកើតឡើងយ៉ាងយឺតៗ ហើយអ្នកមិនអាចមើលឃើញវាកំពុងតែមករកអ្នកនោះទេ ។ ភ្លាមនោះ អ្នកធ្លាក់ខ្លួនជំពាក់គេច្រើនជាងលទ្ធភាពដែលអ្នកអាចរកប្រាក់សងបាន ហើយគ្មានវិធីគេចចេញពីអន្ទាក់បំណុលនោះ បានឡើយ ! អ្នកនឹងត្រូវសងប្រាក់ការជាបន្តបន្ទាប់ ហើយមានសេចក្តីសង្ឃឹមតិចតួចក្នុងការសងប្រាក់កម្ចីវិញបាន ។

ការមានបំណុលយូរអង្វែង គឺជាកត្តាមួយដែលធ្វើឱ្យជនក្រខ្សត់ស្ថិតនៅក្នុងភាពក្រីក្រ។ ចំពោះមនុស្សភាគច្រើន ការរស់នៅជាមួយនឹងបំណុល គឺតែងតែកើតមាន និងបន្តកើតមានជាធម្មតា ។ ពីព្រោះសេចក្តីត្រូវការប្រាក់ឥណទានជាពិសេសនោះ គឺមិនទៅណាឆ្ងាយឡើយ អ្នកទំនងជាបន្តប្រើប្រាស់ប្រាក់កម្ចី ថ្មីៗទៀត ។ ជាក់ស្តែង នៅពេលជួបនឹងកាលៈទេសៈផ្លាស់ប្តូរណាមួយ អ្នកអាចត្រូវការប្រាក់កម្ចីជាច្រើន នៅក្នុងពេលតែមួយ ។ ការណ៍នេះ អាចកើតឡើង នៅពេលអ្នកត្រូវប្រឈមមុខជាមួយនឹងវិបត្តិ ហើយសេចក្តីត្រូវការសាច់ប្រាក់ភ្លាមៗ ។

មិនចំពោះថា ការគ្រប់គ្រងបំណុលដែលកំពុងតែមាន ឬការសម្រេចចិត្តទៅលើលទ្ធភាពរបស់អ្នកក្នុងការទទួលយកប្រាក់កម្ចីជាលើកទីពីរនោះទេ ជាការសំខាន់នោះគឺ ត្រូវធ្វើឱ្យប្រាកដថា កាតព្វកិច្ចនានាសម្រាប់ការសងបំណុលទាំងនោះ នឹងមិនត្រួតត្រាលើជីវិតរបស់អ្នកឡើយ ។ ចំណុចនោះហើយដែលអ្នកនៅតែអាចបង់ថ្លៃចំណាយសម្រាប់សេចក្តីត្រូវការចាំបាច់ និងចំណាយប្រចាំថ្ងៃទាំងឡាយបាន ។ មានគោលការណ៍ ពីរយ៉ាងដែលជួយឱ្យអ្នកអាចត្រួតត្រាលើបំណុលរបស់អ្នកបានគឺ :

**១, កុំខ្ចីប្រាក់ច្រើនជាងលទ្ធភាពដែលអ្នកអាចរកសងបាន ។**
**២, សន្សំប្រាក់ឱ្យទៀងទាត់សម្រាប់ពេលមានភាពបន្ទាន់នានា ដើម្បីកុំឱ្យអ្នកត្រូវការប្រាក់កម្ចីរាល់ពេលមានអាសន្ន ។**